


















# ការបៀតបៀននិងអំពើហិង្សាយេនឌ័រលើអ្នកធ្វើការតាមផ្ទះ

## ករណីរឿងកើតឡើងក្នុងបណ្ដាប្រទេសអាស៊ី

សហព័ន្ធអ្នកធ្វើការតាមផ្ទះអន្តរជាតិ ( IDWF )




**បោះពុម្ពផ្សាយលើកទីមួយនៅខែមេសា ឆ្នាំ២០២០**

ការបៀតបៀននិងអំពើហិង្សាយេនឌ័រលើអ្នកធ្វើការតាមផ្ទះ៖ ករណីរឿងកើតឡើងក្នុងបណ្ដាប្រទេសអាស៊ី - ហុងកុង៖ IDWF

ISBN 978-988-74574-2-8 (web pdf)

International Domestic Workers Federation (IDWF)

**---**

**អំពីសហព័ន្ធអ្នកធ្វើការតាមផ្ទះអន្តរជាតិ** ( IDWF)

សហព័ន្ធអ្នកធ្វើការតាមផ្ទះអន្តរជាតិ (IDWF) គឺជាអង្គការសមាជិកភាពសកលអ្នកធ្វើការតាមផ្ទះ។ គោលបំណងរបស់អង្គការនេះគឺកសាងស្ថាប័នអ្នកធ្វើការតាមផ្ទះជាសកលដ៏រឹងមាំ ប្រជាធិបតេយ្យ និងដោយការរួបរួមមួយដើម្បីការពារនិងលើកកម្ពស់សិទ្ធិរបស់អ្នកធ្វើការតាមផ្ទះគ្រប់ទីកន្លែងក្នុងពិភពលោក។ គិតត្រឹមខែមីនា ឆ្នាំ២០២០ IDWF មានសមាជិកចំនួន ៧៤ ក្នុងប្រទេសចំនួន ៥៧ ដែលតំណាងឲ្យសមាជិកអ្នកធ្វើការតាមផ្ទះសរុបជាង ៥០០ ០០០ នាក់។ សមាជិកភាគច្រើនត្រូវបានចងក្រងឡើងជាលក្ខណៈសហជីព សមាគម បណ្ដាញ និងសហករណ៍កម្មករជាដើម។

www.idwfed.org

---

**Cover photos**

**Top row left: Ivan Abreu/rights exposure © CC BY- NC - ND – baby jane allas during interview for the documentary “the price of justice”, 12 march 2019.**
**Top row middle: celebration of international domestic workers day on 16 June 2019. Photo: FADWU**
**Top row right: JALA PRT Indonesia**
**Middle row (both photos): GKS India**
**Third row left: kompas.com/RobertusBelarminus**
**Third row middle: JALA PRT Indonesia**

**Third row right:**

**NDWF India**

**Design and layout:**

**m+m studios**

**កំណាព្យ តែងនិពន្ធដោយអ្នកស្រី Murni ប្រទេសឥណ្ឌូនេស៊ី ថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៦**

កង់នៃវាលវដ្តសង្សារជីវិតបន្តវិលឥតឈប់

សេចក្តីរីករាយនិងទុក្ខព្រួយ សុភមង្គលនិងទុក្ខវេទនា ផ្អែមនិងល្វីងជូរចត់

ទោះបីជាមានរសជាតិល្វីងជូរចត់ក្នុងជីវិតដែលខ្ញុំកំពុងរស់នៅក្តី

ខ្ញុំនឹងនៅតែបន្តញញឹម

ញញឹមសម្រាប់មនុស្សដែលនៅក្បែរខ្ញុំ

ខ្ញុំនឹងបន្តប្រយុទ្ធ

ដើម្បីការពារយុត្តិធម៌សម្រាប់មនុស្សគ្រប់គ្នានិងពិភពលោកជាទីស្រឡាញ់មួយនេះ៕

សវនាការរបស់អ្នកស្រី Murni ក្នុងតុលាការ



រូបភាព: www.wowkeren.com

*Roda kehidupan akan terus berputar*

*Suka maupun duka, senang maupun susah*

*Manis maupun pahit*

*Meskipun pahit yang aku jalani*

*Aku akan tetap terus tersenyum*

*Untuk semua*

*Yang ada di dekat ku*

*Aku akan terus berjuang*

*Demi membela keadilan untuk semua orang*

*Dan duniaku tercinta*




## អក្សរកាត់

| | |
|---|---|
| ADW | សមាគមអ្នកធ្វើការតាមផ្ទះ ប្រទេសកម្ពុជា |
| C189 and R201 | អនុសញ្ញាអាយឡូ (ILO) លេខ១៨៩ និងអនុសាសន៍លេខ ២០១ ស្តីអំពីការងារសមរម្យសម្រាប់អ្នកធ្វើការតាមផ្ទះ |
| C190 and R206 | អនុសញ្ញាអាយឡូ (ILO) លេខ១៩០ និងអនុសាសន៍លេខ ២០៦ ស្តីអំពីការលុបបំបាត់ការបៀតបៀននិងអំពើហិង្សាក្នុងពិភពការងារ |
| DWO | អង្គការអ្នកធ្វើការតាមផ្ទះ |
| FADWU | សហព័ន្ធសហជីពអ្នកធ្វើការតាមផ្ទះអាស៊ីហុងកុង |
| GKS | Gharelu Kaamgar Sangathan, អង្គការអ្នកធ្វើការតាមផ្ទះ ទីក្រុង Gurgaon ក្នុងប្រទេសឥណ្ឌា |
| IDWF | សហព័ន្ធអ្នកធ្វើការតាមផ្ទះអន្តរជាតិ |
| ILO | អង្គការពលកម្មអន្តរជាតិ ឬហៅកាត់អាយឡូ (ILO) |
| JALA PRT | Jaringan Nasional Advokasi Pekerja Pembantu Rumah Tangga បណ្តាញការតស៊ូមតិអ្នកធ្វើការតាមផ្ទះជាតិ ប្រទេសឥណ្ឌូនេស៊ី |
| NDWM | ចលនាអ្នកធ្វើការតាមផ្ទះជាតិ ប្រទេសឥណ្ឌា |
| NDWWU | សហជីពស្ត្រីអ្នកធ្វើការតាមផ្ទះជាតិ ប្រទេសបង់ក្លាដែស |
| SKDWA | សមាគមអ្នកធ្វើការតាមផ្ទះសាន់ឌីហ្គូន-គុយវ៉ែត |
| UN | អង្គការសហប្រជាជាតិ |
| UNITED | សហព័ន្ធរួបរួមអ្នកធ្វើការតាមផ្ទះ ប្រទេសហ្វីលីពីន |

# មាតិកា


**បុព្វកថា** ........................................................................................ 7

**សេចក្តីផ្តើម** .................................................................................... 9

**ករណីរឿង** ...................................................................................... 12

អ្នកស្រី Murni និង JALA PRT, ទីក្រុងចាកាតា, ឥណ្ឌូនេស៊ី ........ 15

អ្នកស្រី ស្រីមុំ និង ADW, ទីក្រុងភ្នំពេញ, កម្ពុជា ....................... 19

អ្នកស្រី Riza R. Amahan និង UNITED, ទីក្រុងម៉ានីល, ហ្វីលីពីន. 23

អ្នកស្រី Sunita Ekka និង NDWM, ទីក្រុង Patna, ឥណ្ឌា ........... 26

អ្នកស្រី Sabina Khutan និង GKS, ទីក្រុង Gurgaon, ឥណ្ឌា...... 30

អ្នកស្រី Anowara Begum និង NDWWU, ទីក្រុងដាកា, បង់ក្លាដែស.. 36

អ្នកស្រី Maria និង SKDWA, ទីក្រុងគុយវ៉ែត, គុយវ៉ែត................ 40

អ្នកស្រី Baby Jane allas និង FADWU, ក្រុង Yuen long, ហុងកុង. 44

**ការវិភាគនិងការពិភាក្សា** ...................................................49

**សេចក្តីបញ្ចប់និងផ្លូវឆ្ពោះទៅមុខ** ........................................58

**ឯកសារយោង** ..................................................................62

**ឧបសម្ព័ន្ធ៖ របៀបសម្ភាសនិងតារាងផ្ទៀងផ្ទាត់ទិន្នន័យ** .....63

**ទំនាក់ទំនងស្ថាប័ននានា**.......................................................66




ក្រុមអ្នកធ្វើការតាមផ្ទះចំណាកស្រុកប្រារព្ធ«ទិវាអ្នកធ្វើការតាមផ្ទះអន្តរជាតិ» ក្នុងប្រទេសម៉ាឡេស៊ី ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៩

ស្ថិតក្នុងការចងចាំចំពោះ

ប្អូនស្រី Sabina Khuta (២០០០-២០១៤) និងបងស្រីមុំ (១៩៩០-២០២០)

សូមឲ្យព្រលឹងប្អូននិងបងស្រីទៅកាន់សុគតិភព ទៅកាន់កន្លែងស្ងប់សុខ គ្មានការឈឺចាប់ គ្មានទុក្ខព្រួយ។

ភាពក្លាហាននិងការលះបង់របស់អ្នកទាំងពីរ ជំរុញឱ្យយើងបន្តប្រយុទ្ធដើម្បីទាមទារសិទ្ធិសេរីភាពនិងយុត្តិធម៌សម្រាប់អ្នកធ្វើការតាមផ្ទះទាំងអស់ឱ្យទទួលបានការងារសមរម្យ និងការរស់នៅមិនមានអំពើហិង្សា ការបៀតបៀន និងការរើសអើង។

អ្នកធ្វើការតាមផ្ទះភាគច្រើនជាស្ត្រីដែលខិតខំធ្វើការដើម្បីរួចផុតពីភាពក្រីក្រ និងទទួលបាននូវជីវភាពរស់នៅសមរម្យសម្រាប់ខ្លួនឯងនិងគ្រួសារ។ ដូចអ្នកធ្វើការដទៃទៀតដែរ ពួកគេចង់ស្វែងរកប្រាក់កំរៃសមរម្យ ទទួលបានការផ្តល់តម្លៃ ការគោរព និងសេចក្តីថ្លៃថ្នូរ និងទទួលបានការការពារពលកម្មនិងការគាំពារសង្គមផងដែរ។

ប៉ុន្តែជារឿយៗ ការធ្វើការងារតាមផ្ទះគឺមិនត្រូវបានគេផ្តល់តម្លៃ និងជាការងារដែលទទួលបានប្រាក់កម្រៃទាប។ មូលហេតុគឺដោយសារតែការងារផ្ទះជាការងារដែលធ្វើដោយស្ត្រីដែលប្រៀបបានដូចជាការងារផ្ទះដែលពួកគេធ្វើនៅផ្ទះគ្រួសាររបស់ពួកគាត់អីចឹង។ បន្ថែមពីនេះ ការងារផ្ទះគឺជាការងារដែលធ្វើក្នុងផ្ទះ ហើយមិនត្រូវបានឲ្យតម្លៃថាជា«ការងារ» ប៉ុន្តែត្រូវបានគេគិតថាជាការងារស្រាលៗ និងងាយស្រួលដែលក្មេងៗ«អាចជួយធ្វើបាន»។ ដូចនេះហើយបានជាអ្នកធ្វើការងារតាមផ្ទះនេះមិនត្រូវបានគេចាត់ចូលក្នុងចំណោមជា«កម្មករឬបុគ្គលិកការងារ»ឡើយ។ ហើយពួកគេមិនស្ថិតនៅក្រោមការការពារពីច្បាប់ដែលមានប្រសិទ្ធភាព ព្រមទាំងងាយទទួលរងគ្រោះពីការរំលោភបំពាន ការមើលងាយ និងការកេងប្រវ័ញ្ចជាដើម។

ពួកយើងដែលជាធ្វើការតាមផ្ទះហើយភាគច្រើនគឺរស់នៅតាមផ្ទះឯកជនរបស់អ្នកដទៃឬផ្ទះនយោជកតែងប្រឈមនឹងហានិភ័យខ្ពស់នៃការរងទុក្ខពីការយាយី ការបៀតបៀន និងអំពើហិង្សា ដូចជាអំពើហិង្សាយេនឌ័រជាដើម។ ពួកយើងភាគច្រើនជាស្ត្រីនិងក្មេងស្រី ហើយមួយចំនួនទៀតជាបុរសនិងក្មេងប្រុស ដែលសុទ្ធតែអ្នកមកពីគ្រួសារដែលមានជីវភាពក្រីក្រដែលប្រកបការងារដែលមិនស្ថិតក្នុងក្រសែភ្នែករបស់សាធារណជន។ ការយីយាការគំរាមកំហែងផ្សេងៗ បានបង្ខំពួកយើងឱ្យធ្វើការលើសចំនួនម៉ោងកំណត់ មិនឬទទួលបានការប្រាក់ឈ្នួលទាប និងការធ្វើការងារដែលមានភាពគ្រោះថ្នាក់ខ្លាំង។ ពួកយើងអស់សង្ឃឹម យើងទទួលរងការឈឺចាប់ ខាតបង់ និងជួនកាលបាត់បង់ទឹកចិត្តក្នុងការបន្តដំណើរទៅមុខផងដែរ។ ការងារតាមផ្ទះគឺជាការងារមួយដែលប្រៀបបានដូចទាសភាពដែលកំពុងមានវត្តមានពាសពេញពិភពលោកនាពេលបច្ចុប្បន្ននេះ។ ពួកយើងមួយចំនួនត្រូវបានឃាត់ឃាំងមិនអនុញ្ញាតឲ្យចាកចេញពីផ្ទះនយោជក ហើយយើងមួយចំនួនទៀតបានត្រូវក្លាយជាជនរងគ្រោះពីការរំលោភ ទារុណកម្ម និងឃាតកម្មផងដែរ។

ពួកយើងទាំងគ្នាដែលជាអ្នកធ្វើការតាមផ្ទះ ដែលបានរួមគ្នាជាសហព័ន្ធអ្នកធ្វើការតាមផ្ទះអន្តរជាតិ (IDWF) មានជំនឿជាក់យ៉ាងមុតមាំថាការរំលោភបំពានទាំងអស់នេះមកលើពួកយើងត្រូវតែដល់ពេលបញ្ចប់ហើយ។ ពួកយើងបានប្រឹងប្រែងយ៉ាងខ្លាំងក្នុងការអនុម័តនូវស្តង់ដារការងារពលកម្មអន្តរជាតិស្តីអំពីការទទួលបានការងារសមរម្យសម្រាប់អ្នកធ្វើការងារតាមផ្ទះកាលពីឆ្នាំ ២០១១ និងការបញ្ឈប់រាល់នូវការបៀតបៀននិងអំពើហិង្សាផ្សេងៗក្នុងពិភពការងារក្នុងឆ្នាំ ២០១៩។ អ្នកធ្វើការតាមផ្ទះគ្រប់រូបសមនឹងទទួលបានសិទ្ធិទាំងដូចអ្នកធ្វើការការងារផ្សេងៗផងដែរ។ ពួកគេត្រូវតែមានការងារនិងជីវិតរស់នៅដែលគ្មានអំពើហិង្សាជាដាច់ខាត។ សារដ៏មានសារៈសំខាន់នេះត្រូវតែប្រកាសនិងផ្សព្វផ្សាយឲ្យដឹងជាសាធារណៈ ខណៈមានអ្នកធ្វើការតាមផ្ទះជាច្រើនរូបកំពុងទទួលរងនូវបញ្ហាទាំងនេះដោយស្ងាត់ៗ។

ទ្វីបអាស៊ីគឺជាតំបន់ដែលមានអ្នកធ្វើការតាមផ្ទះច្រើនជាងគេក្នុងពិភពលោក។ អ្នកធ្វើការតាមផ្ទះចំនួន៤នាក់ក្នុងចំណោមអ្នកធ្វើការតាមផ្ទះ៥នាក់គឺជាស្ត្រី និងមួយចំនួនធំគឺជាកុមារ ភាគច្រើនជាក្មេងស្រីនិងមានក្មេងប្រុសផង

ដែរ។

មានស្ត្រីអាស៊ីជាច្រើននាក់ដែលធ្វើចំណាកស្រុកទៅធ្វើការនៅការទីកន្លែងនិងប្រទេសផ្សេងៗក្នុងពិភពលោក។ ពួកគេព្យាយាមស្វែងរកប្រាក់កម្រៃដើម្បីផ្គត់ផ្គង់ដល់ក្រុមគ្រួសាររបស់ពួកគេនៅស្រុកកំណើត ប៉ុន្តែត្រូវប្រឈមបញ្ហាមួយចំនួនដល់ខ្លួនឯង។ ពួកគេត្រូវរងការមើលងាយ និងរើសអើង ពីព្រោះដោយសារតែពួកគេជាស្ត្រីភេទមកពីពូជសាសន៍ផ្សេង មានពណ៌សម្បុរ សាសនា និងឋានៈតូចទាបក្នុងសង្គម។ ហើយពួកគេទទួលការរំលោភបំពានដោយសារតែពួកគេមានឋានៈនិងស្ថានភាពសេដ្ឋកិច្ចទាបជាងនយោជករបស់គេ។

ពួកយើងដែលជាអង្គការអ្នកធ្វើការតាមផ្ទះក្នុងតំបន់អាស៊ី និងប្រទេសគុយវ៉ែត និងសមាជិករបស់សហព័ន្ធអ្នកធ្វើការតាមផ្ទះអន្តរជាតិ (IDWF) បានធ្វើការចងក្រងសៀវភៅកំណត់ហេតុនេះឡើងក្នុងគោលបំណងដើម្បីចែករំលែកនូវរឿងរ៉ាវដែលបានកើតឡើងពិតចំពោះអ្នកធ្វើការតាមផ្ទះក្នុងតំបន់អាស៊ីដែលបានឆ្លងកាត់និងទទួលរងទុក្ខលំបាកពីការប្រើប្រាស់អំពើហិង្សា និងការគំរាមកំហែងអាយុជីវិតដោយសារតែការងារដែលពួកគេបានធ្វើ។ មិនត្រឹមតែប៉ុណ្ណោះទេ ពួកយើងក៏ចែករំលែកពីបញ្ហាប្រឈម ភាពជោគជ័យ និងឧបសគ្គ ភាពពិបាកទាំងឡាយដែលពួកយើងបានឆ្លងកាត់ក្នុងការពុះពារជួយពួកគេស្វែងរកយុត្តិធម៌ផងដែរ។

ពួកយើងសង្ឃឹមថាកម្រងរឿងរ៉ាវពិតនៃការរំលោភបំពានយេនឌ័រទៅលើអ្នកធ្វើការតាមផ្ទះនឹងដាស់តឿនបន្ថែមនិងជំរុញលើកទឹកចិត្តបន្ថែមដល់អ្នកធ្វើការតាមផ្ទះនិងអង្គភាពរបស់ពួកគេ នយោជក ស្ថាប័ននានា រដ្ឋាភិបាលនិងភាគីពាក់ព័ន្ធផ្សេងទៀតក្នុងការចូលរួមប្រឆាំងនឹងការបៀតបៀននិងអំពើហិង្សានិងការគំរាមកំហែងដែលអ្នកធ្វើការតាមផ្ទះ។ ពួកយើងបញ្ចេញសកម្មភាពទាំងឡាយដើម្បីទាមទារឲ្យមានប្រព័ន្ធច្បាប់មានប្រសិទ្ធភាពនិងយន្តការណ៍ជំរុញការអនុវត្តច្បាប់ដើម្បីទប់ស្កាត់និងបញ្ឈប់នូវរាល់សកម្មភាពគំរាមកំហែងគ្រប់ទម្រង់ទាំងអស់។

អ្នកស្រី Novelita V. Palisoc
គណៈកម្មាធិការប្រតិបត្តិ (សមាជិកពេញសិទ្ធិ) អាស៊ី, IDWF




រយៈពេល១៦ថ្ងៃនៃសកម្មភាពប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាយេនឌ័រ៖ ចាប់ពីថ្ងៃទី២៥ ខែវិច្ឆិកា រហូតដល់ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១៩

## សេចក្តីផ្តើម

“

អំពើហិង្សាយេនឌ័របានក្លាយជាឃាតករលាក់មុខសម្រាប់អ្នកធ្វើការតាមផ្ទះ ជាច្រើននាក់នៅជុំវិញពិភពលោក ដោយសារតែពួកយើងខ្លាចមិនហ៊ាន និយាយចេញក្រៅ និងខ្លាចបាត់បង់ការងារធ្វើ។ យើងត្រូវតែតម្លើងសម្លេង របស់ពួកយើងដើម្បីបញ្ឈប់ការរំលោភបំពានមួយនេះ។

**អ្នកស្រី Myrtle Witbooi ប្រធាន សហព័ន្ធអ្នកធ្វើការតាមផ្ទះអន្តរជាតិ (IDWF)**

សហព័ន្ធអ្នកធ្វើការតាមផ្ទះអន្តរជាតិ (IDWF) គឺជាអង្គការសមាជិកភាពសកលអ្នកធ្វើការតាមផ្ទះ។ គិតត្រឹមខែមីនា ឆ្នាំ២០២០ IDWF មានសមាជិកចំនួន ៧៤ ក្នុងប្រទេសចំនួន ៥៧ ដែលតំណាងឱ្យសមាជិកអ្នកធ្វើការតាមផ្ទះសរុបជាង ៥០០ ០០០ នាក់។ អ្នកធ្វើការងារតាមផ្ទះគឺជាបុគ្គលដែលបំពេញការងារសព្វបែបយ៉ាងក្នុងផ្ទះដោយមានទំនាក់ទំនងជាការងារចញ្ចឹមជីវិត។ អ្នកធ្វើការតាមផ្ទះត្រូវបានចងក្រងឡើងជាសហជីព សមាគម សហករណ៍ និងបណ្តាញកម្មករជាដើម។ យើងមានការសង្ឃឹមជឿជាក់យ៉ាងមុតមាំថាការងារផ្ទះគឺជាការងារ ហើយអ្នកធ្វើការតាមផ្ទះក៏ជាត្រូវតែទទួលបានសិទ្ធិដូចគ្នានឹងបុគ្គលិកការងារផ្សេងទៀតដែរ។ យើងកំពុងកសាងស្ថាប័នអ្នកធ្វើការតាមផ្ទះជាសកលដ៏រឹងមាំ ប្រជាធិបតេយ្យ និងដោយការរួបរួមមួយដើម្បីការពារនិងលើកកម្ពស់សិទ្ធិរបស់អ្នកធ្វើការតាមផ្ទះគ្រប់ទីកន្លែងក្នុងពិភពលោក។

ចាប់ពីឆ្នាំ ២០០៩ កន្លងមកសហព័ន្ធអ្នកធ្វើការតាមផ្ទះអន្តរជាតិ (IDWF) បានចូលរួមគាំទ្រយ៉ាងសកម្មដល់ការបង្កើតស្តង់ដារការងារអន្តរជាតិស្តីអំពីការងារសមរម្យសម្រាប់អ្នកធ្វើការតាមផ្ទះ។ ក្នុងឆ្នាំ ២០១១ រដ្ឋសមាជិករបស់អង្គការពលកម្មអន្តរជាតិ ឬហៅកាត់អាយឡូ (ILO) ដែលបានប្រមូលផ្តុំរដ្ឋាភិបាល អង្គការ ស្ថាប័ននិយោជិកនិងនិយោជកមកពីជុំវិញពិភពលោក បានសម្រេចលើការងារជោគជ័យធំធេងមួយ នៅពេលដែលពួកគេបានអនុម័តអនុសញ្ញាលេខ ១៨៩ (C១៨៩) និងអនុសាសន៍លេខ ១៩០ (R១៩០) ស្តីអំពីការលើកកម្ពស់ការងារសមរម្យសម្រាប់អ្នកធ្វើការតាមផ្ទះ។

អនុសញ្ញាលេខ ១៨៩ (C189) ចង្អុលបង្ហាញពីហានិភ័យខ្ពស់នៃអំពើហិង្សាលើអ្នកធ្វើការតាមផ្ទះ៖ « ...ការងារផ្ទះនៅតែមានមិនបានគេមើលឃើញនិងឲ្យតម្លៃនិងជាការងាររបស់ស្ត្រីនិងក្មេងស្រីដែលភាគច្រើនជាជនចំណាកស្រុក ឬជាសមាជិកសហគមន៍ទន់ខ្សោយដែលជួបការលំបាក»។ អនុសញ្ញានេះប្រកាសផងដែរថាអ្នកធ្វើការតាមផ្ទះងាយរងគ្រោះដោយសារការរើសអើងនៅកន្លែងការងារនិងការរំលោភសិទ្ធិមនុស្សដទៃទៀត (លំនាំដើម) និងអំពាវនាវឱ្យមានវិធានការនានា «ដើម្បីធានាឲ្យបានថាអ្នកធ្វើការតាមផ្ទះទាំងអស់ទទួលបានការការពារប្រកបដោយប្រសិទ្ធភាពប្រឆាំងរាល់ទម្រង់នៃការរំលោភបំពាន បៀតបៀន និងអំពើហិង្សានានា» (មាត្រា ៥) ។

នៅលើឆាកអន្តរជាតិ ក្នុងឆ្នាំ ២០១៨ IDWF បានចូលរួម វេទិកាទាមទារស្តីអំពីការបៀតបៀននិងអំពើហិង្សាប្រឆាំងស្ត្រីនិងបុរសក្នុងពិភពការងារ (Platform of Demands on Violence and Harassment against Women and Men in the World of Work) ដើម្បីបង្ហាញពីទុក្ខកង្វល់របស់អ្នកធ្វើការតាមផ្ទះនិងគាំទ្រដល់ដំណើរការកំណត់ស្តង់ដារការងារអន្តរជាតិរបស់អាយឡូ (ILO) ក្នុងការបង្កើតនិងអភិវឌ្ឍស្តង់ដារការងារអន្តរជាតិប្រឆាំងនឹងការបៀតបៀននិងអំពើហិង្សាគ្រប់ទម្រង់ក្នុងពិភពការងារ។ នៅក្នុងខែមិថុនា ឆ្នាំ២០១៩ នៅក្នុងសន្និសីទការងារអន្តរជាតិ (International Labour Conference) រដ្ឋសមាជិក ILO បានអនុម័តលើអនុសញ្ញាលេខ ១៩០ (C១៩០) និងអនុសាសន៍លេខ ២០៦ (R២០៦) ដើម្បីលុបបំបាត់ការបៀតបៀននិងអំពើហិង្សាក្នុងពិភពការងារ។

សន្និបាតលើកទី ២ របស់ IDWF នៅប្រទេសអាហ្វ្រិកខាងត្បូង ក្នុងឆ្នាំ ២០១៨ សមាជិក IDWF បានអនុម័តដំណោះស្រាយដើម្បីលុបបំបាត់អំពើហិង្សាយេនឌ័រ (Resolution to Eradicate Gender-Based Violence) ដែលជាគោលការណ៍ក្នុងរយៈពេល ៥ ឆ្នាំខាងមុខនេះ។ ការដាក់ចេញនូវគោលការណ៍ដំណោះស្រាយនេះគឺដើម្បីប្រកាសឲ្យដឹងនិងមានការមើលឃើញកាន់តែច្បាស់នៃអំពើហិង្សាយេនឌ័រ និងការតស៊ូមតិក្នុងគោល

នៅទ្វីបអាស៊ី ក្នុងឆ្នាំ ២០១៧-២០១៨ IDWF បានធ្វើការស្ទង់មតិមួយស្តីអំពី អំពើហិង្សាយេនឌ័រទៅលើអ្នកធ្វើការងារតាមផ្ទះ ទៅលើអង្គការអ្នកធ្វើការតាមផ្ទះ (DWOs) ចំនួន ១៣ នៅក្នុងប្រទេសចំនួន ១២។ ការស្ទង់មតិនោះបានរកឃើញចំណុចសំខាន់ៗដូចជា៖

- អង្គការទាំងអស់សុទ្ធតែបានទទួលពាក្យបណ្តឹងពាក់ព័ន្ធការបៀតបៀននិងអំពើហិង្សាដែលសមាជិករបស់ពួកគេបានប្រឈម។
- ជនល្មើសគឺជានិយោជក និងអ្នកដទៃទៀតនៅក្នុងផ្ទះរបស់នយោជក អន្តរការីការងារ (ភាគីស្វែងរកការងារ) ឬសមាជិកគ្រួសារនយោជកផ្ទាល់។
- ប្រភេទអំពើហិង្សាយេនឌ័រដែលគេតែងតែឃើញកើតមានជាញឹកញាប់ទៅលើសមាជិកអ្នកធ្វើការតាមផ្ទះរួមមាន ការរំលោភបំពានផ្នែកសេដ្ឋកិច្ច ការរំលោភបំពានផ្លូវចិត្ត ការរំលោភបំពានផ្លូវកាយ និងការបំលោភបំពានផ្លូវភេទ ការរំលោភបំពានដោយពាក្យសម្តី និងកង្វះការទទួលបានអាហារបរិភោគសមរម្យ។
- ប្រភេទអំពើហិង្សាដែលមិនសូវកើតមានជាញឹកញាប់ ប៉ុន្តែគួរឲ្យព្រួយបារម្ភគឺការសម្លុត ការបង្ខិតបង្ខំ ការរំលោភលើសិទ្ធិឯកជន និងការដកហូតប្រាក់ខែជាដើម។
- អង្គការអ្នកធ្វើការតាមផ្ទះដែលចូលរួមក្នុងការផ្តល់ការស្រង់មតិនេះភាគច្រើនចាត់ទុកអំពើហិង្សាយេនឌ័រជារឿងអាទិភាពមួយ។ ពួកគេបានបញ្ជាក់ពីតម្រូវការក្នុងការលើកកម្ពស់ ការយល់ដឹង ការតស៊ូមតិ និងការបណ្តុះបណ្តាលអំពីវិធីដោះស្រាយអំពើហិង្សា និងការបៀតបៀនក្នុងចំណោមអ្នកធ្វើការតាមផ្ទះនិងសម្រាប់ការកសាងភាពជាដៃគូនិងសម្ព័ន្ធភាពប្រកបដោយប្រសិទ្ធភាពដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើហិង្សានេះ។



រូបភាព: JALA PRT

នៅដើមឆ្នាំ ២០១៩ IDWF បានអញ្ជើញសមាជិករបស់ DWO ទាំងអស់ដើម្បីធ្វើការរៀបរាប់រឿងរ៉ាវករណីអំពើហិង្សាលើអ្នកធ្វើការតាមផ្ទះក្នុងគោលបំណងបង្កើនការអំពាវនាវអំពីការបៀតបៀននិងអំពើហិង្សាយេនឌ័រដែលអ្នកធ្វើការតាមផ្ទះនៅតំបន់អាស៊ីកំពុងប្រឈមនិងដើម្បីចែករំលែកពីរបៀបដែល DWOs បានជួយជនរងគ្រោះដែលជួបទទួលរងអំពើហិង្សានេះ។ ករណីរឿងចំនួន ៨ ត្រូវបានរៀបរាប់នៅក្នុងសៀវភៅកំណត់ហេតុនេះ រួមទាំងមានមួយករណីមកពីសមាគមអ្នកធ្វើការតាមផ្ទះនៅសាន់ឌីហ្គីន (Sandigan Domestic Workers Association) នៅប្រទេសគុយវ៉ែត ដើម្បីបង្ហាញពីទំហំនៃការបៀតបៀននិងអំពើហិង្សាលើរាងកាយ។ IDWF បានចងក្រងរឿងរ៉ាវទាំងនេះជាមួយនឹងគោលបំណង៖

- កំណត់អត្តសញ្ញាណទម្រង់ផ្សេងៗគ្នានៃការបៀតបៀននិងអំពើហិង្សាយេនឌ័រលើអ្នកធ្វើការតាមផ្ទះ។
- បញ្ជ្រាបការយល់ដឹងកាន់តែស៊ីជម្រៅអំពីមូលហេតុដែលអ្នកធ្វើការតាមផ្ទះងាយរងគ្រោះពីការបៀតបៀននិងអំពើហិង្សាយេនឌ័រ
- ស្វែងយល់អំពីភាពលំបាកនិងយុទ្ធសាស្ត្រជោគជ័យក្នុងការការពារនិងប្រយុទ្ធប្រឆាំងនឹងការបៀតបៀននិងអំពើហិង្សាលើអ្នកធ្វើការតាមផ្ទះ។

រឿងរ៉ាវករណីហិង្សាទាំងអស់ពណ៌នានិងរៀបរាប់អំពីស្ថានភាពជីវិតពិតរបស់ជនរងគ្រោះ។ រឿងរ៉ាវទាំងនេះគឺរៀបរាប់ពីរឿងពិតរបស់អ្នកធ្វើការតាមផ្ទះចំនួន ៦ រូបមកពីប្រទេសបង់ក្លាដែស កម្ពុជា ឥណ្ឌា ឥណ្ឌូនេស៊ី និងហ្វីលីពីនដែលបានទទួលរងអំពើហិង្សានៅក្នុងប្រទេសរបស់ខ្លួន និងក្នុងចំណោមនោះដែរមានអ្នកធ្វើការតាមផ្ទះចំណាកស្រុកពីររូបមកពីប្រទេសហ្វីលីពីនដែលរងការរំលោភបំពាននៅទីក្រុងហុងកុង និងប្រទេសគុយវ៉ែត។ រឿងរ៉ាវភាគច្រើនបង្ហាញពីករណីកើតឡើងដ៏អាក្រក់បំផុតដែលមិនអាចទទួលយកបាននិងបង្កផលប៉ះពាល់លើជនរងគ្រោះ ប៉ុន្តែក៏មានផលវិជ្ជមានបង្ហាញពីភាពក្លាហាននិងភាពអត់ធ្មត់របស់ពួកគេផងដែរ។ ពួកគេបានរៀបរាប់អំពីប្រព័ន្ធច្បាប់ដែលត្រូវបានអនុវត្តដើម្បីប្រយុទ្ធប្រឆាំងនឹងអំពើហិង្សាបែបនេះ ឧបសគ្គដែល DWOs បានជំនះ ដោះស្រាយ និងយុទ្ធសាស្ត្រនិងវិធានការជាក់ស្តែងដែលពួកគេបានប្រើដើម្បីធ្វើសកម្មភាពប្រឆាំងនឹងការរំលោភបំពានទាំងនោះដោយជោគជ័យផងដែរ។

បញ្ហាប្រឈមមានច្រើនណាស់ពីព្រោះប្រព័ន្ធច្បាប់ការពារគ្រប់ជ្រុងជ្រោយនិងយន្តការផ្តល់លទ្ធភាពមិនមាននៅក្នុងប្រទេសភាគច្រើនទាំងអស់នោះ។ នៅក្នុងប្រទេសមួយចំនួននៅមានការកង្វះខាតការយល់ដឹងជាសាធារណៈ និងការគាំទ្រពីស្ថាប័ននានាដើម្បីអនុវត្តប្រកបដោយប្រសិទ្ធភាពដោយសារតែកត្តាយេនឌ័រ និងភាពលំអៀងចំពោះអ្នកធ្វើការតាមផ្ទះ។ ដើម្បីចូលរួមការពារការបៀតបៀននិងអំពើហិង្សាចាប់ពីការកើតឡើងនិងរហូតដល់ការស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះ DWOs ដែលបានចូលរួមនៅក្នុងរបាយការណ៍នេះបានសង្កត់ធ្ងន់លើតម្រូវការ៖ ព័ត៌មាននិងការទំនាក់ទំនង ការបង្កើតបណ្តាញនិងការចងក្រង ការគាំទ្រពីស្ថាប័នសាធារណៈនិងសង្គមស៊ីវិល ការលះបង់និងការតស៊ូរបស់ DWOs និងសមាជិករបស់ពួកគេ រួមទាំងការផ្តល់ជំនួយហិរញ្ញវត្ថុគ្រប់គ្រាន់ដល់ជនរងគ្រោះផងដែរ។







សហព័ន្ធអ្នកធ្វើការតាមផ្ទះអន្តរជាតិ (IDWF) សូមថ្លែងអំណរគុណចំពោះអ្នកធ្វើការតាមផ្ទះនិង DWOs ដែលបានចែករំលែករឿងរ៉ាវពិតរបស់ពួកគេនៅក្នុងសៀវភៅកំណត់ហេតុនេះ៖

- អ្នកនាង Murni និង JALA PRT, ប្រទេសឥណ្ឌូនេស៊ី
- អ្នកស្រី ស្រីមុំ និង ADW, ប្រទេសកម្ពុជា
- អ្នកស្រី Riza R. Amahan និង UNITED, ប្រទេសហ្វីលីពីន
- អ្នកនាង Sunita Ekka និង NDWM, ប្រទេសឥណ្ឌា
- កុមារី Sabina Khutan និង GKS, ប្រទេសឥណ្ឌា
- អ្នកស្រី Anowara Begum និង NDWWU ប្រទេសបង់ក្លាដែស
- អ្នកស្រី Maria និង SKDWA ប្រទេសគុយវ៉ែត
- អ្នកស្រី Baby Jane allas និង FADWU ទីក្រុងហុងកុង

សូមអរគុណចំពោះ៖ អ្នកស្រី Fish Ip សម្រាប់ការធ្វើបទសម្ភាសន៍និងការពិនិត្យឡើងវិញ, អ្នកស្រី Elizabeth Tang សម្រាប់ការណែនាំរួម, Siewhwa Lee សម្រាប់ការស្រាវជ្រាវ, Yuenmei Wong, Nelien Haspels និង Elsa Ramos – Carbon សម្រាប់ការព្រាង តាក់តែង សរសេរ និងកែសម្រួល។

# អ្នកនាង Murni និង JALA PRT, ទីក្រុងចាកាតា ប្រទេសឥណ្ឌូនេស៊ី


## បរិយាយដោយ Lita Anggraini

*អ្នកសម្របសម្រួលថ្នាក់ជាតិ, Jaringan Nasional Advokasi Pekerja Rumah Tangga (JALA PRT ឬ បណ្ដាញការតស៊ូមតិអ្នកធ្វើការតាមផ្ទះជាតិ)*








kompas.com

## អំពើរំលោភបំពាន

អ្នកនាង Murni (មិនមែនឈ្មោះពិត) កើតក្នុងឆ្នាំ ១៩៩៥ ក្នុងគ្រួសារមួយនៅតំបន់ Sundanese ក្នុងស្រុក Bogor ដែលជាតំបន់ភ្នំខ្ពស់នៅខាងក្រៅទីក្រុងចាកាតា រដ្ឋធានីនៃប្រទេសឥណ្ឌូនេស៊ី។ ឪពុករបស់នាងជាកសិករនិងជាអ្នកបើកឡាន និងមានម្ដាយជាស្ត្រីមេផ្ទះ។ នាង Murni គឺជាកូនស្រីច្បងក្នុងចំណោមបងប្អូន ៦ នាក់។

បន្ទាប់ពីបញ្ចប់ថ្នាក់បឋមសិក្សានៅអាយុ ១២ឆ្នាំ ម្ដាយមីងរបស់ Murni បានណែនាំឲ្យនាងធ្វើការតាមផ្ទះនៅគ្រួសារវណ្ណៈកណ្ដាលមួយនៅតំបន់ចាកាតាខាងកើត ដែលចំណាយពេលធ្វើដំណើរប្រមាណ ៣ ម៉ោងពីភូមិរបស់នាងនៅតំបន់ Bogor។ នាងបានយល់ព្រមធ្វើការជាអ្នកធ្វើការតាមផ្ទះ ដោយនាងត្រូវបាននយោជកសន្យាជួយរ៉ាប់រងបង់ប្រាក់សម្រាប់ការសិក្សាថ្នាក់វិទ្យាល័យរបស់នាង។ ប៉ុន្តែតាមពិតទៅនយោជកនោះមិនដែលបើកប្រាក់ខែឲ្យនាងសោះឡើយ។ លើសពីនេះទៅទៀត ពួកគេបានផ្ដល់អាហារតិចតួចដល់នាង ហើយហាមនាងមិនឱ្យទំនាក់ទំនងនិងប្រាស្រ័យទាក់ទងជាមួយនរណាម្នាក់នោះឡើយ។ នាងមិនត្រូវអនុញ្ញាតិឲ្យចាកចេញពីផ្ទះនោះទេ។

នាង Murni ទទួលខុសត្រូវផ្នែកចម្អិនអាហារ បោកគក់ និងសំអាតផ្ទះ៣ជាន់របស់នយោជកដែលបានមានអ្នកធ្វើការតាមផ្ទះ ៣ នាក់ទៀត ដោយម្នាក់គឺជាស្ត្រីមកពីតំបន់ Serang បុរសម្នាក់មកពីតំបន់ Tegal និងបុរសម្នាក់ទៀតមកពី Pardi។ នយោជកស្រីមានមុខរបរជាអ្នកផាត់មុខនិងជាចៅកែហាងកែ

សម្ភស្សជាច្រើនកន្លែង។ ចំណែកនយោជកប្រុសមិនមានការងារឬមុខរបរនោះទេ ប៉ុន្តែជួយប្រពន្ធរបស់លោកក្នុងការធ្វើអាជីវកម្ម។

និយោជករបស់ Murni ឧស្សាហ៍វាយធ្វើបាបរូបនាងជាមួយរបស់របរផ្សេងៗលើរាងកាយនាង ចាក់ទឹកក្តៅលើនាង និងដុតនាងដោយឆ្នាំអ៊ុតផងដែរ។ ពួកគេបានគំរាមនាងថាបើមិនស្តាប់បង្គាប់និងមានទង្វើប្រឆាំងតវ៉ាណាមួយ នោះពួកគេនឹងធ្វើបាបកាន់តែធ្ងន់ធ្ងរជាងនេះថែមទៀត។ ប៉ុន្មានឆ្នាំមកនេះគ្រួសាររបស់នាង Murni បានមកលេងនាង ប៉ុន្តែនិយោជករបស់នាងមិនដែលឱ្យពួកគេបានជួបនាងទេ ហើយថែមទាំងប្រាប់ទៅពួកគេថានាងសុខសប្បាយ ឬនាងកំពុងតែធ្វើការនៅកន្លែងផ្សេងជាមួយសមាជិកគ្រួសាររបស់ពួក។

ថ្ងៃមួយថៅកែស្រីនោះ បានចោទប្រកាន់នាង Murni ថានាងមានចំណង់អារម្មណ៍លើប្តីរបស់អ្នកស្រី។ នាងបានដាក់ទណ្ឌកម្ម Murni ដោយសម្រាតសម្លៀកបំពាក់របស់នាងហើយវាយដំទ្វារមាសរបស់នាងដោយប្រើម្ទេសនិងរបស់វាយផ្សេងៗ។ មិនត្រឹមតែប៉ុណ្ណោះទេ ថៅកែស្រីកំណាចនោះបានបង្ខំឲ្យបុរសធ្វើការតាមផ្ទះពីរនាក់ទៀតរំលោភនាងផងដែរ។ អ្វីដែលនឹកស្មានមិនដល់ទៀតនោះគឺថៅកែស្រីបានបង្ខំឲ្យនាងបរិភោគលាមកសត្វឆ្មានៅក្នុងផ្ទះទៀតផង ដែលជាលទ្ធផលក្រោយមកនាង Murni បានកើតជំងឺរបេងដោយសារការឆ្លងមេរោគ។

## សកម្មភាពប្រឆាំងនឹងអំពើរំលោភបំពាន

នៅឆ្នាំ ២០១៦ នៅពេលដែល Murni មានអាយុ ២១ឆ្នាំ ថៅកែស្រីរបស់នាងបានយកអំបោសវាយធ្វើឲ្យមាត់របស់នាងរងរបួសយ៉ាងធ្ងន់ធ្ងរ។ នាង Murni យល់ឃើញថានាងមិនអាចទ្រាំទ្រនឹងទង្វើហិង្សានេះបានទៀតទេ ព្រោះនេះជារឿងហួសហេតុពេកចំពោះមនុស្សជាតិ។ នាងបានសម្រេចចិត្តលួចរត់គេចចេញពីកន្លែងធ្វើការរបស់នាង។ នាងបានឡើងលើខ្សែកាបទូរទស្សន៍ហើយរត់ទៅប៉ុស្តិ៍ប៉ូលិសសង្កាត់ឲ្យជួយ។ យោងតាមរបាយការណ៍របស់ប៉ូលិសបានឲ្យដឹងថានាងខ្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ ហើយមានទំងន់ត្រឹមតែ ២៥ គីឡូក្រាមប៉ុណ្ណោះ។ មន្ត្រីប៉ូលិសម្នាក់បាននាំនាងទៅមន្ទីពេទ្យប៉ូលិសមួយកន្លែងនៃទីក្រុងចាកាតាខាងកើត និងបានធ្វើការទាក់ទងឪពុកម្តាយរបស់នាងនៅតំបន់ Bogor និងបានទាក់ទងជាមួយ JALA PRT និងវិទ្យាស្ថានជំនួយផ្នែកច្បាប់ស្ត្រី (IPH APIK) នៅចាកាតាផងដែរ។

## យុទ្ធសាស្ត្ររបស់ DWO និងវិធានការអនុវត្ត

ដោយមានការចូលរួមគ្នាជាមួយវិទ្យាស្ថានជំនួយផ្នែកច្បាប់ស្ត្រី JALA PRT បានចាប់ផ្តើមយុទ្ធនាការតស៊ូមតិដើម្បីស្វែងរកយុត្តិធម៌ជូនចំពោះ Murni។ ពួកគេបានធ្វើសន្និសីទកាសែត ផ្តល់ជំនួយផ្នែកច្បាប់ និងតាមដានករណីនេះយ៉ាងជិតដល់បំផុត។ ជាលទ្ធផល ថៅកែរបស់ Murni ត្រូវបាននាំខ្លួនទៅតុលាការនៅខែតុលា ឆ្នាំ ២០១៦។ ពួកគេត្រូវបានរកឃើញថាមានទោស ហើយត្រូវបានផ្តន្ទាទោសដាក់ពន្ធនាគាររយៈពេល ៩ ឆ្នាំ។ ជ័យជំនះលើករណីរបស់ Murni នេះបានកត់សម្គាល់ជាប្រវត្តិសាស្រដ៏សំខាន់មួយនៅក្នុងការប្រយុទ្ធប្រឆាំងដើម្បីការពារស្ត្រីអ្នកធ្វើការតាមផ្ទះនៅក្នុងប្រទេសឥណ្ឌូនេស៊ី។

អ្នកស្រី Lita បានរៀបចំឲ្យនាង Murni រស់នៅក្រោមដំបូលរបស់ JALA PRT។ មន្ត្រីប៉ូលិសបានស្វែងទីកន្លែងឲ្យអ្នកធ្វើការតាមផ្ទះចំនួន ៣ នាក់ផ្សេងទៀតដែលត្រូវបាននយោជកដូចគ្នានោះរំលោភបំពានក្នុងគ្រួសារមួយខាងលើ អាចស្នាក់នៅក្នុងទីតាំងដែលមានការគ្រប់គ្រងដោយរដ្ឋាភិបាល។ ពេលខ្លះឪពុកម្តាយរបស់ Murni បានមកស្នាក់នៅជាមួយនាង Murni នៅទីជំរករបស់ JALA PRT នោះ។ បំណងប្រាថ្នាមួយដ៏មុតមាំរបស់ Murni គឺចង់បន្តការសិក្សានៅថ្នាក់វិទ្យាល័យរបស់នាងក្នុងនាមជាសិស្សពេញវ័យ។ មហិច្ឆិតារបស់នាងគឺចង់ក្លាយជាគ្រូបង្ហាត់បង្រៀនម៉ាស្សា។ បំណងប្រាថ្នារបស់នាងត្រូវបានក្លាយជាការពិតនៅពេលនាងបញ្ចប់ការ

 សិក្សានៅថ្នាក់វិទ្យាល័យរបស់នាងនៅក្នុងសាលារបស់ JALA PRT ដែលការបង្រៀននោះត្រូវបានផ្តល់ជូននិងរៀបចំដោយក្រសួងអប់រំឥណ្ឌូនេស៊ី។

## ឧបសគ្គប្រឈមនិងផ្លូវឆ្ពោះទៅមុខ

អំពើហិង្សាកើតឡើងលើស្ត្រីនៅតែកើតមានជាទូទៅនៅក្នុងប្រទេសឥណ្ឌូនេស៊ី។ ក្រមព្រហ្មទណ្ឌ ចែងអំពីការហាមការរំលោភលើរាងកាយលើមនុស្សគ្រប់រូប។ នៅឆ្នាំ ២០០៤ ប្រទេសឥណ្ឌូនេស៊ីបានអនុម័តច្បាប់ដើម្បីលុបបំបាត់អំពើហិង្សាក្នុងគ្រួសារ (ច្បាប់លេខ ២៣ ឆ្នាំ២០០៤) ។ ច្បាប់នេះបានដាក់បញ្ចូលអ្នកធ្វើការតាមផ្ទះដែលរស់នៅជាមួយនយោជកនៅក្នុងនិយមន័យផ្លូវច្បាប់ថាជាគ្រួសារតែមួយ។ ដូច្នេះ ពួកគេត្រូវបានការពារដោយច្បាប់ប្រឆាំងនឹងអំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និងផ្នែកសេដ្ឋកិច្ចនៅក្នុងគ្រួសារនិយោជក។ ប៉ុន្តែ ឧបសគ្គជាច្រើននៅតែមានក្នុងការអនុវត្តច្បាប់នេះប្រកបដោយប្រសិទ្ធភាព ដូចជាការមិនបានអប់រំសហគមន៍និងស្ថាប័ននានាឱ្យបានយល់ដឹងបន្ថែមអំពីអំពើហិង្សាក្នុងគ្រួសារជាដើម។

JALA PRT និង Komnas Perempuan (គណៈកម្មការជាតិប្រឆាំងអំពើហិង្សាលើស្ត្រី) និងអង្គការសមភាពយេនឌ័រជាច្រើនកំពុងបន្តយុទ្ធនាការលុបបំបាត់អំពើហិង្សាលើស្ត្រី។ ចាប់តាំងពីឆ្នាំ ២០០៤ មក JALA PRT បានក្លាយជាអ្នកឈានមុខគេក្នុងការអភិវឌ្ឍនិងតស៊ូមតិសម្រាប់ការអនុម័តច្បាប់ Perlindungan Pekerja Rumah Tangga (PPRT ឬច្បាប់ការការពារអ្នកធ្វើការតាមផ្ទះ)។ ដំណើរការមានភាពយឺតយ៉ាវរហូតមកដល់បច្ចុប្បន្នដោយសារកង្វះឆន្ទៈនយោបាយក្នុងចំណោមសមាជិកសភាតំណាងប្រជាជនឥណ្ឌូនេស៊ី (Indonesian House of Representatives)។ ទោះយ៉ាងណានៅដើមឆ្នាំ ២០២០ សភានេះបានចាប់ពិចារណាលើសេចក្តីព្រាងច្បាប់នេះដើម្បីការពារអ្នកធ្វើការតាមផ្ទះ។

## អ្នកស្រី ស្រីមុំ និង ADW, រាជធានីភ្នំពេញ ប្រទេសកម្ពុជា

**បរិយាយដោយ អ្នកស្រី យឹម សុធី**

**ប្រធានសមាគមអ្នកធ្វើការតាមផ្ទះ (ADW)**





រូបភាព: ADW

**អំពើរំលោភបំពាន**

អ្នកស្រី ស្រី មុំ (មិនមែនឈ្មោះពិត) អាយុ ២៩ ឆ្នាំជាក្មេងកំព្រាដែលត្រូវរស់នៅនិងចិញ្ចឹមបីបាច់ដោយម្ដាយចិញ្ចឹមម្នាក់។ ក្នុងឆ្នាំ ២០០៦ នៅពេលនាងមានអាយុ ១៦ ឆ្នាំនាងបានចាប់ផ្ដើមធ្វើការជាអ្នកធ្វើការតាមផ្ទះដោយរស់នៅជាមួយគ្រួសារនយោជកមួយនៅទីក្រុងភ្នំពេញ ប្រទេសកម្ពុជា ដោយរកចំណូលបាន ១២០ដុល្លារអាមេរិកក្នុងមួយខែ។ បន្ទាប់ពីធ្វើការអស់រយៈពេល ៣ឆ្នាំ ឪពុករបស់គ្រួសារនយោជករបស់នាងបានឲ្យនាងរៀបការជាមួយកូនប្រុសពៅរបស់គាត់។ ដោយសារភាពក្រីក្រនិងការទទួលខុសត្រូវក្នុងការមើលថែម្ដាយដែលមានជំងឺផង នាងបានយល់ព្រមរៀបការ។ បន្ទាប់មកនាងចាប់ផ្ដើមធ្វើការជាអ្នករៀបចំតុបតែងពិធីមង្គលការ និងពិធីបុណ្យនានា ដោយទទួលបានប្រាក់ចាយវាយតិចតួចពីឪពុកក្មេកដោយសម្ងាត់។ នាងសម្រាលបានកូនប្រុសពីរនាក់។

នៅឆ្នាំ២០១៥ ឪពុកក្មេករបស់អ្នកស្រីបានទទួលមរណភាព។ បន្ទាប់មក ប្ដីរបស់អ្នកស្រីចាប់ផ្ដើមសុំលុយពីនាង។ អ្នកស្រីបានបដិសេធថាអ្នកស្រីមិនដែលបានទទួលប្រាក់ពីឪពុកក្មេកនោះពីមុនមកទេ។ ការបដិសេធរបស់នាងបានជំរុញឲ្យប្ដីនិងម្ដាយក្មេករបស់នាងចាប់ផ្ដើមរំលោភបំពានលើរាងកាយរបស់នាង។ ពួកគេបានទាញសក់របស់នាងអូសនាងចុះជណ្ដើរ។ ជាញឹកញាប់ក្បាលរបស់នាងត្រូវបានគេបប្រឡាក់ឈាមនិងមានស្នាមជាំពេញដៃនិងជើងដោយសារតែការវាយធ្វើបាប។

## សកម្មភាពប្រឆាំងនឹងអំពើរំលោភបំពាន

ស្រីមុំ បានរាយការណ៍រឿងនេះប្រាប់អ្នកជិតខាងដែលជាមន្ត្រីប៉ូលិសអំពីការរំលោភបំពាននេះ។ តាមយោបល់អ្នកជិតខាងរូបនោះ នាងបានដាក់ពាក្យបណ្តឹងទៅកាន់ប៉ុស្តិ៍ប៉ូលិសក្នុងតំបន់។ ប៉ុន្តែមន្ត្រីប៉ូលិសមិនបានចាត់វិធានការអ្វីចំពោះម្តាយក្មេករបស់នាងទេ ដោយប្រហែលមកពីឥទ្ធិពលរបស់ម្តាយក្មេកនាងនៅក្នុងសហគមន៍នោះ។ នៅពេលដែលអ្នករត់រ៉ឺម៉កកង់បី បានជូនស្រីមុំទៅធ្វើការ ហើយបានឮដំណឹងអំពីអំពើហិង្សានោះ គាត់បានណែនាំស្រីមុំទៅជួបអ្នកស្រី យឹម សុធី ប្រធានបណ្តាញអ្នកធ្វើការតាមផ្ទះកម្ពុជា (CDWN)។ ក្រោយមក ការផ្លាស់ប្តូរបានចាប់ផ្តើមកើតឡើង។






## យុទ្ធសាស្ត្ររបស់ DWO និងវិធានការអនុវត្ត

ដោយមានការចូលរួមជួយដោយ ហៃ សុម៉ាលី លេខាធិការ CDWN អ្នកស្រី សុធី បាននាំស្រីមុំទៅសម្ព័ន្ធខ្មែរជំរឿន និងការពារសិទ្ធមនុស្ស លីកាដូ (Cambodian League for the Promotion and Defense of Human Rights ) ដើម្បីសុំការជួយពីពួកគេ។ អង្គការលីកាដូ បានរៀបចំសំណុំរឿងរបស់នាងនិងបានជួយនាងក្នុងការដាក់ពាក្យបណ្ដឹងទៅតុលាការ។ អ្នកស្រី សុធី ក៏បានជួយស្រីមុំក្នុងការទាក់ទងគណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់ (Commune Committee for Women and Children) តាមរយៈទូរស័ព្ទតែគ្មាននរណាម្នាក់លើកទូរស័ព្ទនោះទេ។

មិនយូរប៉ុន្មាន ប្ដីរបស់ស្រីមុំបានដាក់ពាក្យសុំលែងលះ។ ស្រីមុំមានភាពពិបាកខ្លាំងក្នុងការចូលរួមស្ដាប់សវនាការរបស់តុលាការ៖ មានម្ដងនោះ នាងបានដួលសន្លប់នៅក្នុងតុលាការ ហើយជារឿយៗនាងទទួលរងសម្ពាធផ្លូវចិត្តយ៉ាងខ្លាំងនៅពេលត្រូវបានគេរំលឹកឡើងវិញនូវព្រឹត្តិការណ៍នៃការរំលោភបំពានដែលបានទទួលរងពីក្រុមគ្រួសារប្ដីរបស់នាង។ នៅទីបញ្ចប់ ដោយសារប្ដីនាងមានការប្រើប្រាស់គ្រឿងញៀន តុលាការបានផ្ដល់សិទ្ធិក្នុងការចិញ្ចឹមបីបាច់ពេញលេញលើកូនប្រុសពីរនាក់របស់នាង។

អ្នកស្រី សុធី និង សុម៉ាលី បានជួយទំនុកបម្រុងហិរញ្ញវត្ថុផ្ទាល់ខ្លួនដល់ស្រីមុំ រហូតដល់ពួកគេឈប់ធ្វើការនៅ CDWN ក្នុងឆ្នាំ២០១៦ និងបង្កើតសមាគមអ្នកធ្វើការតាមផ្ទះ (ADW) នៅកម្ពុជា។ សមាគម ADW បានជួយទទួលខុសត្រូវលើស្រីមុំ និងបានជួយនាងការងារជាអ្នកធ្វើការតាមផ្ទះ។ ទោះជាយ៉ាងណាក៏ដោយ នៅទីបំផុតនាងបានបាត់បង់សមត្ថភាពក្នុងការបំពេញការងារតាមផ្ទះដោយសារតែបញ្ហាផ្លូវចិត្តធ្ងន់ធ្ងរ។ នាងបានមករស់នៅជាមួយម្ដាយរបស់នាងវិញហើយបានធ្វើការជាអ្នករើសសំរាមដោយរកប្រាក់បានគ្រាន់ដើម្បីទិញម្ហូបអាហារផ្គត់ផ្គង់គ្រួសារ។

រយៈពេលបួនឆ្នាំក្រោយការលែងលះ ស្រីមុំនៅតែទទួលរងការឈឺចាប់ដោយសារការរំលោភបំពានកន្លងមកដែលនាងបានឆ្លងកាត់ ហើយពឹងផ្អែកការព្យាបាលជំងឺនេះ។ ដោយសារភាពក្រីក្រនិងភាពលំបាកផ្នែកហិរញ្ញវត្ថុក្នុងការចំណាយលើការព្យាបាលរបស់នាង (៣ ដុល្លារសម្រាប់ការពិគ្រោះយោបល់ប្រចាំខែនិងការបង់ប្រាក់បន្ថែមសម្រាប់ថ្នាំព្យាបាល) នាងបានបោះបង់ចោលទំនួលខុសត្រូវលើការចិញ្ចឹមកូនប្រុសរបស់នាង។ ក្រោយមកម្ដាយរបស់នាងបានទទួលមរណភាពនៅដើមឆ្នាំ ២០១៩ ហើយនាងកាន់តែជួបការពិបាកខ្លាំងឡើងក្នុងការរស់នៅតែម្នាក់ឯងតាំងពីពេលនោះមក។

បច្ចុប្បន្ននាងមានការងារនៅភោជនីយដ្ឋានមួយដែលទទួលបានប្រាក់ឈ្នួលប្រចាំខែចំនួន ១២០ ដុល្លារដោយគ្មានថ្ងៃឈប់សម្រាកហើយ ៥០ ភាគរយនៃប្រាក់ឈ្នួលប្រចាំខែរបស់នាងត្រូវបានប្រើប្រាស់ចាយវាយលើការបង់ថ្លៃឈ្នួលផ្ទះ។

### ឧបសគ្គប្រឈម

នៅប្រទេសកម្ពុជា ច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងការការពារជនរងគ្រោះ (Prevention of Domestic Violence and Protection of Victims) ត្រូវបានអនុម័តក្នុងឆ្នាំ ២០០៥ ប៉ុន្តែច្បាប់នេះមិនអាចត្រូវបានអនុវត្តដោយមេឃុំឬមន្ត្រីប៉ូលិសនោះទេ ពីព្រោះបទប្បញ្ញត្តិមិនត្រូវបានអនុម័តនិងមិនមានពេលវេលាជាក់លាក់សម្រាប់នីតិវិធីបណ្តឹងឡើយ។ ដូច្នេះ នៅពេលជនរងគ្រោះដែលជួបអំពើហិង្សា ទៅរកដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍ប៉ូលិសគឺពួកគេត្រូវបានគេណែនាំឲ្យធ្វើបណ្តឹងព្រហ្មទណ្ឌ ហើយនីតិវិធីស្ថិតក្រោមក្រមព្រហ្មទណ្ឌត្រូវបានអនុវត្តលើរឿងបណ្តឹងនេះ។ ខណៈដែលក្រមព្រហ្មទណ្ឌហាមឃាត់ការរំលោភបំពានលើរាងកាយវាជាការលំបាកសម្រាប់ជនរងគ្រោះនៃអំពើហិង្សាក្នុងគ្រួសារក្នុងការទទួលបានយុត្តិធម៌។ ស្រីមុំបានដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌកាលពីឆ្នាំ ២០១៥ ប៉ុន្តែនាងមិនដែលត្រូវបានតុលាការកោះហៅឲ្យមកផ្តល់សក្ខីកម្មនៅតុលាការទេហើយរឿងក្តីរបស់នាងនៅតែស្ថិតក្នុងការរង់ចាំមកទល់ពេលនេះ។ សំណុំរឿងរបស់នាងត្រូវបានផ្ទេរពីចៅក្រមម្នាក់ទៅចៅក្រមម្នាក់ទៀតជាច្រើនដង ហើយនៅឆ្នាំ ២០១៩ មេធាវីការពារក្តីត្រូវបានគេផ្តល់ដំណឹងថាឯកសាររបស់នាងបានបាត់។ នេះមានការដាក់ការសង្ស័យថាប៉ូលិសនិងអាជ្ញាធរត្រូវបានទទួលសំណូកពីសំណាក់ក្រុមគ្រួសារប្តីរបស់ជនរងគ្រោះ។

## អ្នកស្រី Riza R. Amahan និង UNITED ទីក្រុងម៉ានីល ប្រទេសហ្វីលីពីន

**បរិយាយដោយ** Himaya Montenegro
*សហព័ន្ធរួបរួមអ្នកធ្វើការតាមផ្ទះ (UNITED)*




ប្រទេសហ្វីលីពីន៖ កម្មវិធីកម្មវិធីជួបជុំបែបកម្សាន្ត UNITED សម្រាប់សមាជិកអ្នកធ្វើការតាមផ្ទះ [រូបភាព: Del Bañares Via D. Montenegro]

### អំពើរំលោភបំពាន

អ្នកនាង Riza R. Amahan មកពីទីក្រុង Kidapawan ខេត្ត Cotabato ក្នុងប្រទេសហ្វីលីពីន មានអាយុ ២៣ ឆ្នាំនៅពេលដែលនាងត្រូវបានជ្រើសរើសដោយទីភ្នាក់ងារស្វែងរកការងារមួយនៅទីក្រុងម៉ានីល រដ្ឋធានីរបស់ប្រទេសនេះដើម្បីធ្វើការជាអ្នកធ្វើការតាមផ្ទះ។ បន្ទាប់ពីបានបំពេញការងារបានរយៈពេលមួយខែ និយោជករបស់នាងបានបញ្ជូននាងត្រលប់ទៅឲ្យភ្នាក់ងារនោះវិញ ដោយសារនាងធ្លាក់ខ្លួនឈឺនិងកំពុងលេបថ្នាំ ហើយនយោជកនោះទាមទារអ្នកធ្វើការថ្មីជំនួសនាងវិញ។ Riza មិនបានដែរប្រាប់ពីជំងឺនោះទេពីព្រោះនិយោជករបស់នាងបានផ្តល់ប្រាក់ខែខ្ពស់ជាងប្រាក់ឈ្នួលអប្បបរមា ហើយនាងថែមទាងត្រូវបានគេផ្តល់កន្លែងស្នាក់នៅសមរម្យនិងមានអាហារគ្រប់គ្រាន់ទៀតផង។

បន្ទាប់ពីបាត់បង់ការងារនាង Riza R. Amahan ត្រូវបានទីភ្នាក់ងារការងារនោះឃុំខ្លួនអស់រយៈពេលជាងមួយសប្តាហ៍។ លោក Daniel ម្ចាស់ទីភ្នាក់ងារនោះ តែងតែជេរប្រមាថនាងដោយប្រើពាក្យជេរប្រមាថ អសុរសហើយបានចោទប្រកាន់នាងថាខ្ជិលច្រអូស អាស និងរកស៊ីលក់ខ្លួន។ នាងមិនត្រូវបានគេផ្តល់គ្រែឲ្យសម្រាកត្រឹមត្រូវទេ ដោយត្រូវដេកនៅលើបេតុងដោយគ្មានខ្នើយឬភួយ។ នៅពេលនាងមិនមានលទ្ធភាពបង់ថ្លៃការប្រើប្រាស់អគ្គិសនីដល់ភ្នាក់ងារនេះ នាងត្រូវបានដាក់ពិន័យដោយកាត់ផ្តាច់ពីការទំនាក់ទំនងជាមួយមិត្តភក្តិនិងសាច់ញាតិ។ អ្វីដែលអាក្រក់បំផុតនោះគឺនាងមិនត្រូវបានគេផ្តល់អាហារនិងទឹកឲ្យបរិភោគគ្រប់គ្រាន់ហើយនាងតែងតែឃ្លានគ្រប់ពេល។

## យុទ្ធសាស្ត្ររបស់ DWO និងវិធានការអនុវត្ត

អ្នកនាង Riza បានប្រាប់សាច់ញាតិរបស់នាងឈ្មោះ Maricel Hermosa អំពីការប្រព្រឹត្តទង្វើអមនុស្សធម៌ពីទីភ្នាក់ងារស្វែងរកការងារខាងលើ ហើយនាងចង់រត់គេចពីទីនោះ។ នាង និង Maricel ដែលជាសមាជិកសហព័ន្ធរួបរួមអ្នកធ្វើការតាមផ្ទះនៅប្រទេសហ្វីលីពីន (UNITED) បានបង្កើតផែនការស្វែងរកការសង្គ្រោះឲ្យនាងរួចផុតពីកន្លែងនោះ។

ផែនការសង្គ្រោះនេះត្រូវបានរៀបចំដោយមានការចូលរួមពីសំណាក់នាយកដ្ឋានពលកម្មនិងការងារ (Department of Labor and Employment) និងការិយាល័យស៊ើបអង្កេតជាតិ (National Bureau of Investigation)។ នៅពេលភ្នាក់ងាររដ្ឋាភិបាលចូលទៅដល់លើកដំបូង ម្ចាស់ទីភ្នាក់ងារការងារនោះបានបដិសេធពាក្យបណ្តឹងរបស់ Riza ហើយទាមទារឱ្យនាងបង់ថ្លៃ PHP ៦,០០០,០០ (ប្រហែល ១១៤ ដុល្លារអាមេរិក) សម្រាប់ថ្លៃឈ្នួលស្វែងរកការងារដោយទីភ្នាក់ងារនេះថែមទៀតផង មុនពេលនាងត្រូវបានអនុញ្ញាតិឲ្យចាកចេញ។ ទោះជាយ៉ាងណាក៏ដោយ បន្ទាប់ពីការពិភាក្សាអស់រយៈពេលយ៉ាងយូរទើបទីបំផុតលោក Daniel និងភរិយាបានយល់ព្រមអនុញ្ញាតឱ្យ Riza ទៅចូលជាមួយ United។ បុគ្គលិករបស់ DOLE បានលើកទឹកចិត្ត UNITED ឱ្យជួយ Riza ដាក់ពាក្យបណ្តឹងប្រឆាំងនឹងទីភ្នាក់ងារការងារខាងលើនោះប៉ុន្តែនាងបានបដិសេធមិនធ្វើដូច្នេះទេដោយសារថាលោក Daniel ម្ចាស់ទីភ្នាក់ងារងនោះ ជាអតីតបុគ្គលិករដ្ឋាភិបាលចូលនិវត្តន៍ម្នាក់នៃសង្កាត់ Barangay ។ នាងមានភាពតក់ស្លុត មិនព្រមដាក់ពាក្យបណ្តឹង គ្រាន់តែចង់ត្រឡប់មកស្រុកកំណើតវិញតែប៉ុណ្ណោះ។



## វឌ្ឍនភាពនិងឧបសគ្គប្រឈម

ក្នុងឆ្នាំ២០១២ ហ្វីលីពីនបានក្លាយជាប្រទេសដំបូងគេនៅទ្វីបអាស៊ីដែលបានចុះហត្ថលេខានិងផ្តល់សច្ចាប័នលើអនុសញ្ញា ILO លេខ១៨៩ ស្តីពីការងារសមរម្យសម្រាប់អ្នកធ្វើការតាមផ្ទះ។ មួយឆ្នាំក្រោយមកគឺក្នុងឆ្នាំ ២០១៣ ប្រទេសហ្វីលីពីនបានអនុម័តច្បាប់ស្តីពីអ្នកធ្វើការតាមផ្ទះ (Batas Kasambahay ឬគោលការណ៍បង្កើតច្បាប់សម្រាប់ការពារនិងសុខុមាលភាពរបស់អ្នកធ្វើការតាមផ្ទះ - Act Instituting Policies for the Protection and Welfare of Domestic Workers) ។ ប្រធានាធិបតី Benigno S. Aquino បានចុះហត្ថលេខាលើច្បាប់នេះជាច្បាប់នៅដើមឆ្នាំ ២០១៣ ហើយវាបានចូលជាធរមាននៅពាក់កណ្តាលឆ្នាំ ២០១៣ បន្ទាប់ពីការប្រកាសឱ្យប្រើវិធាននិងបទបញ្ញត្តិស្តីពីការអនុវត្ត IRR (Implementing Rules and Regulations) ។ ចាប់តាំងពីពេលនោះមក ច្បាប់ទទួលស្គាល់ការងារផ្ទះឬក្នុងគ្រួសារជាវិស័យផ្លូវការនៃពលកម្មនៅប្រទេសហ្វីលីពីន។ ច្បាប់នេះផ្តល់ការការពារការងារនិងសង្គមដល់អ្នកធ្វើការតាមផ្ទះនៅក្នុងប្រទេសនិងការពារពួកគេពីការរំលោភបំពាននៅក្នុងគ្រួសារនិយោជក។

អនុលោមតាមច្បាប់ស្តីអំពីអ្នកធ្វើការតាមផ្ទះ(Domestic Workers Act) ទីភ្នាក់ងារផ្តល់សេវាស្វែងរកការងារត្រូវតែធានាថាសិទ្ធិរបស់អ្នកធ្វើការតាមផ្ទះត្រូវបានការពារ។ យោងតាមទស្សនៈរបស់ UNITED DOLE គួរតែធ្វើការស៊ើបអង្កេតបន្ថែមទៀតទោះបីជនរងគ្រោះមិនអាចដាក់ពាក្យបណ្តឹងជាផ្លូវការក៏ដោយ។ តែទោះជាយ៉ាងណាក៏ដោយ ដោយសារតែ Riza មិនបានដាក់ពាក្យបណ្តឹងជាផ្លូវការ ដូចនេះជនល្មើសមិនត្រូវបានដាក់ទោសនោះឡើយ លុះត្រាតែ United យកករណីរបស់នាងក្នុងយុទ្ធនាការលើកកម្ពស់សកម្មភាពនិងការយល់ដឹងជាសាធារណៈ។

នៅកំរិតថ្នាក់ស្រុក Barangay, DOLE និងនាយកដ្ឋានសុខុមាលភាពសង្គមកិច្ចនិងការអភិវឌ្ឍ (DSWD) ហើយនិងប៉ូលិសត្រូវមានទំនួលខុសត្រូវចំពោះការជួយសង្គ្រោះនិងស្តារនីតិសម្បទារបស់អ្នកធ្វើការតាមផ្ទះដែលទទួលរងការរំលោភបំពាន។ ប៉ុន្តែ នៅក្នុងការអនុវត្តជាក់ស្តែងដែលនិយោជកនិងទីភ្នាក់ងារផ្តល់សេវាការងារឯកជនភាគច្រើនមានទំនាក់ទំនងជិតស្និទ្ធជាមួយមន្ត្រីនិងអាជ្ញាធរស្រុក Barangay ហើយវាពិតជាមានភាពលំបាកខ្លាំងណាស់ក្នុងការអនុវត្តច្បាប់និងការពារអ្នកធ្វើការតាមផ្ទះពីការរំលោភបំពានទាំងឡាយ។

ហ្វីលីពីនជាប្រទេសតែមួយគត់នៅអាស៊ីដែលបានអនុម័តច្បាប់ជាតិជាក់លាក់ស្តីពីការងារតាមផ្ទះ។ ទោះយ៉ាងណាតាមបទពិសោធរបស់ UNITED អ្នកធ្វើការតាមផ្ទះនៅប្រទេសហ្វីលីពីននៅតែងាយរងគ្រោះទោះបីជាមានច្បាប់នេះក៏ដោយ ហើយមូលហេតុចំបងគឺ៖

- កន្លែងធ្វើការរបស់អ្នកធ្វើការតាមផ្ទះគឺជាផ្ទះឯកជន ហើយយន្តការត្រួតពិនិត្យស្ថានភាពជាក់ស្តែងនៅកន្លែងធ្វើការនៅមានភាពអន់ខ្សោយ។
- នាយកដ្ឋានពលកម្មនិងការងារ (DOLE) នៅកម្រិតស្រុក Baragya មិនមានថវិកាគ្រប់គ្រាន់ទេ ហេតុដូច្នេះហើយបានជាមានបញ្ហាខ្វះធនធានមនុស្សនិងហិរញ្ញវត្ថុដើម្បីបំពេញភារកិច្ចរបស់ពួកគេស្របតាមគោលការណ៍ច្បាប់។
- ជនរងគ្រោះភាគច្រើនមានការគោរពស្រលាញ់ខ្លួនឯងទាបនិងមកពីក្រុមគ្រួសារដែលមានឋានៈតូចទាបនៅក្នុងសង្គម។ ប្រសិនបើគ្មានជំនួយពីសហជីព សមាគម និងរដ្ឋាភិបាលទេ នោះមានការពិបាកខ្លាំងណាស់សម្រាប់ពួកគេក្នុងការស្វែងរកយុត្តិធម៌។

### អ្នកនាង **Sunita Ekka** និង **NDWM,** ទីក្រុង **Patna,** ប្រទេសឥណ្ឌា

***បរិយាយដោយ** Leema Rose George **អ្នកធ្វើការផ្នែកសង្គម***
***ចលនាអ្នកធ្វើការតាមផ្ទះជាតិ** (NDWM)*







អ្នកនាង Sunita ត្រូវទទួលរងការបៀតបៀននិងអំពើហិង្សា ប៉ុន្តែមិនដែលចុះចាញ់នោះឡើយ។ អ្នកនាង Sunita ត្រូវទទួលបានពានរង្វាន់ Cimage សម្រាប់អ្នកជំរុញឲ្យមានការផ្លាស់ប្តូរក្នុងសង្គម នៅថ្ងៃទី០៨ ខែមីនា ឆ្នាំ ២០១៦។

## អំពើរំលោភបំពាន

អ្នកនាង Sunita Ekka (មិនមែនឈ្មោះពិត) មកពីកុលសម្ព័ន្ធ Uraon នៅក្នុងតំបន់ Jharkhand ។ កាលពីខែមីនាឆ្នាំ ២០១៤ នៅពេលនាងមានអាយុ ១៦ឆ្នាំ អ្នកជិតខាងម្នាក់មកពីភូមិកំណើតរបស់នាងបាននាំនាងទៅទីក្រុង Patna នៃរដ្ឋ Bihar ក្នុងប្រទេសឥណ្ឌា ដើម្បីធ្វើការជាអ្នកធ្វើការតាមផ្ទះឲ្យគ្រួសារមួយ។ នាងមិនដែលទទួលបានការទូទាត់ប្រាក់ឈ្នួលសម្រាប់ការងាររបស់នាងទេ។ រាល់ពេលដែលថៅកែស្រីចេញទៅឆ្ងាយពីការងារ និយោជកប្រុសជាប្តីតែងតែធ្វើបាបនិងបៀតបៀនផ្លូវភេទលើរូបនាង។ រយៈពេល ៤ ខែក្រោយមកថៅកែប្រុសបានចាប់រំលោភនាងម្តងហើយម្តងទៀតរយៈពេល៣ថ្ងៃ។ នៅពេលនាងវាយតទល់វិញ នាងត្រូវថៅកែប្រុសរូបនោះគំរាមសម្លាប់។ នាងបានរាយការណ៍រឿងនេះទៅប្រពន្ធនិយោជករូបនោះ ប៉ុន្តែនយោជកជាប្តីប្រពន្ធនោះបានវាយដំនាងថែមទៀតផង។

## យុទ្ធសាស្ត្ររបស់ DWO និងវិធានការអនុវត្ត

ថ្ងៃមួយនៅពេលនាងបានចេញទៅយកកូននយោជកពីសាលារៀន នាងបានជួប Leena ដែលជាមេដឹកនាំក្រុមអ្នកធ្វើការនៅតាមផ្ទះ និងបានជជែកលេងជាមួយនាងជាធម្មតា។ បន្ទាប់មកនាង Sunita ចាប់ផ្តើមយំហើយបានប្រាប់ Leena ពីរឿងរ៉ាវដែលកំពុងកើតឡើងលើរូបនាង។ ក្រោយមក Leena បានបញ្ចុះបញ្ចូល Sunita ឲ្យសុំដាក់ពាក្យលាឈប់ពីការងាររបស់នាង។ ចលនាអ្នកធ្វើការតាមផ្ទះជាតិ (NDWM) បាននាំនាងទៅកាន់

ការិយាល័យនិងទីជំរកនៅក្នុងចលនាអ្នកធ្វើការតាមផ្ទះជាតិ (NDWM) នោះ។ នៅថ្ងៃបន្ទាប់ NDWM បានជួយនាងរៀបចំរឿងក្ដីជាមួយប៉ូលិសប្ដឹងផ្ដល់ប្ដីប្រពន្ធនិយោជកនិងអ្នកជិតខាងដែលបាននាំនាងទៅទីក្រុង Patna ដើម្បីធ្វើការជាមួយគ្រួសារនយោជកនោះ។ នាង Sunita ត្រូវបានគេឲ្យនៅសម្រាកនៅប៉ុស្តិ៍ប៉ូលិសរយៈពេលពីរថ្ងៃនិងត្រូវបាននាំទៅពិនិត្យសុខភាព។ ទោះយ៉ាងណា របាយការណ៍វេជ្ជបណ្ឌិតបានបង្ហាញថាគ្មានអ្វីកើតឡើងលើរូបនាង ហើយនេះគេសង្ស័យថាប្រហែលជាប៉ូលិសនិងគ្រូពេទ្យនោះបានទទួលសំណូកពីភាគីនយោជកខាងលើ។ NDWM បានទាមទារឲ្យមានការពិនិត្យសុខភាពឯករាជ្យមួយផ្សេងទៀត ហើយរកឃើញថានាង Sunita ត្រូវបានគេចាប់រំលោភពិតមែន។ ទោះយ៉ាងណាក៏ដោយគ្មាននរណាម្នាក់ត្រូវបានចាប់ខ្លួនទេ ពីព្រោះប៉ូលិសមូលដ្ឋានត្រូវបានគេសូកប៉ាន់បំបិទមាត់។

ចលនាអ្នកធ្វើការតាមផ្ទះជាតិ (NDWM) បានជួយនាង Sunita ទាក់ទងមន្ត្រីជាន់ខ្ពស់និងយករឿងក្តីរបស់នាងទៅដាក់ស្នើនៅអាជ្ញាធរច្បាប់រដ្ឋ (State Legal Authority) នៃរដ្ឋ Bihar ដោយយោងតាមមាត្រា ៣៧៦ ស្តីពីបទល្មើសផ្លូវភេទនៅក្នុងក្រមព្រហ្មទណ្ឌឥណ្ឌា (Indian Penal Code) ដែលមានចែងពីការផ្តន្ទាទោសនៃការរំលោភផ្លូវភេទនិងការរំលោភសេពសន្ថវៈ។ ទឹកប្រាក់ ១ សែនរូពីឥណ្ឌា (ប្រហែល ១ ៣៩២ ដុល្លារអាមេរិក) ត្រូវបានប្រគល់ទៅឲ្យ Sunita ជាសំណងពីរដ្ឋាភិបាលប៊ីហារ ក្រោមគោលការណ៍សំណងជនរងគ្រោះប៊ីហារឆ្នាំ ២០១៤ (2014 Bihar Victim Compensation Scheme)។ ទោះបីជាយ៉ាងណា រហូតមកដល់ថ្ងៃនេះនៅមិនទាន់មាននរណាម្នាក់ត្រូវបានចាប់ខ្លួនពាក់ព័ន្ធនឹងករណីហិង្សានោះឡើយ។

នាង Sunita មានភាពក្លាហានក្នុងការបន្តតស៊ូដើម្បីស្វែងរកយុត្តិធម៌ដល់ខ្លួននាង។ នាងមានសម្ពាធផ្លូវចិត្តប៉ុន្តែមិនដែលចុះចាញ់ក្នុងការស្វែងរកយុត្តិធម៌នោះទេ។ ដោយមានជំនួយពី NDWM នាង Sunita ទទួលបានការងារមួយទៀតជាអ្នកធ្វើការតាមផ្ទះនិងបានបញ្ចប់ការអប់រំស្តង់ដារទី ១២ របស់នាង។ នាងបានបន្តដំណើរជីវិតរបស់នាងទៅមុខហើយឥឡូវនេះនាងជាមេដឹកនាំអ្នកធ្វើការតាមផ្ទះដ៏រឹងមាំម្នាក់។ បន្ទាប់ពីការតស៊ូលើរឿងក្តីនេះអស់រយៈពេលជាច្រើនឆ្នាំ នៅខែមីនា ឆ្នាំ២០១៩ ទីបំផុតនាងបានទទួលដំណឹងពីនាយកដ្ឋានស៊ើបអង្កេតព្រហ្មទណ្ឌ (Criminal Investigation Department) ដោយស្នើឲ្យមានករណីនេះស្ថិតក្រោមច្បាប់ការពារកុមារពីបទល្មើសផ្លូវភេទ (Protection of Children from Sexual Offences Act) (POCSO ដែលត្រូវបានអនុម័តនៅឆ្នាំ២០១២ និងធ្វើវិសោធនកម្មនៅឆ្នាំ២០១៩)។ ប៉ុន្តែ ជាមួយនឹងការផ្លាស់ប្តូរនៅក្នុងជីវិតផ្ទាល់ខ្លួន នាងបានសម្រេចចិត្តមិនបន្តរឿងក្តីនេះទៀតទេ។ ការពន្យាពេលផ្តល់យុត្តិធម៌ ជាការបង្ខំឲ្យបោះបង់ការស្វែងរកយុត្តិធម៌ពីសំណាក់ជនរងគ្រោះ សូម្បីស្ត្រីវ័យក្មេងមានភាពរឹងមាំដូចនាង Sunita ក៏ដោយ។

## បញ្ហាប្រឈមនិងផ្លូវឆ្ពោះទៅមុខ

ក្រៅពីដំណើរការដ៏យូរនៃការស៊ើបអង្កេតរបស់ប៉ូលិសនិងតុលាការ នាង Sunita ត្រូវមកទ្រាំនឹងការធ្វើ «តេស្តម្រាមដៃពីរ» (ការធ្វើកោសល្យវិនិច្ឆ័យលើរាងកាយនិងលើទ្វារមាសរបស់នាងថែមទៀត) ពីសំណាក់អាជ្ញាធរ។ ខណៈពេលដែល Sunita កំពុងសំរាកព្យាបាលនៅ NDWM ថៅកែប្រុសរបស់នាងតែងតែមកលួចមើលនាងនៅទីនោះ ហើយរដ្ឋាភិបាលក៏មិនបានផ្តល់ការការពារសុវត្ថិភាពណាមួយដល់ជនរងគ្រោះដូចរូបនាងនោះឡើយ។ ទោះជាយ៉ាងណា នាង Sunita បានជាសះស្បើយនៅក្នុងជម្រកស្នាក់នៅ NDWM ហើយមិនបានជួបប្រទះបញ្ហាផ្សេងនៅទីនោះព្រោះតែទីជម្រក Juniors Homes របស់រដ្ឋាភិបាលនេះធ្លាប់មានប្រវត្តិជនរងគ្រោះដោយសារការរំលោភបំពានមួយចំនួនបានជួបប្រទះការបំពានផ្លូវភេទនៅទីនោះ[1]។

ចលនាអ្នកធ្វើការតាមផ្ទះជាតិ (NDWM), សមាគមស្ត្រីមានមុខរបរផ្ទាល់ខ្លួន SEWA (Self-Employed Women's Association) អង្គការសិទ្ធិស្ត្រី, អង្គការសិទ្ធិកម្មករនិងសិទ្ធិកុមារជាច្រើនទៀតនៅក្នុងប្រទេសឥណ្ឌាបានរកឃើញថាកុមារនិងស្ត្រីមកពីក្រុមជនជាតិភាគតិចនិងក្រុមអ្នកដែលមានជីវភាពលំបាកងាយនឹងរងគ្រោះ

[1] ស្វែងរក, ឧទាហរណ៍, https://www.aljazeera.com/indepth/features/tragedy-year-girls-raped-shelter-180731081743838.html និង https://www.bbc.com/news/world-asia-india-45124802 (accessed 5 January 2020).

ដោយការរំលោភផ្លូវភេទនិងឃាតកម្ម។ ពេលខ្លះភាពឃោរឃៅទាំងនេះក៏ត្រូវបានកត់ត្រានិងចែកចាយតាមប្រព័ន្ធអ៊ីនធឺណិតឬតាមវីដេអូនានា។ ការរំលោភបំពានលើរាងកាយនិងការរំលោភសេពសន្ថវៈគឺជាអំពើខុសច្បាប់ក្រោមក្រមព្រហ្មទណ្ឌឥណ្ឌា (Indian Penal Code) ប៉ុន្តែតាមការអនុវត្តជាក់ស្តែងវាជាការលំបាកសម្រាប់ជនរងគ្រោះក្នុងការកសាងសំណុំរឿងជាមួយប៉ូលិស ដោយសារតែនៅពេលដែលជនរងគ្រោះដាក់ពាក្យបណ្តឹងដោយមានជំនួយពីអង្គការគាំទ្រនានា ប៉ូលិសឬជនដៃដល់និងក្រុមគ្រួសារជនល្មើសជារឿយៗតែងតែមានការគំរាមកំហែងដល់ជនរងគ្រោះឬបង់ប្រាក់ឲ្យជនរងគ្រោះដើម្បីដកពាក្យបណ្តឹងនោះចេញ។

NDWM និងអង្គការសិទ្ធិស្ត្រីនិងកុមារនិងអង្គការសិទ្ធិមនុស្សដទៃទៀតនៅក្នុងប្រទេសឥណ្ឌាបានផ្តល់ជាយោបល់ថា៖

- តុលាការដាច់ដោយឡែកមួយគួរតែត្រូវបានបង្កើតឡើងសម្រាប់ការស៊ើបអង្កេតនិងធ្វើការកាត់ទោសជនល្មើសក្នុងករណីរំលោភបំពាននានា។
- អង្គភាពពិសេសមួយគួរតែត្រូវបានបង្កើតឡើងនៅក្នុងប៉ុស្តិ៍ប៉ូលិសដើម្បីដោះស្រាយករណីបទល្មើសរំលោភឬការយាយីផ្លូវភេទ។
- មន្ត្រីប៉ូលីសស្រីគួរតែត្រូវបានចាត់តាំងឲ្យធ្វើការពិនិត្យកោសល្យវិនិច្ឆ័យលើជនរងគ្រោះជាស្ត្រី (ក្មេងស្រីនិងស្ត្រី) ក្នុងករណីរំលោភសេពសន្ថវៈឬការបំពានផ្លូវភេទនានា។
- ជម្រកសម្រាប់ស្ត្រីនិងសេវាកម្មប្រឹក្សាគួរតែត្រូវបានផ្តល់ជូនទៅដល់ជនរងគ្រោះដែលជួបការរំលោភ ការយាយីផ្លូវភេទ និងការបៀតបៀននិងអំពើហិង្សាគ្រប់ទម្រង់។

*នាង Sunita ពិតជាមានភាពក្លាហានក្នុងការបន្តតស៊ូដើម្បីស្វែងយុត្តិធម៌សម្រាប់ខ្លួននាង។ នាងមានសម្ពាធផ្លូវចិត្ត ប៉ុន្តែមិនដែលបាក់ទឹកចិត្តនោះឡើយ ...*

# កុមារី Sabina Khutan និងអង្គការអ្នកធ្វើការតាមផ្ទះ (GKS) ទីក្រុង Gurgaon ក្នុងប្រទេសឥណ្ឌា

*បររិយាយដោយ Elizabeth Khumallambam*
***Gharelu Kaamgar Sangathan, Gurgaon (GKS)***



## អំពើរំលោភបំពាន

សាកសពរបស់កុមារី Sabina Khutan ត្រូវបានគេប្រទះឃើញចងកសម្លាប់ខ្លួនកាលពីថ្ងៃទី២៩ ខែមករា ឆ្នាំ ២០១៤ នៅក្នុងគេហដ្ឋានរបស់ក្រុមគ្រួសារ Beri នៅទីក្រុង Gurgaon រដ្ឋធានី Haryana ប្រទេសឥណ្ឌា។ កុមារី Sabina គឺជាអ្នកធ្វើការតាមផ្ទះ ហើយនាងមានអាយុ ១៤ ឆ្នាំ។ ឪពុកម្តាយរបស់នាងមកពីតំបន់ West Bengal ដោយមានឪពុកធ្វើការនៅ Rajasthan មុនពេលគ្រួសារពួកគេទាំងអស់ផ្លាស់ទៅកាន់ភូមិ Nathupur ដែលមិនឆ្ងាយពីកន្លែងដែលគ្រួសារ Beri រស់នៅ។ កុមារី Sabina ជាកូនពៅនៅក្នុងគ្រួសារដែលនាងមានបងស្រីម្នាក់និងបងប្រុសម្នាក់។ ឪពុកនិងបងប្រុសរបស់នាងធ្វើការសំណង់នៅការដ្ឋានសំណង់។

## យុទ្ធសាស្ត្ររបស់ DWO និងវិធានការអនុវត្ត

នៅថ្ងៃដែលសាកសពរបស់ Sabina ត្រូវបានគេប្រទះឃើញស្លាប់ ក្រុមគ្រួសាររបស់នាងបានកសាងសំណុំរឿងបញ្ជូនទៅប៉ូលិសក្នុងតំបន់ ប៉ុន្តែប៉ូលិសមិនព្រមទទួលយកសំណុំរឿងនោះទេ។ ក្រុមគ្រួសារមានទុក្ខព្រួយជាខ្លាំងដោយមិនដឹងថាត្រូវទៅទីណាទៀតឡើយ។ ក្រោយមក អ្នកធ្វើការតាមផ្ទះម្នាក់ដែលជាសមាជិករបស់អង្គការ Gharelu Kaamgar Sangathan (GKS ជាអង្គការអ្នកធ្វើការតាមផ្ទះនៅ នៅទីក្រុង Gurgaon នៅជិតរដ្ឋធានីញូវដេលីប្រទេសឥណ្ឌា) បានដឹងពីស្ថានភាពគ្រួសាររបស់កុមារី Sabina ខណៈពេលកំពុងចែកខិតប័ណ្ណនៅតំបន់ក្បែរនោះហើយក្នុងពេលតែមួយសាច់ញាតិម្នាក់របស់ Sabina ក៏បានទាក់ទងអង្គការ GKS នេះដែរ។ នៅថ្ងៃបន្ទាប់ GKS បានទៅលេងគ្រួសាររបស់នាង ហើយបន្ទាប់ពីការពិភាក្សា ក្រុមការងារផ្នែកច្បាប់របស់ GKS និងសមាជិកគ្រួសារពីរនាក់របស់កុមារី Sabina បានទៅដាក់ពាក្យបណ្តឹងនៅទីស្នាក់ការប៉ូលិស។ ក្រោយមក សាកសពរបស់នាងត្រូវបានបញ្ជូនទៅមន្ទីរពេទ្យដើម្បីពិនិត្យ និងធ្វើកោសល្យវិនិច្ឆ័យ។




ដំបូងឡើយប៉ូលិសបានបដិសេធមិនបញ្ចេញរបាយការណ៍ការពិនិត្យនិងកោសល្យវិនិច្ឆ័យសាកសពឡើយ។ បន្ទាប់មកអង្គការ GKS បានប្រមូលផ្តុំកម្លាំងអ្នកធ្វើការតាមផ្ទះនៅឯមុខមន្ទីរពេទ្យដើម្បីទាមទាររបាយការណ៍នោះ។ អង្គការ GKS និងសមាជិករបស់ខ្លួនបាននិយាយថាប្រសិនបើមន្ទីរពេទ្យមិនព្រមចេញរបាយការណ៍ក្រោយមរណភាពទេ ពួកគេនឹងបដិសេធមិនយកសាកសពចេញពីទីនោះឡើយ។ បុគ្គលិកមន្ទីរពេទ្យក៏សម្រេចចិត្តផ្តល់របាយការណ៍ទៅក្រុមគ្រួសាររបស់ Sabina ។ ដំបូង របាយការណ៍នេះបាននិយាយថា Sabina បានស្លាប់ដោយសារជំងឺស្ទះដង្ហើម (asphyxia) ដោយមិនមានការសរសេររៀបរាប់ណាមួយពីការរំលោភបំពាននោះទេ។ GKS និងក្រុមគ្រួសារមិនជឿលើរបាយការណ៍នេះ ព្រោះបើយោងតាមក្រុមគ្រួសាររបស់ Sabina បានឲ្យដឹងថាជើងរបស់សាកសពបានប៉ះនឹងដីនៅពេលដែលនាងត្រូវបានគេប្រទះឃើញចងក ហើយរាងកាយរបស់នាងមានស្នាមរបួសនៅលើមុខនិងករបស់នាងដែលបង្ហាញពីការវាយដំលើរាងកាយ។ ដោយសារតែការតវ៉ានៅមន្ទីរពេទ្យ សកម្មជន GKS ពីរនាក់ត្រូវបានប៉ូលិសចាប់ខ្លួននិងឃុំខ្លួនហើយពួកគេត្រូវបានដោះលែងវិញនៅកណ្តាលអធ្រាត្រយប់ដដែល។

ក្រោយមក GKS បានដាក់ពាក្យបណ្តឹងនៅតុលាការស្រុក (District Court) ហើយទាមទារឲ្យមានការពិនិត្យលើរាងកាយសាកសពសារជាថ្មី។ តុលាការស្រុកបានយល់ព្រមហើយបានបញ្ជាឲ្យប៉ូលិសធ្វើការពិនិត្យឡើងវិញលើសាកសពនោះ។ ទន្ទឹមនឹងនេះដែរក្រុមគ្រួសារ Beri បានផ្តល់ទឹកប្រាក់ជូនក្រុមគ្រួសាររបស់នាង Sabina ចំនួនជាង ៤ ១៧៨ដុល្លារអាមេរិក ដើម្បីបញ្ឈប់ការស៊ើបអង្កេតចំពោះករណីស្លាប់របស់ Sabina។ ប៉ុន្តែក្រុមគ្រួសារជនរងគ្រោះបានបដិសេធនិងបានទាមទារស្វែងរកយុត្តិធម៌ឲ្យកូនរបស់ខ្លួនវិញ ព្រោះរបាយការណ៍ក្រោយមរណភាពលើកទី២ មានភាពខុសគ្នាពីរបាយការណ៍លើកទី១ ដោយរបាយការណ៍នេះបានបញ្ជាក់ពីការសង្ស័យថារាងកាយរបស់ Sabina ត្រូវបានគេរំលោភបំពានផ្លូវភេទ។ GKS បានទាមទារឲ្យប៉ូលិសស៊ើបអង្កេតលើក្រុមគ្រួសារ Beri ចំពោះករណីមរណភាពនេះដោយសំណាកឈាមរបស់ជនសង្ស័យ ៤ នាក់ដែលមានឪពុក កូនប្រុសពីរនាក់ និងអ្នកបើកបរម្នាក់ត្រូវបានបញ្ជូនទៅធ្វើតេស្ត DNA ។

ចាប់ពីខែកុម្ភៈ ឆ្នាំ២០១៤ មក អង្គការ GKS បានអំពាវនាវឲ្យមានការិយាល័យរដ្ឋាភិបាលនានាជាច្រើនដើម្បីបើកឲ្យមានការស៊ើបអង្កេតឲ្យបានហ្មត់ចត់និងទាន់ពេលវេលាលើករណីរំលោភបំពាននេះ។ ពួកគេបានទៅជួបជាមួយគណៈកម្មការជាតិការការពារសិទ្ធិកុមារ NCPCR (National Commission for the Protection of Child Rights), គណៈកម្មាធិការជាតិស្ត្រី NCW (National Commission for Women), ស្នងការប៉ូលិស (Police

Commissioner) ប្រធានគណៈកម្មការជនជាតិភាគតិច (Minority Commission) នៅរដ្ឋធានីញូវដេលី និង ប៉ូលិសគ្រប់ជាន់ថ្នាក់ ក៏ដូចជាសមាជិកសភានីតិប្បញ្ញត្តិ (Legislative Assembly) និងសមាជិកនៃសាជីវកម្ម (Municipal Corporation of Gurgaon) ទីក្រុង Gurgaon ផងដែរ។ នៅទីបំផុតនៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ ២០១៤ សវនាការសាធារណៈត្រូវបានរៀបចំឡើងដោយវេទិកាជាតិអ្នកធ្វើការតាមផ្ទះ (National Platform for Domestic Workers) ហើយករណីរបស់ Sabina ត្រូវបានលើកឡើងក្នុងវេទិកានេះដែរ។ ប្រធានគណៈកម្មការជាតិស្ត្រី NCW (National Commission for Women) លោកស្រី Smt Lalitha Kumaramnagalam សមាជិកគណៈវិនិច្ឆ័យនៅក្នុងសវនាការសាធារណៈ បាននិយាយថាលោកស្រីនឹងពិនិត្យយ៉ាងយកចិត្តទុកដាក់លើករណីពិសេសនេះនិងចាត់វិធានយ៉ាងហ្មត់ចត់បំផុត។

ប៉ុន្តែ របាយការណ៍តុលាការមិនបានបង្ហាញដល់ក្រុមគ្រួសារជនរងគ្រោះនៅឡើយ។ ដូច្នេះ GKS បានទាក់ទងអង្គភាពរដ្ឋាភិបាលនានាដើម្បីទាមទារឲ្យមានការចេញផ្សាយរបាយការណ៍នោះជាសាធារណៈ។ ក្នុងខែកុម្ភៈ ឆ្នាំ ២០១៥ ដោយមានជំនួយពី GKS ផងនោះ បងប្រុសរបស់នាង Sabina បានដាក់ពាក្យបណ្តឹងសិទ្ធិទទួលបានព័ត៌មាន (Right to Information) ទៅកាន់អគ្គនាយកដ្ឋាននគបាល (Director General of Police) លោក Haryana ដើម្បីទទួលបានព័ត៌មានអំពីការស៊ើបអង្កេតនិងរបាយការណ៍ធ្វើតេស្ត DNA។ នៅឆ្នាំបន្ទាប់គឺនៅខែមករា ឆ្នាំ២០១៦ បណ្តឹងមួយទៀតត្រូវបានដាក់ទៅកាន់តុលាការជាន់ខ្ពស់ (Chandigarh High court) ស្នើសុំឲ្យការិយាល័យកណ្តាលស៊ើបអង្កេត (Central Bureau of Investigation) តវ៉ាអំពីការពន្យាពេលក្នុងការចេញរបាយការណ៍វិភាគមន្ទីពិសោធន៍នៃការពិនិត្យក្រោយមរណភាព។ បន្ទាប់ពីការប្រឹងប្រែងស្វែងរកនេះ ក្នុងខែធ្នូ ឆ្នាំ ២០១៦ ក្រុមគ្រួសាររបស់ Sabina និង GKS បានទទួលបានរបាយការណ៍ព័ត៌មានបឋម (First Information Report) ដែលបានសរសេរយ៉ាងថាការពិនិត្យសំណាក DNA ទៅលើជនត្រូវចោទគឺលោក Apoorva Beri កូនប្រុសម្នាក់របស់ក្រុមគ្រួសារ Beri និងអ្នកបើកបរឈ្មោះ Om Prakash មានលក្ខណៈដូចគ្នានឹងសំណាកដែលយកចេញពីប្រដាប់ភេទរបស់សាកសពជនរងគ្រោះ។ ការធ្វើតេស្តខាងលើបានបញ្ជាក់ថាជនជាប់ចោទទាំង ២ នាក់បានចាប់រំលោភជនរងគ្រោះពិតមែន។ ដោយសារនាង Sabina ជាអនីតិជន ការចោទប្រកាន់ត្រូវបានធ្វើឡើងក្រោម ច្បាប់ការការពារកុមារពីបទល្មើសផ្លូវភេទ (Protection of Children from Sexual Offences (POCSO) Act) ឆ្នាំ២០១២។

នៅពេលដែលប៉ូលិសចេញដីកាចាប់ខ្លួនលោក Apoorva Beri និងលោក Om Prakash កាលពីខែមករា ឆ្នាំ ២០១៧ គឺពួកគេទាំងពីរនាក់បានភៀសខ្លួនចេញពីប្រទេស។ នៅខែមីនា ឆ្នាំ២០១៧ ក្រុមគ្រួសាររបស់ Sabina ត្រូវបានបញ្ចុះបញ្ចូលឲ្យដកពាក្យបណ្តឹងជាថ្នូរនឹងប្រាក់ ៨ សែនរូពីឥណ្ឌា (ប្រហែល ១១ ១៤០ ដុល្លារអាមេរិក) ប៉ុន្តែនៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៧ ចៅក្រមនៅតុលាការជាន់ខ្ពស់ (Chandigarh High Court) បានច្រានចោលការដកពាក្យបណ្តឹងរឿងក្តីនោះ។ ប៉ុន្តែទោះជាយ៉ាងណា នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ ខណៈមេធាវីជាច្រើននាក់កំពុងធ្វើកូដកម្មតវ៉ា ចៅក្រមម្នាក់ទៀតបានទទួលយកការបញ្ចប់រឿងក្តីនេះ។ បន្ទាប់មកអង្គការ **GKS** បានដាក់ពាក្យបណ្តឹងទៅតុលាការដើម្បីពិនិត្យឡើងវិញចំពោះដកសំណុំរឿងខាងលើនេះ។ ខណៈដែលជនសង្ស័យទាំងពីរនាក់បានរត់គេចខ្លួនពីប្រទេសឥណ្ឌា អង្គការ GKS បានទាក់ទងក្រសួងការបរទេស (Ministry of External Affairs) ដើម្បីសុំយោបល់ ប៉ុន្តែក្រសួងការបរទេសបានបញ្ជាក់ថាពួកគេមិនអាចធ្វើអ្វីបានបើគ្មានដីកាពីតុលាការ។ បន្ទាប់ពីទទួលបានចម្លើយបែបនេះអង្គការ GKS ដាក់ពាក្យបណ្តឹងនេះក្រោមឈ្មោះ GKS ទៅតុលាការម្តងទៀត។ ហើយនៅចន្លោះក្នុងខែមីនា និងខែមេសា ឆ្នាំ២០១៨ តុលាការបានប្រកាសថាលោក Om Prakash ដែលជាអ្នកបើកឡានធ្វើការតាមផ្ទះរបស់គ្រួសារជនល្មើសត្រូវបានគេប្រកាសថាជាជនបង្ករ ប៉ុន្តែមិន

អង្គការ GKS បានបន្តជំរុញឲ្យមានសវនាការនៅតុលាការ។ បន្ទាប់មកតុលាការជាន់ខ្ពស់ (Chandigarh High Court) បានរៀបចំសវនាការមួយដែលគ្រោងធ្វើឡើងនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩។ ប៉ុន្តែរហូតមកដល់ពេលនេះសវនាការនោះមិនទាន់បានធ្វើឡើងនៅឡើយ ហើយមេធាវីរបស់អង្គការ GKS នៅតែជំរុញឲ្យតុលាការបើកសវនាការសាកសួរអំពីមូលហេតុដែល លោក Apoorva Beri មិនត្រូវបានចោទប្រកាន់ជាជនល្មើស។ អស់រយៈពេល ៥ ឆ្នាំមក គ្មាននរណាម្នាក់ត្រូវបានចាប់ខ្លួនដាក់ទោសនៅឡើយ។

គ្រួសារ Beri មានគឺជាគ្រួសារដែលមានអំណាចហើយពួកគេប្រហែលជាបានសូកប៉ាន់ប៉ូលិសឲ្យបញ្ឈប់ឬពន្យារពេលការស៊ើបអង្កេតកន្លងមក។ គ្មានអ្នកភូមិណាម្នាក់ហ៊ាននិយាយអំពីរឿងក្តីនេះទៀតឡើយ ហើយអង្គការ GKS ក៏មិនអាចទទួលបានព័ត៌មានបន្ថែមអំពីគ្រួសារ Beri ដូចគ្នា។ ក្រុមអ្នកស៊ើបអង្កេតប៉ូលិសមានភាពលំអៀងនិងឃោរឃៅចំពោះក្រុមគ្រួសាររបស់ Sabina ដែលជាជនរងគ្រោះនិងអង្គការ GKS ។ របាយការណ៍ប៉ូលិសលើកទីមួយគឺជាការក្លែងបន្លំមិនមែនជារបាយការណ៍ពិតប្រាកដ ដែលបានធ្វើឲ្យអង្គការ GKS និងក្រុមគ្រួសារជនរងគ្រោះខិតខំប្រឹងប្រែងអស់រយៈពេលជាង ៥ ឆ្នាំមកហើយដើម្បីទាមទារឲ្យមានការស៊ើបអង្កេតត្រឹមត្រូវនិងការចេញរបាយការណ៍ក្រោយមរណភាពលើកទី២ពិតប្រាកដនិងរបាយការណ៍ការពិនិត្យ DNA។

## បញ្ហាប្រឈមនិងផ្លូវឆ្ពោះទៅមុខ

តាមរយៈបទពិសោធន៍របស់អង្គការ GKS បានបង្ហាញថាដើម្បីបញ្ជូនរឿងក្តីទៅរកភាពយុត្តិធម៌គឺត្រូវទាមទារឲ្យមានសកម្មភាពជំរុញផ្សេងៗដើម្បីដាក់សម្ពាធលើប៉ូលិស តុលាការ និងស្ថាប័នរដ្ឋាភិបាលនានាដើម្បីឲ្យរឿងក្តីនេះដើរទៅមុខ។ ជាអកុសលវាមិនងាយស្រួលទេសម្រាប់មនុស្សសាមញ្ញក្នុងការដាក់ពាក្យបណ្តឹងបានជោគជ័យក្រោមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ (Prevention of Corruption Act) ដោយសារតែអាជ្ញាធរមិនធ្វើសកម្មភាពដោយគ្មានភស្តុតាងជាក់ស្តែង ហើយដំណើរការនេះត្រូវចំណាយពេលយូរទៀតផង។ លើសពីនេះទៅទៀត ប្រសិនបើពាក្យបណ្តឹងមិនត្រូវបានប្រកាសថាជាករណីពុករលួយនោះទេ ដើមបណ្តឹងអាចនឹងត្រូវបានគេប្តឹងនិងចោទប្រកាន់ពីបទប្រព្រឹត្តិខុសមិនខាន។

អង្គការ GKS ចាត់ទុកថាករណីរំលោភសេពសន្ថវៈនិងឃាតកម្មទៅលើ Sabina ចង្អុលបង្ហាញបញ្ហាឬសគល់នៅក្នុងច្បាប់ស្តីពីពលកម្មកុមារ (ការហាមឃាត់និងបទបញ្ញត្តិ) (Child Labour) ពីព្រោះច្បាប់នេះហាមឃាត់តែពលកម្មកុមារក្នុងការងារតាមផ្ទះសម្រាប់កុមារអាយុក្រោម ១៤ ឆ្នាំប៉ុណ្ណោះ។ ប៉ុន្តែ អនីតិជនអាយុចន្លោះពី ១៤ ទៅ ១៨ ឆ្នាំត្រូវបានគេចាត់ទុកថាជាមនុស្សវ័យជំទង់ដែលមានការហាមឃាត់ក្មេងវ័យជំទង់ក្នុងការធ្វើការងារដែលមានគ្រោះថ្នាក់មួយចំនួន។ ទោះយ៉ាងណាការងារតាមផ្ទះមិនត្រូវបានគេចាត់ទុកថាជា «ការងារដែលមានគ្រោះថ្នាក់» សម្រាប់ក្មេងវ័យជំទង់នោះទេ ដូច្នេះមនុស្សដែលមានអាយុចន្លោះពី ១៤-១៨ ឆ្នាំអាចធ្វើការជាអ្នកធ្វើការតាមផ្ទះបាន។

បញ្ហាមួយទៀតគឺទាក់ទងនឹងកង្វះការអនុវត្តច្បាប់។ អធិការកិច្ចការងារអាចចុះពិនិត្យរោងចក្រឬកន្លែងធ្វើការផ្លូវការផ្សេងទៀត ហើយប្រសិនបើមានការរំលោភបំពានច្បាប់ គឺអាជ្ញាប័ណ្ណរបស់រោងចក្រ ឬក្រុមហ៊ុននោះនឹងត្រូវដកហូតចេញ។ ទោះយ៉ាងណាក៏ដោយ មិនមានអ្នកត្រួតពិនិត្យមើលការជួលពលកម្មកុមារនៅធ្វើការក្នុងផ្ទះឯកជននោះទេ។ ដូច្នេះ ហើយបានជាពលកម្មកុមារក្នុងការងារតាមផ្ទះនៅតែមានច្រើននៅក្នុងប្រទេសឥណ្ឌា។




រូបភាព: GKS

ទស្សនៈរឹងមាំរបស់ GKS គឺកុមារត្រូវតែមានសិទ្ធិទទួលបានការអប់រំត្រឹមត្រូវ ហើយកុមារនិងក្មេងជំទង់ដែលមានអាយុក្រោម ១៨ ឆ្នាំគួរតែត្រូវបានហាមឃាត់មិនឲ្យចូលរួមក្នុងការងារតាមផ្ទះដែលការងារត្រូវបានចាត់ថាជាការងារគ្រោះថ្នាក់ដល់អ្នកដែលមានអាយុក្រោម ១៨ឆ្នាំ។ ម្យ៉ាងទៀតគួរតែមានគោលនយោបាយស្ដីអំពីការធ្វើការតាមផ្ទះដោយមានការកំណត់លក្ខខណ្ឌការងារនិងសុខុមាលភាពរបស់ពួកគេនិងទទួលស្គាល់សិទ្ធិរបស់ពួកគេដោយមានបទប្បញ្ញត្តិច្បាស់លាស់និងវិធានការអនុវត្តន៍ ដូចជាការត្រួតពិនិត្យការងារនៅក្នុងគ្រួសារឯកជនដែលជាកន្លែងមានអ្នកធ្វើការតាមផ្ទះបម្រើការ។

ដូចនឹងចលនាអ្នកធ្វើការតាមផ្ទះជាតិក្នុងប្រទេសឥណ្ឌា (NDWM) ដែរ អង្គការអ្នកធ្វើការតាមផ្ទះ (GKS) គាំទ្រការឲ្យមានការបង្កើតតុលាការនិងអង្គភាពប៉ូលិសដាច់ដោយឡែកដោយមានមន្ត្រីស្រីធ្វើការទទួលយកករណីរំលោភផ្លូវភេទលើកុមារនិងស្ត្រីរួមទាំងអ្នកធ្វើការក្នុងផ្ទះ។ អង្គភាពឯករាជ្យនិងឯកទេសបែបនេះសម្រាប់ជនរងគ្រោះនៃការរំលោភបំពានផ្លូវភេទដែលភាគច្រើនជាស្ត្រី នឹងជួយពន្លឿនការស៊ើបអង្កេតនិងដំណើរការតុលាការបានយ៉ាងល្អប្រសើរ។

ចំណុចដែលត្រូវកែប្រែនៃស្ថាប័នមួយទៀតដែលត្រូវដោះស្រាយគឺគណៈកម្មការជាតិដូចជា គណៈកម្មការជាតិការការពារសិទ្ធិកុមារ (NCPCR) និងគណៈកម្មការជាតិស្ត្រី (NCW) ដែលបច្ចុប្បន្នមានតួនាទីជាស្ថាប័នប្រឹក្សាយោបល់ដល់រដ្ឋាភិបាលហើយមិនមានសិទ្ធិអំណាចនោះឡើយ និងអំណាចស្ថាប័ននេះដើម្បីបញ្ជាឲ្យនាយកដ្ឋានរដ្ឋាភិបាលធ្វើសកម្មភាពដោះស្រាយ។ គណៈកម្មការគួរតែត្រូវបានផ្ដល់អំណាចបន្ថែមទៀតក្នុងការសួរដេញដោលលើករណីអ្វីមួយ។ ឧទាហរណ៍ ប្រសិនបើគណៈកម្មការស្នើសុំអង្គភាពរដ្ឋាភិបាលដើម្បីឆ្លើយតបតែមិនមានការឆ្លើយតបណាមួយ គណៈកម្មការគួរតែមានសិទ្ធិអំណាចដើម្បីតម្រូវឲ្យអង្គភាពពាក់ព័ន្ធផ្ដល់ការពន្យល់លើហេតុផលមិនឆ្លើយតបលើករណីនោះ។

*...អនីតិជនអាយុចន្លោះពី ១៤ទៅ១៨ឆ្នាំ ត្រូវបានគេចាត់ទុកថាជាមនុស្សវ័យជំទង់ ហើយមានការហាមឃាត់ជាក់លាក់ដោយច្បាប់ក្នុងការហាមឃាត់ក្មេងជំទង់មិនឲ្យធ្វើការក្នុងការងារដែលមានគ្រោះថ្នាក់មួយចំនួន។*

*ទោះយ៉ាងណាការងារតាមផ្ទះមិនត្រូវបានគេចាត់ទុកថាជា «ការងារដែលមានគ្រោះថ្នាក់» សម្រាប់ក្មេងវ័យជំទង់នោះទេ ដូច្នេះកុមារដែលមានអាយុចន្លោះពី ១៤-១៨ ឆ្នាំ អាចធ្វើការអ្នកធ្វើការតាមផ្ទះបាន។*

## អ្នកស្រី Anowara Begum និងសហជីពស្ត្រីអ្នកធ្វើការតាមផ្ទះជាតិ ( The National Domestic Women Workers Union ), ទីក្រុងដាកា ( Dhaka ), ប្រទេសបង់ក្លាដេស

***បរិយាយដោយលោកស្រី Murshita Akter អគ្គលេខាធិការនៃសហជីពស្ត្រីអ្នកធ្វើការតាមផ្ទះជាតិ (NDWWU)***



សហជីពស្ត្រីអ្នកធ្វើការតាមផ្ទះជាតិ (NDWWU) បានជួយអ្នកស្រី Anowara Begum ដែលមានអាយុ ៣៥ឆ្នាំ ក្នុងការទទួលបានប្រាក់ឈ្នួល៣ខែដែលមិនបានទូទាត់ដោយនយោជក លោក Jahid តាមរយៈសកម្មភាពប្រមូលផ្តុំផ្ទាល់និងរហ័សរបស់ក្រុមអ្នកធ្វើការតាមផ្ទះ។

### អំពើរំលោភបំពាន

អ្នកស្រី Anowara ធ្វើការជាអ្នកធ្វើការតាមផ្ទះក្រៅម៉ោងក្នុងគ្រួសាររបស់លោក Jahid ក្នុងតំបន់ Demra ទីក្រុង Dhaka ប្រទេសបង់ក្លាដេស ចាប់ពីខែសីហា រហូតដល់ខែតុលា ឆ្នាំ២០១៨។ ដើមឡើយ នយោជករបស់អ្នកស្រី Anowara បានយល់ព្រមបង់ថ្លៃប្រាក់ឈ្នួលចំនួនប្រហែល ១៤ដុល្លារអាមេរិក ក្នុងមួយខែសម្រាប់ការងារជាអ្នកធ្វើការតាមផ្ទះ។ ប៉ុន្តែ លោក Jahid តែងតែបង្ខំឲ្យលោកស្រីបោសសម្អាតពេញម៉ោងដោយទទួលបានប្រាក់ឈ្នួលប្រចាំខែក្នុងតម្លៃចរចាគ្នាខាងលើទៅវិញ។ លើសពីនេះ លោក Jahid មិនបានទូទាត់ប្រាក់ឈ្នួលឲ្យអ្នកស្រី Anowara រយៈពេល៣ខែនោះឡើយ។

កាលដើមខែតុលា ឆ្នាំ២០១៨ អ្នកស្រី Anowara មិនប្រយ័ត្នបានធ្វើឲ្យធ្លាក់កែវទឹកដោយចៃដន្យ ខណៈដែលលោកស្រីកំពុងលាងចានបន្ទាប់ពីការទទួលទានអាហារពេលព្រឹកហើយ។ លោក Jahid ដែលជានយោជកបានផ្ទុះកំហឹងជាខ្លាំង ហើយបានដេញបណ្តេញលោកស្រីចេញពីផ្ទះដោយមិនមានការទូទាត់ប្រាក់ឈ្នួលអ្វីឡើយ ហើយករណីនេះបានឈានចូលដល់អំពើហិង្សារថែមទៀត។ អ្នកស្រី Anowara ត្រូវទទួលរងការវាយដំយ៉ាង

កំរោលប្រមាណ ៣នាទីពីសំណាក់ជយោជកកំណាចរូបនោះ។ លោក Jahid បានទះនិងវាយដំខ្នង ទាញសក់អូសអ្នកស្រី Anowara ពីជាន់ទី៣ដល់ជាន់ផ្ទាល់ដី។ បន្ថែមពីនេះទៀត នយោជករូបនេះថែមទាំងបានបណ្តេញអ្នកស្រីចេញពីអាផាតមិន (apartment) ថែមទៀត។ អ្នកស្រី Anowara ទទួលរងការឈឺចាប់ផ្នែកក្បាល និងឈឺឆាប់ពេញរាងកាយ។

## យុទ្ធសាស្ត្ររបស់ DWO និងវិធានការអនុវត្ត

បន្ទាប់ពីករណីអំពើហិង្សានេះកើតឡើង អ្នកស្រី **Anowara** ដែលជាសមាជិកម្នាក់របស់សហជីពស្ត្រីអ្នកធ្វើការតាមផ្ទះជាតិ (**NDWWU**) បានស្វែងរកជំនួយពីលោកស្រី Shahanur Begum លេខាផ្នែកចងក្រងរបស់សហជីពស្ត្រីអ្នកធ្វើការតាមផ្ទះ (NDWWU Organizing Secretary) ក្នុងតំបន់ **Demra**។ នាថ្ងៃបន្ទាប់ ដោយមានការជួយពីសំណាក់សហជីពស្ត្រីអ្នកធ្វើការតាមផ្ទះ ក្រុមអ្នកធ្វើការតាមផ្ទះមានគ្នាប្រមាណ ៥០នាក់ក្នុងតំបន់ **Demra** បានប្រមូលផ្តុំគ្នានិងបានធ្វើដំណើរទៅផ្ទះរបស់លោក Jahid និងតវ៉ាឲ្យមានការទូទាត់ប្រាក់ឈ្នួលជូនអ្នកស្រី Anowara។ លោក Jahid មានការភ្ញាក់ផ្អើលដោយឃើញមានក្រុមអ្នកធ្វើការតាមផ្ទះច្រើននាក់លើកផ្ទាំងបដាសហជីពស្ត្រីអ្នកធ្វើការតាមផ្ទះជាតិ (**NDWWU**) ហើយលោកបានធ្វើការទូទាត់ប្រាក់ឈ្នួលជូនអ្នកស្រី **Anawara** ភ្លាមៗ។ ប៉ុន្តែ នយោជករូបនេះបានធ្វើការកាត់ប្រាក់ខែចំនួន ២០តាកា (ស្មើនឹង ០.២៤សែន) ក្នុងតម្លៃកែវដែលអ្នកស្រី **Anawara** បានធ្វើឲ្យធ្លាក់បែក។

## ឧបសគ្គនិងវិធីដោះស្រាយ

យោងតាមបទពិសោធន៍របស់សហជីពស្ត្រីអ្នកធ្វើការតាមផ្ទះជាតិ (**NDWWU**) អ្នកធ្វើការតាមផ្ទះស្ទើតែ ១០០ ភាគរយក្នុងប្រទេសបង់ក្លាដេសគឺជាស្ត្រី ហើយពួកគេប្រឈមនឹងបញ្ហាដូចៗគ្នា។ ករណីរឿងនេះបង្ហាញឲ្យឃើញថាអ្នកធ្វើការតាមផ្ទះម្នាក់អាចធ្លាក់ខ្លួនជាជនរងគ្រោះនៃអំពើហិង្សាយេនឌ័រផ្នែកសេដ្ឋកិច្ចនិងផ្លូវកាយ ដោយសារតែពួកគេគឺជាស្ត្រីភេទ។ ស្ត្រីងាយក្នុងការធ្លាក់ចូលក្នុងការធ្វើបាបផ្នែកផ្លូវកាយនិងការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ចតាមរយៈរូបភាពនានាដូចជាការបន្ថែមម៉ោងធ្វើការដោយមិនផ្តល់ប្រាក់ឈ្នួលបន្ថែម ពន្យាពេលឬដកទុកប្រាក់ឈ្នួលជាដើម។

ក្នុងប្រទេសបង់ក្លាដេស ច្បាប់ប្រឆាំងនឹងការបៀតបៀននិងអំពើហិង្សារលើអ្នកធ្វើការតាមផ្ទះត្រូវបានដាក់បញ្ចូលក្នុងក្រមព្រហ្មទណ្ឌ (Penal Code) ក្នុងច្បាប់ការងារ (Labour Act) ប្រទេសបង់ក្លាដែស ក្នុងឆ្នាំ២០០៦ ដែលត្រូវបានធ្វើវិសោធនកម្មក្នុងឆ្នាំ២០១៨ ដោយអនុលោមតាមស្តង់ដាររបស់អាយឡូ (**ILO**) ស្តីអំពីច្បាប់ការពារការគាបសង្កត់ស្ត្រីនិងកុមារ ឆ្នាំ២០០០ ( Prevention of Oppression against Women and Children Act of 2000 ) និងច្បាប់ការងារនិងការធ្វើចំណាកស្រុកក្រៅប្រទេសឆ្នាំ ២០១៣ (Overseas Employment and Migration Act of 2013)។

លើសពីនេះទៀត គោលការណ៍សុខុមាលភាពនិងការពារអ្នកធ្វើការតាមផ្ទះ (Domestic Worker Protection and Welfare Policy) ដែលបានអនុម័តក្នុងឆ្នាំ២០១៥ និងក្នុងឆ្នាំ២០០៩ តុលាការកំពូលបង់ក្លាដែស បានដាក់ចេញនូវ គោលការណ៍ណែនាំលើគោលនយោបាយបង្ការការបៀតបៀនផ្លូវភេទ (Guidelines on the Elimination and Prevention of Sexual Harassment Policy)។ ទោះបីជាយ៉ាងណាក៏ដោយ ច្បាប់ការងារឆ្នាំ២០០៦ (2006 Labour Act) មិនទាន់ត្រូវបានធ្វើវិសោធនកម្មដាក់បញ្ចូលអ្នកធ្វើការតាមផ្ទះនៅឡើយទេ។ ដោយសារតែហេតុផលនេះហើយ គោលនយោបាយឆ្នាំ២០១៥ដើម្បីការពារអ្នកធ្វើការតាមផ្ទះ និងគោលការណ៍ណែនាំឆ្នាំ២០០៩ ប្រឆាំងនឹងការរំលោភបំពានផ្លូវភេទមិនទាន់ត្រូវបានអនុវត្តឲ្យមានប្រសិទ្ធភាពនៅឡើយទេ។

សហជីពស្រ្តីអ្នកធ្វើការតាមផ្ទះជាតិ (**NDWWU**) មានការជឿជាក់លើកម្លាំងនៃការចងក្រង។ អំឡុងរយៈពេល ២ឆ្នាំកន្លងទៅ សហជីពស្រ្តីអ្នកធ្វើការតាមផ្ទះ បានធ្វើការចងក្រងអ្នកធ្វើការតាមផ្ទះក្នុងតំបន់ផ្សេងៗក្នុងទីក្រុង **Dhaka** និងទីក្រុងនានាក្នុងប្រទេសបង់ក្លាដែស និងបានធ្វើការផ្តល់ជូននូវការបណ្តុះបណ្តាលវិធីសាស្រ្តបង្កើតបណ្តាញនិងចងក្រង ការពារនិងដោះស្រាយបញ្ហាអំពើហិង្សាយេនឌ័រផងដែរ។ សហជីពស្រ្តីអ្នកធ្វើការតាមផ្ទះជាតិ (**NDWWU**) ចង់បង្ហាញនូវអំណាចនៃការចងក្រងតាមរយៈការអន្តរាគមន៍ផ្ទាល់និងជាក់ស្តែង។ នៅពេលមានអ្នកធ្វើការតាមផ្ទះណាម្នាក់ប្រឈមនឹងបញ្ហាជាមួយនយោជក ត្រូវធ្វើការទំនាក់ទំនងទៅកាន់សមាជិកអ្នកធ្វើការតាមផ្ទះដទៃទៀត ដែលនេះធ្វើឲ្យនយោជកត្រូវប្រឈមនឹងក្រុមអ្នកធ្វើការតាមផ្ទះជាច្រើននាក់។ ជាធម្មតានយោជកនឹងមានអារម្មណ៍ភ័យខ្លាចនៅពេលមានសហជីពទៅជួបដោយមានក្រុមអ្នកធ្វើការតាមផ្ទះច្រើននាក់ ហើយពួកគេនឹងប្រាកដជាចង់ធ្វើការជជែកដោះស្រាយដោយស្ងាត់ៗមិនខាន។ ការធ្វើបែបនេះគឺជាការដាក់សម្ពាធទៅលើនយោជកឲ្យមានការចរចានិងផ្តល់ជូននូវការទាមទារក្នុងការចរចា។

សហជីពស្រ្តីអ្នកធ្វើការតាមផ្ទះជាតិ (**NDWWU**) ក៏បានរកឃើញផងដែរថាការយុទ្ធសាស្រ្តចងក្រងនិងបង្កើតបណ្តាញមានភាពជោគជ័យជាច្រើនករណីរួចមកហើយ ដោយសារលទ្ធផលនៃការចរចាទំនងមានភាពទេរទៅរកអ្នកធ្វើការតាមផ្ទះនិងអាចជួយឲ្យពួកគេទទួលបានយុត្តិធម៌។ វិធានការផ្លូវច្បាប់មានរយៈពេលយូរនិងត្រូវការចំណាយថវិកាច្រើន។ ជនរងគ្រោះដែលជាអ្នកធ្វើការតាមផ្ទះជាទូទៅត្រូវការការចាយវាយលើការធ្វើដំណើរ និងបង់ប្រាក់ក្នុងដំណើរសវនាការតុលារ ហើយចុងក្រោយក៏មិនច្បាស់ថាអាចទទួលបានយុត្តិធម៌ឬអត់ផង។ ដូច្នេះសហជីពស្រ្តីអ្នកធ្វើការតាមផ្ទះជាតិ (**NDWWU**) ជ្រើសរើសសកម្មភាពចងក្រងជាក្រុមដើម្បីដោះស្រាយបញ្ហាដោយផ្ទាល់រវាងអ្នកធ្វើការតាមផ្ទះនិងនយោជក។ ការធ្វើបែបនេះក៏អាចជាវិធីមួយដែលធ្វើឲ្យនយោជកមានការបាក់មុខ អាម៉ាស់ និងថែមទាំងអាចជួយឲ្យជនរងគ្រោះទទួលបានការសិទ្ធិទាមទារពីនយោជកផងដែរ។

*មនុស្សប្រមាណជិត ១០០ភាគរយនៃអ្នកធ្វើការតាមផ្ទះក្នុងប្រទេសបង់ក្លាដែសគឺជាស្រ្តី ហើយពួកគេកំពុងប្រឈមនឹងបញ្ហាដូចគ្នានឹងបញ្ហារបស់អ្នកស្រី Anowara។*

# អ្នកស្រី **Maria** និងសមាគមអ្នកធ្វើការតាមផ្ទះសាន់ឌីហ្គីន - គុយវ៉ែត (**SKDWA**) ទីក្រុងគុយវ៉ែត ប្រទេសគុយវ៉ែត

*បរិយាយដោយ Mary Ann Abunda ស្ថាបនិកសមាគមអ្នកធ្វើការតាមផ្ទះសាន់ឌីហ្គីន - គុយវ៉ែត (Sandigan-Kuwait Domestic Workers Association)*



https://Unsplash.com/photos/I4vDYnvelbs [Tony Yang]

## អំពើរំលោភបំពាន

អ្នកស្រី **Maria** (មិនមែនជាឈ្មោះពិត) ជាអ្នកធ្វើការតាមផ្ទះចំណាកស្រុកពីទីក្រុងហ្សាមបូហ្គាន (Zamboanga City) កោះមិនដាណាវ (Mindanao) ប្រទេសហ្វីលីពីន បានចាប់ផ្តើមធ្វើការចំណាកស្រុកជាអ្នកធ្វើការតាមផ្ទះក្នុងប្រទេសគុយវ៉ែត កាលពីខែវិច្ឆិកា ឆ្នាំ២០១៧។ អ្នកស្រីមានអាយុ ៣២ឆ្នាំ។ អ្នកស្រី **Maria** បានធ្វើការជាអ្នកធ្វើការតាមផ្ទះក្នុងគ្រួសារមួយដែលមានសមាជិក៣នាក់ មានប្តីប្រពន្ធ និងកូនស្រីអាយុ១៣ឆ្នាំម្នាក់។ មិនខុសពីអ្នកធ្វើការតាមផ្ទះចំណាកស្រុកជាច្រើននាក់ផ្សេងទៀតក្នុងប្រទេសដីកោះមួយនេះ អ្នកស្រី **Maria** ត្រូវបានទទួលរងការធ្វើបាប ការសម្លុតគម្រាម វាយដុំរាល់ថ្ងៃ និងមិនទទួលបានប្រាក់ឈ្នួលពេញលេញនោះឡើយ។

អំឡុងពេលការធ្វើបទសម្ភាសការងារ ថៅហ្វាយស្រីដែលជានយោជករបស់អ្នកស្រីបានបង្ហាញគ្រឿងពាក់សំគាល់ខ្លួនក្លែងក្លាយជាប៉ូលិសក្នុងគោលបំណងបំប្លែងខ្លួនថាជាប៉ូលិសគុយវ៉ែត បើទោះបីជាក្រុមគ្រួសាររបស់លោកស្រីមិនមែនជាជនជាតិគុយវ៉ែតក្តី។ ការរំលោភបំពានបានចាប់កើតឡើងបន្ទាប់ពីនយោជកទាំងពីររូបប្តីប្រពន្ធនោះបានរកឃើញរូបថតកូនស្រីរបស់ខ្លួនក្នុងកាបូបរបស់ Maria។ អ្នកស្រី Maria ត្រូវបានចោទប្រកាន់ពីបទប្រព្រឹត្តអំពើផ្លូវភេទលើកុមារ និងសង្ស័យថាបានប្រព្រឹត្តបទល្មើសចាប់រំលោភកូនស្រីខាងលើផង។ ថៅហ្វាយស្រីរូបនោះបានបង្ខំឲ្យអ្នកស្រី Maria ឆ្លើយសារភាពពីបំណងអាក្រក់របស់ខ្លួនទៅលើកូនស្រីនៅមុខ

កាមេរ៉ាវីដេអូ។ ថៅហ្វាយស្រីរូបនោះបានគម្រាមអ្នកស្រី Maria ថាខ្លួននឹងយកវីដេអូនោះទៅប្រគល់ឲ្យប៉ូលិស និងឲ្យប៉ូលិសដាក់ទោសអ្នកស្រី។

អ្នកស្រី Maria មានការភ័យខ្លាចជាខ្លាំង ដោយអ្នកស្រីមិនហ៊ានបដិសេធនឹងថៅហ្វាយស្រីរូបនោះឡើយ ដោយសារតែអ្នកស្រីគិតថាថៅហ្វាយស្រីរបស់ខ្លួនគឺជាមន្ត្រីប៉ូលិស។ នាថ្ងៃបន្ទាប់ ក្នុងស្ថានភាពអារម្មណ៍កើតទុក្ខព្រួយ Maria បានភ្លេចលាងសម្អាតសាប៊ូក្នុងប៉ាន់តែមុនពេលធ្វើការឆុងតែ។ អ្នកស្រីថៅហ្វាយរូបនោះបានចោទប្រកាន់ អ្នកស្រី Maria ពីអំពីបទឃាតកម្មដោយចេតនា ហើយថៅហ្វាយកំណាចរូបនោះបានបង្ខំឲ្យ Maria ផឹកទឹកតែដែលមានសាប៊ូក្នុងប៉ាន់តែនោះ និងបង្ខំឲ្យផឹកទឹកសាប៊ូមួយដបផងដែរ។ ចាប់តាំងពីពេលនោះមក អ្នកស្រី Maria ត្រូវបានឃាយី បំពារបំពានពីសំណាក់នយោជកកំណាចដោយឆ្នាំងអ៊ុត កន្ត្រៃ ជ័រ កាំបិត រំពាត់ ស្ទើររាល់ថ្ងៃ។ នយោជកស្រីរូបនោះបានកាត់សក់របស់ Maria យ៉ាងកំរោលដែលធ្វើឲ្យមុតដាច់ស្បែកក្បាល និងបានចាក់ទឹកខ្មេះលើស្នាមរបួសយ៉ាងឃោឃៅថែមទៀត។




ថ្នាក់ដឹកនាំអ្នកធ្វើការតាមផ្ទះចំណាកស្រុកហ្វីលីពីនមកពីតំបន់ផ្សេងៗគ្នាដើម្បីចូលរួមកម្មវិធីសន្និសីទមួយក្នុងខែធ្នូ ២០១៩។ រូបថត៖ ADWF

## យុទ្ធសាស្ត្ររបស់ DWO និងវិធានការអនុវត្ត

នាថ្ងៃមួយ នយោជករបស់ **Maria** បានវាយដុំអ្នកស្រីយ៉ាងដំណំដោយដំបង។ ការវាយដំនេះគឺជាពិតជាឃោឃៅ ដោយ **Maria** មានអារម្មណ៍ស្ទើរស្លាប់ស្ទើររស់។ ក្នុងពេលនោះ អ្នកស្រី **Maria** បានសម្រេចចិត្តស្វែងរកជំនួយតាមរយៈការបង្ហោះវីដេអូខ្លីបមួយទៅលើបណ្តាញទំនាក់ទំនងហ្វេសបុក (**Facebook**) ដោយប្រើប្រាស់ថេបប្លេតរបស់កូនស្រីនយោជកនោះ។ ការបង្ហោះរបស់អ្នកស្រីទទួលបានការចាប់អារម្មណ៍ពីសំណាក់ សមាគមអ្នកធ្វើការតាមផ្ទះសាន់ឌីហ្គីន - គុយវ៉ែត (SKDWA) ហើយបានស្នើទៅកាន់ស្ថានទូតហ្វីលីពីនក្នុងប្រទេសគុយវ៉ែតដើម្បីធ្វើការជួយ Maria។ នៅពេលស្ថានទូតបញ្ជូនអ្នកតំណាងទៅកាន់កន្លែងធ្វើការរបស់ Maria នយោជករូបនោះបានបដិសេធថាខ្លួនមិនបានធ្វើអំពើរំលោភបំពានបែបនោះឡើយ។ អ្នកស្រី Maria មានភាពភ័យតក់ស្លុតយ៉ាងខ្លាំង និងបានបដិសេធមិនចាកចេញពីផ្ទះនយោជកនោះ។ ក្រោយមក ក្នុងខែមេសា ឆ្នាំ២០១៨ ស្ថានទូតគុយវ៉ែតបាន

ដាក់ពាក្យបណ្ដឹងទៅកាន់ប៉ូលីសគុយវ៉ែតដើម្បីនាំខ្លួន Maria ទៅកាន់ប៉ុស្ដិ៍ប៉ូលិសដើម្បីធ្វើការសាកសួរ។

នៅប៉ុស្ដិ៍ប៉ូលិស អ្នកស្រី **Maria** នៅស្ងប់ស្ងាត់ មិនមាត់ មិនស្ដីអ្វីទាំងអស់។ អ្នកស្រី **Ann** ថ្នាក់ដឹកនាំសមាគមអ្នកធ្វើការតាមផ្ទះសាន់ឌីហ្គិន - គុយវ៉ែត (SKDWA) បានមកជួប Maria នៅប៉ុស្ដិ៍ប៉ុលិស និងបានឃើញថាមានស្នាមរបួសនិងស្នាមជាំលើពេញដងខ្លួននៅក្រោមកន្សែងបង់ក និងសំលៀកបំពាក់របស់ Maria។ នៅពេលទទួលរងអំពើហិង្សាវាយដំ អ្នកស្រី Maria មិនបានយកដៃទៅរងដើម្បីការពារខ្លួនប្រាណនោះឡើយ។ អ្នកស្រី Ann បានស្នើសុំឲ្យស្ថានទូតគុយវ៉ែតអនុញ្ញាតិឲ្យអ្នកស្រីអាចធ្វើការនិយាយជាមួយ Marai ដោយភាពឯកជន។ ក្រោយមកអ្នកស្រី Maria បានធ្វើការរៀបរាប់អំពីរឿងរ៉ាវ និងការព្រួយបារម្ភអំពីរឿងបង្ហោះវីដេអូខ្លីបនោះ។ មេធាវីមួយរូបបានបញ្ជាក់ប្រាប់អ្នកស្រី Maria ថានយោជករបស់អ្នកស្រីមិនអាចប្រើប្រាស់វីដេអូខ្លីបនោះដើម្បីបំភ័យអ្នកស្រីបានឡើយ។ ប៉ុន្តែ វីដេអូខ្លីបនោះអាចប្រើប្រាស់ជាភស្ដុតាងដើម្បីនាំខ្លួននយោជកនោះទៅកាន់តុលាការបាន។ រយៈពេល១ខែក្រោយមក អ្នកស្រី Maria បានដាក់ពាក្យបណ្ដឹងទៅកាន់ប៉ូលិសគុយវ៉ែត ហើយទទួលបានមេធាវីពីស្ថានទូតហ្វីលីពីន ដើម្បីធ្វើជាមេធាវីអំណាចពិសេស (Special Power Attorney) តំណាងក្នុងដំណើរការតុលាការក្នុងប្រទេសគុយវ៉ែត។

បើទោះបីជាយ៉ាងណាក៏ដោយ រហូតមកទាល់ពេលនេះមិនទាន់មានដំណឹងណាមួយទាក់ទងនឹងករណីខាងលើនោះឡើយ។ អ្នកស្រី Maria បានត្រលប់ទៅផ្ទះវិញ និងទទួលរងការឈឺចាប់ផ្នែករាយកាយពីការវាយដំ រំលោភបំពាន។ អ្នកស្រី មានការរងរបួសខ្លាំងនិងតែងតែមានអារម្មណ៍ចង់ក្អួតចង្អោរ រាល់ពេលធុំក្លិនសាប៊ូម្ដងៗ។

## ឧបសគ្គប្រឈមនិងវិធីដោះស្រាយ

ក្នុងប្រទេសគុយវ៉ែត ការរំលោភនិងការបំពារបំពានផ្នែករូបរាងកាយត្រូវចាត់ចូលជាច្បាប់ក្រមព្រហ្មទណ្ឌ ហើយការផ្ដល់ការងារដល់អ្នកធ្វើការតាមផ្ទះចំណាកស្រុកដែលមកពីប្រទេសដទៃមានចែងក្នុងច្បាប់អន្តោប្រវេសន៍និងច្បាប់ការងារផងដែរ។ ច្បាប់លេខ៦៨ (**Law No.** 68) នៃការងារអ្នកធ្វើការតាមផ្ទះឆ្នាំ២០១៥ (**Employment of Domestic Workers of** 2015) ចែងថាបុគ្គលគ្រប់រូបគ្មានសិទ្ធិក្នុងការបង្អាប់បន្ទាបសេចក្ដីថ្លៃថ្នូររបស់អ្នកធ្វើការតាមផ្ទះឡើយ។

សមាគមអ្នកធ្វើការតាមផ្ទះសាន់ហ្គេន - គុយវ៉ែត (SKDWA) រកឃើញថាប៉ូលិសគុយវ៉ែតតែងតែចាត់វិធានការប្រឆាំងអំពើរំលោភបំពានទៅលើអ្នកធ្វើការតាមផ្ទះនៅពេលមានការរាយការណ៍ណាមួយ។ ទោះបីយ៉ាងក៏ដោយករណីមួយចំនួនតូចប៉ុណ្ណោះដែលត្រូវបានរាយការណ៍ទៅប៉ូលិស ដោយសារកត្តាឧបសគ្គនៃភាសា ការសម្លុតគំរាប និងភាពស្ទាក់ស្ទើររបស់ជនរងគ្រោះក្នុងការរាយការណ៍អំពីការរំលោភបំពានណាមួយ ពីព្រោះនយោជករបស់ពួកគេនិងប៉ូលិសរស់នៅក្នុងសហគមន៍ជាមួយគ្នាដោយមានប៉ូលិសមួយចំនួនមានជាប់ខ្សែ ឬសាច់ញាតិជាមួយជនបង្កផង។

អ្នកធ្វើការតាមផ្ទះចំណាកស្រុកជាច្រើន ដូចជាអ្នកស្រី Maria ជាដើម មានការស្ទាក់ស្ទើមិនហ៊ានក្នុងការរាយ

ករណីអំពីអំពើហិង្សា ការយាយីបំពារបំពាន ពីព្រោះតែច្បាប់អន្តោប្រវេសន៍ក្នុងប្រទេសគុយវ៉ែត ក៏ដូចក្នុងប្រទេសដទៃទៀត ហាមមិនឲ្យអ្នកធ្វើការតាមផ្ទះចំណាកស្រុកចាកចេញពីផ្ទះនយោជក និងស្វែងរកនយោជកថ្មី ដោយគ្មានការព្រមព្រៀងពីនយោជកដើមឡើយ បើទោះបីជានយោជកនោះរំលោភបំពានជនរងគ្រោះក្តី។

## អ្នកស្រី **Baby Jane Allas** និងសហព័ន្ធសហជីពអ្នកធ្វើការតាមផ្ទះអាស៊ីហុងកុង (**FADWU**), តំបន់យូលូន (**Kowloon**) ទីក្រុងហុងកុង

***បរិយាយដោយ** Kamei Lau, **សហព័ន្ធសហជីពអ្នកធ្វើការតាមផ្ទះអាស៊ីហុងកុង** (FADWU)*




អ្នកស្រី Baby Jane allas និងថ្នាក់ដឹកនាំសហព័ន្ធសហជីពអ្នកធ្វើការតាមផ្ទះអាស៊ី (FADWU) បន្ទាប់ពីស្តាប់សវនាការតុលាការការងារ (Labour Tribunal) កាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១៩ (រូបថត: FADWU)

### អំពើរំលោភបំពាន

អ្នកស្រី **Baby Jane Allas** មានអាយុ ៣៨ឆ្នាំ គឺជាអ្នកធ្វើការតាមផ្ទះចំណាកស្រុកជនជាតិហ្វីលីពីន។ អ្នកស្រី **Baby Jane Allas** ត្រូវបានជួលឲ្យបានធ្វើការជាអ្នកធ្វើតាមផ្ទះដោយអ្នកស្រី **Jamil** ចាប់ពីខែកញ្ញា ឆ្នាំ២០១៧ រហូតដល់ឆ្នាំ ២០១៩ នៅពេលអ្នកស្រីត្រូវបានគេបញ្ចេញចេញពីការងារ។ ភាពលំបាកខ្លាំងក្នុងគ្រួសារនយោជកខាងលើ ដោយអ្នកស្រី **Baby Jane** ត្រូវមើលថែទាំមនុស្សពេញវ័យ៥នាក់ និងឪពុករបស់អ្នកស្រី **Jamil** ដែលមានជំងឺរុំរ៉ៃ។ អ្នកស្រី **Baby Jane** មិនត្រូវបានផ្តល់ជូនកន្លែងស្នាក់នៅនិងម្ហូបអាហារបរិភោគត្រឹមត្រូវដែលមានកំណត់ក្នុងកុងត្រាការងារនោះឡើយ។ អ្នកស្រី បរិភោគតែអាហារសល់ នំប៊ីស្គីត និងគេងនៅលើគ្រែបត់ក្នុងបន្ទប់ដាក់សម្ភារៈនៅក្រោមជណ្តើរប៉ុណ្ណោះ។

អ្នកស្រី **Baby Jane** មិនដែលមានភាពរីករាយនឹងថ្ងៃសម្រាកពេញមួយថ្ងៃរៀងរាល់សប្តាហ៍នោះឡើយ ដោយសារអ្នកស្រីត្រូវបណ្តើរសត្វឆ្កែ សម្អាត និងបម្រើគ្រួសារនយោជកក្នុងថ្ងៃឈប់សម្រាក។ បើយោងតាមមាត្រាទី ២ និង ១៧ របស់ច្បាប់ការងារហុងកុង (**Hong Kong's Employment Ordinance**) អ្នកធ្វើការតាមផ្ទះទទួលបានថ្ងៃឈប់សម្រាកមួយថ្ងៃក្នុងមួយសប្តាហ៍ ដោយមួយថ្ងៃនេះមានន័យថាមានពេលឈប់សម្រាករយៈពេល២៤ម៉ោង។ ប៉ុន្តែ នយោជកជាច្រើនបំពានច្បាប់ ដោយពួកគេតែងតែឲ្យអ្នកធ្វើការតាមផ្ទះចំណាកស្រុករៀបចំម្ហូបអាហារពេលព្រឹកនាថ្ងៃអាទិត្យ និងថ្ងៃផ្សេងទៀតមុនពួកគេចាកចេញទៅក្រៅ។ លើសពីនេះ ពួកគេឲ្យអ្នកធ្វើការតាមផ្ទះទាំងនោះមកដល់ផ្ទះរបស់ពួកគេនៅម៉ោង ៦ ឬ៧ល្ងាចដើម្បីសម្អាតទីធ្លារផ្ទះ។

កាលពីខែមករា ឆ្នាំ២០១៩ អ្នកស្រី Baby Jane បានធ្វើការប្រឹក្សាជាមួយវេជ្ជបណ្ឌិតបន្ទាប់ពីអ្នកស្រីមានអារម្មណ៍មិនស្រួលខ្លួន។ Baby Jane ត្រូវបានរកឃើញថាមានជំងឺមហារីកដំណាក់កាលទី៣។ វេជ្ជបណ្ឌិតបានចេញនូវលិខិតបញ្ជាដែលអាចអនុញ្ញាតិឲ្យអ្នកស្រីមានពេលវេលាឈប់សម្រាកឈឺរយៈពេល៣សប្តាហ៍។ ប៉ុន្តែក្រោយពីនយោជករបស់អ្នកស្រីដឹងរឿងនេះ អ្នកស្រីត្រូវបានបញ្ចេញចេញពីការងារនិងចេញលិខិតបញ្ចប់ការងារដោយសរសេរច្បាស់ៗថា «មហារីកមាត់ស្បូន»។

ការបាត់បង់ការងារមានន័យថាអ្នកស្រី Baby Jane បាត់បង់សិទ្ធិទាំងអស់ដែលទទួលបានក្នុងនាមជាអ្នកធ្វើការតាមផ្ទះហ្វីលីពីន ក្នុងទីក្រុងហុងកុង។ ទីមួយ អ្នកស្រីត្រូវទាមទារសិទ្ធិទទួលបានថ្ងៃឈប់សម្រាប់ឈឺដែលមានចែងក្នុងច្បាប់ការងារមាត្រា ៣៣ ជំពូក៥៧ (Employment Ordinance) (S.33, Ch.57)។ ទីពីរ អ្នកស្រីត្រូវបាត់បងសិទ្ធិទទួលការផ្តល់ជូនឥតគិតថ្លៃការព្យាបាលក្នុងពេលធ្វើការដែលមានចែងក្នុងកិច្ចសន្យាស្តង់ដារអ្នកធ្វើការតាមផ្ទះខ៩ លេខ៤០៧ (clause 9, ID 407)។ កិច្ចសន្យានេះតម្រូវឲ្យនយោជកផ្តល់ជូនការព្យាបាលដោយឥតគិតថ្លៃទៅដល់នយោជិក និងទិញធានារ៉ាប់រងការព្យាបាលជូនពួកគេ។

ការបណ្តេញពីការងារដោយមិនសមស្របនេះធ្វើឲ្យមានផលអវិជ្ជមានកាន់តែច្រើន។ អ្នកធ្វើការតាមផ្ទះដែលមានវីសា (Visa) ការងារមានសុពលភាពនិងកិច្ចសន្យាការងារ និងទទួលបានអត្តសញ្ញាណប័ណ្ណហុងកុង ប៉ុន្តែអត្តសញ្ញាណប័ណ្ណហុងកុងអស់សុពលភាពក្នុងរយៈពេល ២សប្តាហ៍បន្ទាប់ពីការបញ្ឈប់ពីការងារ។ ដូចនេះ អ្នកស្រី Baby Jane ត្រូវបាត់បង់ការងារ និងភាពជាពលរដ្ឋហុងកុងអស់ក្នុងរយៈពេល២សប្តាហ៍ក្រោយការបណ្តេញចេញពីការងារ។

## វិធានការចំពោះអំពើរំលោភបំពាន

អ្នកស្រី **Baby Jane** បានដាក់ពាក្យបណ្តឹងនយោជករបស់អ្នកស្រី ដែលធ្វើឲ្យអ្នកស្រីទទួលបានសិទ្ធិជាអ្នកទស្សនៈកិច្ចហុងកុងពីនាយកដ្ឋានអន្តោប្រវេសន៍ហុងកុង។ ការទទួលបានសិទ្ធិមួយនេះអនុញ្ញាតិឲ្យអ្នកស្រី អាចស្នាក់នៅទីក្រុងហុងកុងដើម្បីបន្តការប្តឹងផ្តល់ជាមួយនយោជករបស់អ្នកស្រីបាន។ ប៉ុន្តែ ដោយសារតែមានសិទ្ធិត្រឹមតែជាអ្នកទស្សនៈកិច្ច អ្នកស្រី **Baby Jane** មិនអាចទទួលបានសេវាសុខភាពសាធារណៈ និងអាចធ្វើការដើម្បីរកកម្រៃបានឡើយ។

អ្នកស្រី **Baby Jane** បានស្នើឲ្យប្អូនស្រីរបស់ខ្លួនគឺនាង **Mary Anne** ដែលជាអ្នកធ្វើការតាមផ្ទះក្នុងទីក្រុងហុងកុងឲ្យជួយអ្នកស្រី។ ដោយមានការជួយពីនាង **Mary Anne** និងនយោជករបស់នាងគឺអ្នកស្រី **Jessica** ផងនោះ អ្នកស្រី **Baby Jane** បានចាកចេញពីផ្ទះរបស់អ្នកស្រី **Jamil** ហើយទៅរស់នៅជាមួយប្អូនស្រីក្នុងផ្ទះរបស់អ្នកស្រី **Jessica**។ អ្នកស្រី **Jessica** បានជួយដោយពេញទំហឹងដោយបានអនុញ្ញាតិឲ្យអ្នកស្រីស្នាក់នៅ និងការហូបចុក និងថែមទាំងបានជួយរៃអង្គាសប្រាក់តាមរយៈយុទ្ធនាការណ៍បរិច្ចាគដើម្បីយកថវិការទៅព្យាបាលជំងឺរបស់ **Baby Jane** ផងដែរ។

## យុទ្ធសាស្ត្ររបស់ DWO និងវិធានការអនុវត្ត

ដោយមានការជួយទំនុកបំរុងពីសំណាក់នយោជករបស់ប្អូនស្រីខ្លួនគឺអ្នកស្រី Jessica និងសហព័ន្ធសហជីពអ្នកធ្វើការតាមផ្ទះអាស៊ី (FADWU) ផងនោះ អ្នកស្រី Baby Jane បានដាក់ពាក្យបណ្តឹងចំនួន២ផ្សេងគ្នា។ ទី១ ទាមទារអំពីការបញ្ឈប់ការងារដែលមិនស្របតាមច្បាប់ក្រោមបទបញ្ញត្តិការងារ (Employment Ordinance) និងទី២ បណ្តឹងពីការរើសអើងការងារ ក្រោមបទបញ្ញត្តិរើសអើងជនពិការជំពូក ៤៨៧ (Ch. 487) (Disability Discrimination Ordinance)។ ពាក្យបណ្តឹងទី១ត្រូវបានដាក់ស្នើទៅកាន់នាយកដ្ឋានការងារ (Labour Department) និងពាក្យបណ្តឹងទី២ត្រូវបានដាក់ជូន គណៈកម្មការឱកាសស្មើភាពគ្នា EOC (Equal Opportunities Commission)។

នៅពេលទទួលបានពាក្យបណ្តឹងពីដើមបណ្តឹង នាយកដ្ឋានការងារ (Labour Department) បានរៀបចំកិច្ចប្រជុំលុបកិច្ចសន្យារវាងភាគីនយោជក និងភាគីនយោជិតដើម្បីរកចំណុចស្របគ្នាដើម្បីឈានដល់ការលុបកិច្ចសន្យាដោយសន្តិវិធី។ អ្នកស្រ្តី Jamil អតីតនយោជករបស់អ្នកស្រ្តី Baby Jane មិនបានបង្ហាញមុខក្នុងការប្រជុំនោះឡើយ ដោយអ្នកស្រ្តីនិយាយថាអ្នកស្រ្តីមិនស្រួលខ្លួន ហើយអ្នកស្រ្តីបានឲ្យមេធាវីតំណាងពីររូបចូលរួម ខណៈដែលអ្នកស្រ្តី Baby Jane ដែលកំពុងមានជំងឺមហារីកធ្ងន់ធ្ងរចូលខ្លួនមកដោះស្រាយទៅវិញ។ ដោយសារតែមានភាសាដើមជាភាសា Tagalog ដូចនេះ Baby Jane មិនសូវចេះភាសាអង់គ្លេសនោះទេ ហើយអ្នកស្រ្តីគួរទទួលបានជំនួយអ្នកបកប្រែដូចបានចែងក្នុង គោលការណ៍ណែនាំរដ្ឋបាលស្តីពីការលើកកម្ពស់សមភាពពូជសាសន៍ (Administrative Guidelines on Promotion of Racial Equality) នៃការិយាល័យកិច្ចការដីគោកនិងរដ្ឋធម្មនុញ្ញ (Constitutional and Mainland Affairs Bureau) ក្រោមគោលការណ៍ បទបញ្ញត្តិរើសអើងពូជសាសន៍ (ជំពូក ៦០២) (Race Discrimination Ordinance (Cap. 602))។ ប៉ុន្តែ មិនមានការជួយសម្រួលណាមួយផ្នែកបកប្រែនោះឡើយ ដូចនេះវាពិតជាមានភាពពិបាកខ្លាំងសម្រាប់ Baby Jane ក្នុងការស្វែងយល់លម្អិតនៃការប្រជុំដែលធ្វើឡើងជាភាសាអង់គ្លេសនោះ។ ទោះបីជាយ៉ាងណាក៏ដោយ ភាពគួរឲ្យរីករាយនោះគឺអ្នកស្រ្តី Baby Jane បានការពារករណីបណ្តឹងនោះបានជោគជ័យ។

ដោយសារតែការដោះស្រាយនេះមិនអាចឈានដល់ដល់សេចក្តីសម្រេចក្នុងកិច្ចប្រជុំរំលាយកិច្ចសន្យា ករណីបណ្តឹងនេះត្រូវបានបញ្ជូនទៅកាន់ តុលាការការងារ (Labour Tribunal)។ នៅពេលនេះអ្នកស្រី Baby Jane ទទួលបានសេវាកម្មបកប្រែក្នុងតុលាការ។ អ្នកស្រី Baby Jane បានផ្តល់សិទ្ធិទៅអ្នកតំណាងរបស់ សហព័ន្ធសហជីពអ្នកធ្វើការតាមផ្ទះអាស៊ី (FADWU) អ្នកស្រី Shiella Estrada ដែលមានតួនាទីជាប្រធានសហជីពការងាររីកចម្រើនរបស់អ្នកធ្វើការតាមផ្ទះក្នុងទីក្រុងហុងកុង (Progressive Labor Union of Domestic Workers in Hong Kong (PLU)) ដើម្បីធ្វើជាអ្នកតំណាងសហជីពរបស់អ្នកស្រ្តី ក្នុងការស្តាប់សវនាការក្នុងតុលាការការងារ (Labour Tribunal)។ ប៉ុន្តែ បើទោះបីជាអ្នកស្រី Shiiella Estrada បានដាក់ស្នើឯកសារធ្វើជាអ្នកតំណាងសហជីពរបស់នាងក្តី មន្ត្រីតំណាងប្រធានបានបដិសេធក្នុងការកោះហៅអ្នកស្រីក្នុងការស្តាប់សវនាការ។ ជំនួសមកវិញ អ្នកស្រី Baby Jane ត្រូវបានសួរសំនួរដោយអវត្តមានអ្នកតំណាងសហជីពរបស់នាងទៅវិញ។ មន្ត្រីតំណាងប្រធានខាងលើបានជំរុញរហូតទាល់តែអ្នកស្រ្តី Baby Jane ព្រមទទួលសំណងជាទឹកប្រាក់ ៣០ ០០០ដុល្លារហុងកុង (ស្មើនឹងប្រមាណ ៣ ៨៤៦ដុល្លារអាមេរិក) ពីនយោជករបស់អ្នកស្រ្តី ដែលនេះផ្ទុយពីការទាមទារពីដំបូងក្នុងទឹកប្រាក់ ៤៧ ០០០ដុល្លារហុងកុង។

## បញ្ហាប្រឈមនិងវិធានការអនុវត្ត

អ្នកធ្វើការតាមផ្ទះក្នុងទីក្រុងហុងកុងសុទ្ធតែមានការការពារដោយច្បាប់។ ការរំលោភសេពសន្ថវៈនិងបៀតបៀនរាងកាយមានចែងក្នុងច្បាប់ព្រហ្មទណ្ឌ ហើយការងាររបស់អ្នកធ្វើការតាមផ្ទះគឺត្រូវបានចែងក្នុងច្បាប់អន្តោប្រវេសន៍និងច្បាប់ការងារ។





ក្នុងទីក្រុងហុង បទបញ្ញត្តិការងារឆ្នាំ១៩៦៨ (Employment Ordinance of 1968) ចែងក្នុងជំពូក ៥៧ សម្រាប់អ្នកធ្វើការតាមផ្ទះ និងកិច្ចសន្យាស្តង់ដារការងារ (Standard Contract for the Employment) អ្នកធ្វើការតាមផ្ទះចំណាកស្រុកលេខ ៤០៧ (ID407) ត្រូវតែមានការបំពេញនិងចុះហត្ថលេខាដោយភាគីអ្នកធ្វើការតាមផ្ទះនិងភាគីនយោជក។ បទបញ្ញត្តិជាក់លាក់មួយចំនួនទៀតក៏ត្រូវបានអនុម័តផងដែរដូចជា ការរើសអើងភេទ ពូជសាសន៍ ពិការភាព និងស្ថានភាពគ្រួសារជាដើម។ ក្នុងគោលការច្បាប់នីមួយៗ ច្បាប់ប្រតិបត្តិត្រូវបានដាក់ចេញដើម្បីជួយសម្រួលដល់ការអនុវត្តនៃច្បាប់ទាំងនេះ។

បើទោះបីជាយ៉ាងណានោះ ក្នុងទីក្រុងហុងកុង សិទ្ធិការងាររបស់អ្នកធ្វើការតាមផ្ទះចំណាកស្រុកដែលនឹងទទួលបាន កំពុងមានការផ្លាស់ប្តូរដោយការរឹតបណ្តឹងទៅលើអ្នកធ្វើការតាមផ្ទះអន្តោប្រវេសន៍ ដូចជា «ច្បាប់ពីរសប្តាហ៍» (two-week rule) ដែលច្បាប់នេះអនុញ្ញាតិឲ្យអ្នកធ្វើការតាមផ្ទះអាចស្នាក់នៅបានតែរយៈពេល២សប្តាហ៍ក្រោយបញ្ចប់កុងត្រាការងារជាមួយនយោជកប៉ុណ្ណោះ។ នយោជករបស់អ្នកស្រី Baby Jane បានធ្វើការបណ្តេញអ្នកស្រ្តីចេញដោយអយុត្តិធម៌ដោយសារតែអ្នកស្រី Baby Jane មានជំងឺមហារីក។ ដូច្នេះហើយ អ្នកស្រីមិនអាចទទួលបានសេវាថែរក្សាសុខភាពសាធារណៈ បើទោះបីអ្នកស្រីកំពុងស្នាក់នៅក្នុងហុងកុងដើម្បីបន្តពាក្យបណ្តឹងទាមទារយុត្តិធម៌ក្តី។ លើសពីនេះ អ្នកស្រ្តី Baby Jane មិនត្រូវបានអនុញ្ញាតិឲ្យស្វែងរកការងារធ្វើដើម្បីរកកម្រៃនោះទេ។ អ្នកស្រ្តី Baby Jane អាចស្នាក់នៅទីក្រុងហុងកុងបាន នេះក៏ព្រោះតែមានការជួយពីប្អូនស្រី និងនយោជករបស់នាង ដែលបានជួយជាថវិការដើម្បីស្វែងរកមន្ទីពេទ្យឯកជនដើម្បីព្យាបាលជំងឺ។

ដំណើរការនៃការដោះស្រាយទំនាស់ដែលស្ថិតក្រុម បទបញ្ញត្តិការងារ (Employment Ordinance) ត្រូវបានចាប់ផ្តើម បន្ទាប់ពីអ្នកស្រី Baby Jane បានដាក់ពាក្យបណ្តឹង ប៉ុន្តែត្រូវបានអនុវត្តដោយបញ្ហាកើតឡើង។ ដំបូងក្នុងកិច្ចប្រជុំបញ្ចប់កិច្ចសន្យាជាមួយភាគីនយោជក អ្នកស្រី Baby Jane មិនត្រូវទទួលបានសេវាបកប្រែសម្រួល ហើយក្នុងតុលាការងារងារ (Labour Tribunal) ទៀតសោត មន្ត្រីតំណាងប្រធានមិនទទួលយកអ្នកតំណាងសហជីពរបស់អ្នកស្រ្តី Baby Jane និងមិនអនុញ្ញាតិឲ្យតំណាងនោះចូលស្តាប់សវនាការនោះឡើយ ហើយបែរជាដាក់គំនាបឲ្យអ្នកស្រី Baby Jane យល់ព្រមទទួលយកការដោះស្រាយដោយទឹកប្រាក់ដែលមានចំនួនតិចជាង

ការទាមទារទៅវិញ។

ករណីរឿងរបស់អ្នកស្រី Baby Jane បង្ហាញយ៉ាងច្បាស់ថាវាពិតជាមានចន្លោះប្រហោងធំក្នុងផ្លូវច្បាប់ក្នុងទីក្រុងហុងកុង ពាក់ព័ន្ធនឹងការការពារអ្នកធ្វើការតាមផ្ទះចំណាកស្រុកនៅពេលពួកគេធ្លាក់ខ្លួនឈឺ។ សម្រាប់សហព័ន្ធសហជីពអ្នកធ្វើការតាមផ្ទះអាស៊ី (FADWU) បញ្ហាអាទិភាពដែលត្រូវដោះស្រាយជាបន្ទាន់មានដូចខាងក្រោម៖

- ការលុបចោលច្បាប់២សប្តាហ៍ (two-week rule)
- ការផ្តល់សេវានិងការជួយគាំទ្រពីរដ្ឋាភិបាលក្នុងការអនុញ្ញាតិឲ្យអ្នកធ្វើការតាមផ្ទះអាចបន្តពាក្យបណ្តឹងរបស់ខ្លួនក្នុងតុលាការ
- ការទទួលបានសេវាសុខភាពសាធារណៈនិងការធានារ៉ាប់រងការព្យាបាលសម្រាប់អ្នកធ្វើការតាមផ្ទះដោយមិនត្រឹមតែក្នុងអំឡុងការធ្វើការនោះទេ ប៉ុន្តែថែមទាំងក្រោយការធ្វើការ ក្នុងករណីមានការបញ្ចប់កិច្ចសន្យាការងារមុនអណត្ត។

នៅពេលសរសេរសាច់រឿងនេះ អ្នកស្រី Baby Jane នៅបន្តដាក់ពាក្យបណ្តឹងករណីរបស់អ្នកស្រីទៅកាន់គណៈកម្មការឱកាសស្មើភាពគ្នា EOC (Equal Opportunities Commission) ក្រោមបទបញ្ញត្តិរើសអើងជនពិការ (Disability Discrimination Ordinance) ហើយកំពុងរង់ចាំស្តាប់សវនាការក្នុងតុលាការផងដែរ។ សហព័ន្ធសហជីពអ្នកធ្វើការតាមផ្ទះអាស៊ី (FADWU) បានធ្វើយុទ្ធនាការណ៍មួយក្នុងការជួយឲ្យអ្នកធ្វើការតាមផ្ទះអាចធ្វើការប្រើប្រាស់សេវាសុខភាពសាធារណៈនៅពេលនយោជកបញ្ឈប់ការងាររបស់ពួកគេដោយអយុត្តិធម៌ ដោយតាមរយៈការធ្វើសន្និសីទកាសែតដើម្បីបង្ហាញអំពីស្ថានភាពរបស់អ្នកស្រី Baby Jane និងកំពុងគៀងគរការជួយគាំទ្រលើយុទ្ធនាការណ៍មួយនេះបន្ថែម។ សកម្មភាពទាំងនេះទាក់ទាញចំណាប់អារម្មណ៍ពីបណ្តាញផ្សព្វផ្សាយព័ត៌មាននានាទាំងជាតិនិងអន្តរជាតិ។ សវនាការមួយត្រូវបានធ្វើឡើងនៅក្នុងកិច្ចពិភាក្សាតុមូលស្តីអំពីអំណាចកម្លាំងពលកម្មនៃក្រុមប្រឹក្សានីតិបញ្ញត្តិ (Panel on Manpower of the Legislative Council) កាលពីពាក់កណ្តាលខែមេសា ឆ្នាំ២០១៩ កន្លងទៅ។ ចាប់តាំងពីពេលនោះមក យុទ្ធនាការណ៍របស់យើងមិនទាន់ទទួលបានលទ្ធផលនៅឡើយដោយសារតែបញ្ហាវឹកវរផ្ទនយោបាយក្នុងទីក្រុងហុងកុង។

ចូលទៅកាន់កិច្ចប្រជុំថ្ងៃទី១៦ មេសា ២០១៩ នៃណាចកម្លាំងពលកម្ម ក្រោមរបៀបវារៈទី៤ «ជំនួយអ្នកធ្វើការតាមផ្ទះបរទេសក្នុងការទទួលបានសេវាព្យាបាលសុខភាព» ក្នុងតំណភ្ជាប់នេះ៖

https://www.legco.gov.hk/yr18-19/english/panels/mp/agenda/mp20190416.htm

## ការវិភាគនិងការពិភាក្សា

### ការបៀតបៀននិងអំពើអំពើហិង្សាយេនឌ័រ

ការបៀតបៀននិងអំពើហិង្សាគឺជាអំពើរំលោភបំពានទៅលើឆន្ទៈរបស់បុគ្គលណាម្នាក់។ ករណីរឿងរ៉ាវទាំងអស់នេះបង្ហាញថាការបៀតបៀននិងអំពើហិង្សាគឺជាការបំពារបំពានដោយប្រើអំណាចទៅលើអ្នកធ្វើការតាមផ្ទះ។ ក្នុងរឿងរ៉ាវចំនួន ៦ក្នុងចំណោម ៨ករណី នយោជកម្នាក់ឬច្រើននាក់បានប្រព្រឹត្តិអំពើហិង្សានិងការបៀតបៀនទៅលើអ្នកធ្វើការតាមផ្ទះដែលជានយោជិករបស់ខ្លួន។ ក្នុងករណីប្រទេសហ្វីលីពីន ម្ចាស់ភ្នាក់ងារផ្តល់សេវាស្វែងការងារ បានបៀតបៀន Riza ហើយក្នុងប្រទេសកម្ពុជា ស្រីមុំ ត្រូវបានគ្រួសារដែលនាងរៀបការជាមួយធ្វើបាបរំលោភបំពាន ក្រោយធ្លាប់ធ្វើការជាអ្នកធ្វើការតាមផ្ទះជូនគ្រួសារខាងលើ។

ការបៀតបៀននិងអំពើហិង្សាក្នុងពិភពការងារបង្កឲ្យមានស្ថានភាពការងារដែលមិនល្អ មានការសម្លុត ការគំរាមកំហែង និងភាពអាម៉ាស់ទៅដល់ជនរងគ្រោះ និងថែមទាំងធ្វើឲ្យរារាំងសុខុមាលភាព និងទំនាក់ទំនងការងារល្អក់កករថែមទៀតផង។ ការគំរាមកំហែងនៃអំពើហិង្សានិងការបៀតបៀនក៏ចាត់ទុកថាជាអំពើហិង្សាផងដែរ។ ការគំរាមកំហែងផ្សេងៗដូចជាការគំរាមហែកកេរ្តិ៍ ឬដែលគេហៅថាអំពើហិង្សារនិងការបៀតបៀន "quid pro quo" មានន័យថា «ការធ្វើអ្វីមួយដើម្បីជាថ្នូរនឹងបានអ្វីមួយ»។ អំពើបែបនេះកើតឡើងនៅពេលនយោជកឬបុគ្គលណាម្នាក់ដែលមានអំណាចទាមទារការផ្តល់សេវាកម្មបន្ថែមពីអ្នកធ្វើការតាមផ្ទះជាថ្នូរឲ្យអាចបន្តធ្វើការងារបន្តបាន។ អំពើនេះបង្ខំឲ្យអ្នកធ្វើការតាមផ្ទះជ្រើសរើសរវាងការផ្តល់ជូនទៅដល់ការទាមទារដែលគ្មានហេតុផល ឬបាត់បង់ការងារឬផលប្រយោជន៍ការងារនោះ។

អនុសញ្ញាអន្តរជាតិអាយឡូ (ILO) លេខ 190 បានឲ្យនិយមន័យនៃ «ការបៀតបៀននិងអំពើហិង្សាក្នុងការងារ» ថាជា «អាកប្បកិរិយានិងការអនុវត្តមិនសមរម្យនានា ឬការគំរាមកំហែងណាមួយ មិនថាសកម្មភាពនោះកើតឡើងម្តងឬកើតឡើងដដែល ថា៖

- មានគោលបំណង ឬបង្ករជា ឬបង្កើតជាផលប៉ះពាល់មិនល្អដល់រូបរាងកាយ ផ្លូវចិត្ត ផ្លូវភេទ ឬផ្នែកហិរញ្ញវត្ថុ
- និងរួមទាំងការបៀតបៀននិងអំពើហិង្សាយេនឌ័រ ក្នុងមាត្រា១»។

**ការបៀតបៀននិងអំពើហិង្សាផ្លូវកាយ** គឺជាអំពីប៉ះពាល់នានាទៅដល់រូបរាងកាយរបស់បុគ្គលម្នាក់។ ករណីសាច់រឿងរបស់អ្នកធ្វើការតាមផ្ទះដែលត្រូវបានធ្វើឃាត វាយដំ ដាល់ ដុត ឬរុញច្រានទម្លាក់ពីលើជណ្តើរជាដើម។ ការបង្អត់អាហារ ដូចកើតឡើងក្នុងករណីរឿងក្នុងប្រទេសឥណ្ឌា ឥណ្ឌូនេស៊ី ហ្វីលីពីន និងគុយវ៉ែត ការបង្ខិតបង្ខំឲ្យបរិភោគលាមកសត្វឆ្មា ឬបរិភោគសាប៊ូដើម្បីជាការដាក់ទោស ឬការកោរសក់និងការធ្វើឲ្យមានស្លាកស្នាមលើស្បែកក្បាលនិងការចាក់ទឹកខ្មេះជាដើម គឺសុទ្ធតែទម្រង់ផ្សេងៗនៃអំពើហិង្សាផ្នែករាយកាយដែលបង្កឲ្យក្លាយទៅជាការធ្វើទារុណកម្ម និងជាការគំរាមកំហែងដែលគ្រោះថ្នាក់ដល់អាយុជីវិតបុគ្គល។ អ្នកស្រី Baby Jane ក្នុងទីក្រុងហុងកុង ត្រូវបោះបង់សិទ្ធិទទួលបានការព្យាបាលជំងឺមហារីកមាត់ស្បូន ដោយសារតែនយោជករបស់អ្នក

 ស្រីបានបណ្តេញចេញពីការងារនៅពេលនយោជករូបនោះបានដឹងពីជំងឺរបស់អ្នកស្រី។

ការបៀតបៀននិងអំពើហិង្សាផ្លូវកាយគឺជាទិដ្ឋភាពចិត្តសាស្រ្ត ពីព្រោះទង្វើបែបនេះគឺជាការធ្វើឲ្យមានភាពអាម៉ាស់ បាក់មុខយ៉ាងខ្លាំង។ អំពើហិង្សារផ្លូវកាយអាចជាការបៀតបៀនគេរគេទដូចក្នុងករណីចាប់រំលោភ ឬការប្រព្រឹត្តផ្សេងៗទៀតពាក់ព័ន្ធនឹងផ្លូវភេទ។ ការមិនអនុញ្ញាតិឲ្យអ្នកធ្វើការតាមផ្ទះគេងឬសម្រាក ដោយបង្ខំឲ្យធ្វើការច្រើនម៉ោងដោយមិនមានពេលសម្រាកគ្រប់គ្រាន់ ឬការមិនផ្តល់ជូននូវទីកន្លែងសម្រាកសមរម្យក៏ស្ថិតក្នុងទម្រង់ជាការបៀតបៀន និងអំពើហិង្សាផ្លូវកាយ និងផ្លូវចិត្តផងដែរ។

**ការបៀតបៀននិងអំពើហិង្សាផ្លូវចិត្ត**គឺទង្វើទាំងឡាយណាដែលប៉ះពាល់ដល់ផ្លូវចិត្តនិងព្រលឹងវិញ្ញាណតាមរយៈការបំភិតបំភ័យ ការសម្លុតគំរាម ការសម្លឹង ការគំរាមកំហែង និងការបំពារបំពានដោយពាក្យស្តីណាមួយ ដោយរាប់បញ្ចូលទាំងការសន្យាខ្យល់ផងដែរ។ ឧទាហរណ៍ នៅពេលនាង Murni ដែលមានអាយុ១២ឆ្នាំនិងគ្រួសាររបស់នាងក្នុងប្រទេសឥណ្ឌូនាស៊ីត្រូវបាននយោជកសន្យាថានឹងធ្វើការទូទាត់រ៉ាប់រងការចំណាយលើការអប់រំដើម្បីសិក្សារៀនសូត្របន្ត។

ឧទាហរណ៍នៃកង្វះនៃឯកជនភាព នៅពេលអ្នកធ្វើការតាមផ្ទះស្នាក់នៅក្នុងផ្ទះនយោជកគ្មានសិទ្ធិបិទទ្វារបន្ទប់របស់ខ្លួន ឬនៅពេលត្រូវបង្ខំឲ្យគេងនៅក្នុងផ្ទះបាយ ក្រោមជណ្តើរ ឬគេងក្នុងបន្ទប់គេងរបស់អ្នកដទៃជាដើមគឺសុទ្ធតែជាទម្រង់នៃការបៀតបៀតផ្លូវចិត្ត។ ការនៅដាច់ដោយឡែកក្នុងទម្រង់ជាការហាមឃាត់អ្នកធ្វើការតាមផ្ទះមិនឲ្យចាកចេញពីផ្ទះ ឬការរារាំងមិនឲ្យពួកគេអាចទំនាក់ទំនងទៅកាន់គ្រួសារឬមិត្តភក្តិ ដូចនឹងករណីរឿងក្នុងប្រទេសឥណ្ឌូនេស៊ីមានផលប៉ះពាល់ជាអវិជ្ជមានដល់សុខុមាលភាពរបស់នយោជិក។

ករណីសាច់រឿងរបស់អ្នកស្រី Maria ក្នុងប្រទេសគុយវ៉ែត បង្ហាញឲ្យឃើញអំពីអត្តចរិតនៃការរំលោភបំពាននៃអំពើហិង្សារផ្លូវចិត្ត។ ទី១៖ ដោយមានគោលបំណងបំភិតបំភ័យអ្នកស្ត្រី Maria នយោជករបស់អ្នកស្រីបានកុហក់បោកប្រាស់ក្នុងពេលធ្វើការសម្ភាសការងារថាខ្លួនគឺជាមន្ត្រីប៉ូលិសម្នាក់ដែលមានអំណាច។ ទី២៖ នយោជករូបនោះបានចោទប្រកាន់អ្នកស្រី Maria អំពីបទរំលោភបំពានផ្លូវភេទទៅលើកូនស្រីរបស់ខ្លួន (ក្មេងស្រីដែលអ្នកស្រី Maria ជាអ្នកមើលថែទាំ) ដោយសារតែអ្នកស្រី Maria មានរូបថតកូនស្រីម្នាក់នោះក្នុងកាបូបដៃរបស់អ្នកស្រី។ ទី៣៖ នយោជករូបនេះបានបង្ខំអ្នកស្រី Maria ឲ្យសារភាពនៅចំពោះមុខវីដេអូខ្លីបអំពីគោលបំណងអាក្រក់របស់ខ្លួន។ ដោយមានវីដេអូនោះក្នុងដៃ នយោជករូបនោះបានគំរាមអ្នកស្រី Marai ថាខ្លួននឹងដាក់ពាក្យបណ្តឹងលើអំពើបំពាននិងអំពើហិង្សានោះ។

**ការបៀតបៀននិងអំពើហិង្សាផ្លូវភេទ** គឺជាទង្វើទាំងឡាយណាដែលពាក់ព័ន្ធនឹងផ្លូវភេទដែលប្រព្រឹត្តិឡើងដោយរំលោភលើឆន្ទៈរបស់បុគ្គលណាម្នាក់។ អំពើទាំងនោះគឺជាការបង្ខិតបង្ខំបុគ្គលម្នាក់ឲ្យឆ្លងកាត់ឬប្រព្រឹត្តិអំពើផ្លូវភេទដោយរំលោភលើឆន្ទៈរបស់បុគ្គលនោះ។ អ្នកធ្វើការតាមផ្ទះដែលស្នាក់នៅក្នុងផ្ទះនយោជកមានការប្រឈមនឹងហានិភ័យខ្ពស់នៃការបៀតបៀននិងអំពើហិង្សាផ្លូវភេទ ពីព្រោះតែពួកគេធ្វើការនិងរស់នៅជិតស្និទ្ធនឹងនយោជកនិងសមាជិកគ្រួសារដទៃទៀតទាំងថ្ងៃនិងយប់។ ជនរងគ្រោះជាច្រើននាក់ក្នុងការរំលោភនិងការបៀតបៀនផ្លូវភេទគឺជាក្មេងស្រីនិងស្ត្រីគ្រប់វ័យ។ ក្មេងប្រុស និងមានបុរសខ្លះដែរក៏អាចក្លាយជាជនរងគ្រោះការបៀតបៀន

និងអំពើហិង្សាផ្លូវភេទ។ ជនដែលប្រព្រឹត្តអំពើហិង្សាផ្លូវភេទទៅលើអ្នកធ្វើការតាមផ្ទះភាគច្រើនគឺជាបុរស និងនយោជក។ ករណីសាច់រឿងចំនួនបីក្នុងប្រទេសឥណ្ឌា និងឥណ្ឌូនេស៊ីគឺជាឧទាហរណ៍មួយចំនួននៃការរំលោភបូក។ ក្នុងប្រទេសឥណ្ឌា កុមារី Sabina មានអាយុ១៤ឆ្នាំ ត្រូវបានបុរសនយោជកនិងអ្នកធ្វើការតាមផ្ទះបុរសម្នាក់ទៀត ដែលជាអ្នកបើកបរឲ្យគ្រួសារនយោជកនោះ ចាប់រំលោភនិងសម្លាប់ចោល។

ករណីសិក្សាទាំងពីរផ្សេងទៀតបានបង្ហាញថាស្ត្រីដែលជាប្រពន្ធឬម្ដាយដែលជិតស្និទជាមួយបុរស ជាញឹកញាប់រួមគំនិតជាមួយបុរសនិងឃុបឃិតគ្នាប្រព្រិត្តិអំពើហិង្សារំលោភផ្លូវភេទលើអ្នកធ្វើការតាមផ្ទះ។ អ្នកនាង Sunita មកពីប្រទេសឥណ្ឌាត្រូវបានរំលោភបំពានផ្លូវភេទ និងត្រូវបានរំលោភជាបន្តបន្ទាប់ដោយបុរសនយោជក នៅពេលដែលប្រពន្ធរបស់នយោជកនោះមិននៅផ្ទះ។ អ្នកនាង Sunita បានរាយការណ៍រឿងរ៉ាវប្រាប់ស្ត្រីជាប្រពន្ធ ហើយត្រូវបុរសនយោជកវាយ និងធ្វើបាបដោយនយោកជនទាំងពីរនោះ។ ក្នុងប្រទេសឥណ្ឌូនេស៊ី ស្ត្រីនយោជកបានចោទប្រកាន់ អ្នកនាង Murni ថាមានចំណង់ផ្លូវភេទជាមួយបុរសជាប្តីរបស់ខ្លួន និងថាបានប្រើប្រាស់ចំណង់តណ្ហារបស់ខ្លួនដែលធ្វើឲ្យករណីអំពើហិង្សាផ្លូវភេទនេះកើនឡើង។ អ្នកស្រីនយោជកបានប្រើប្រាស់ការរំលោភជាវិធីសាស្ត្រក្នុងការបង្ខំស្ត្រីអ្នកធ្វើការតាមផ្ទះបុរសពីរនាក់ផ្សេងទៀតរបស់ខ្លួនរំលោភ Murni ដែលជាអ្នកធ្វើការតាមផ្ទះក្មេងជាងគេក្នុងគ្រួសារនោះ។

**ការបៀតបៀននិងអំពើហិង្សាផ្នែកសេដ្ឋកិច្ចឬហិរញ្ញវត្ថុ** កើតឡើងនៅពេលនយោជកមិនធ្វើការទូទាត់ឬទូទាត់ប្រាក់ឈ្នួលដែលចែងក្នុងអត្រាតិចតួចទៅដល់អ្នកធ្វើការតាមផ្ទះ ពន្យារការទូទាត់ប្រាក់ឈ្នួល ឬនៅពេលដែលពួកគេទាមទារឲ្យធ្វើការហួសកម្រិតឬធ្វើការលើសតួនាទីទូទៅ ដោយមិនមានសំណងសមរម្យ។ ទង្វើបែបនេះជាការគាបសង្កត់អ្នកធ្វើការតាមផ្ទះឲ្យស្ថិតក្រោមការគ្រប់គ្រងរបស់ពួកគេ និងជាការបង្ខំអ្នកពួកគេឲ្យធ្វើការបន្ថែមនិងធ្វើការកាន់តែខ្លាំង។

អ្នកធ្វើការតាមផ្ទះក្នុងករណីសាច់រឿងជាច្រើនធ្លាប់ប្រឈមនឹងការបៀតបៀននិងអំពើហិង្សាផ្នែកសេដ្ឋកិច្ច។ អ្នកស្រី Murni ក្នុងប្រទេសឥណ្ឌូនេស៊ី និងអ្នកនាង Sunita ក្នុងប្រទេសឥណ្ឌា មិនដែលទទួលបានការទូទាត់ប្រាក់ឈ្នួល ដោយធ្វើការដើម្បីតែមានជីវិតរស់នៅប៉ុណ្ណោះ។ អ្នកស្រី Maria ក្នុងប្រទេសគុយវ៉ែតមិនត្រូវបាននយោជកខ្លួនទូទាត់ប្រាក់ឈ្នួលពេញថ្លៃនោះឡើយ។ ចំណែកក្នុងប្រទេសបង់ក្លាដែស បើទោះបីអ្នកស្រី Anowara យល់ព្រមធ្វើការងារសម្អាតក្រៅម៉ោង នយោជករបស់អ្នកស្រីបានបង្ខំឲ្យអ្នកស្រីធ្វើការពេញម៉ោងដោយទូទាត់ប្រាក់ខែក្នុងការអត្រាប្រាក់ខែយល់ស្របការងារក្រៅម៉ោងទៅវិញ និងថែមទាំងបានដកប្រាក់ខែរយៈពេល៣ខែរបស់អ្នកស្រីទៀតផង។ អ្នកស្រី Maria ត្រូវបានបណ្តេញចេញពីការងារ និងអូសចេញពីផ្ទះដោយគ្មានការទូទាត់ប្រាក់ខែជូន ដោយសារតែអ្នកស្រីធ្វើបែកកែវទឹកមួយ។

ឧទាហរណ៍ទូទៅមួយទៀតនៃអំពើហិង្សាផ្នែកសេដ្ឋកិច្ចគឺនៅពេលភ្នាក់ងារស្វែងរកការងារធ្វើការទាមទារប្រាក់ឈ្នួលជើងសារហួសកម្រិតពីអ្នកធ្វើការតាមផ្ទះជាថ្នូរក្នុងការស្វែងរកការងារឲ្យធ្វើ។ ទង្វើបែបនេះបង្កឲ្យអ្នកធ្វើការតាមផ្ទះធ្លាក់ខ្លួនជាប់ជំពាក់បំណុលវ័ណ្ឌករ។ ការរំលោភផ្លូវភេទនិងផ្នែកសេដ្ឋកិច្ចជាញឹកញាប់កើតឡើងជាមួយគ្នាក្នុងទម្រង់នៃការគម្រាមផ្លូវភេទ។ ឧទាហរណ៍ នៅពេលនយោជកគំរាមបណ្តេញអ្នកធ្វើការតាមផ្ទះពីការងារ ឬធ្វើការដកយកប្រាក់ឈ្នួលឬម្ហូបអាហាររបស់នយោជិត ដើម្បីជាថ្នូរការផ្តល់ជូនសេវាផ្លូវភេទដល់ខ្លួន។

ការបៀតបៀននិងអំពើហិង្សាយេនឌ័រ ត្រូវបានឲ្យនិយមន័យដោយអនុសញ្ញា ILO លេខ ១៩០ (ILO Convention 190) ថា៖ «ការបៀតបៀនិងអំពើហិង្សាទៅលើបុគ្គលដោយសារតែភេទឬយេនឌ័រ ឬការប៉ះពាល់យេនឌ័ររបស់បុគ្គលម្នាក់ដោយអំពើមិនសមរម្យ និងរួមទាំងការបៀតបៀនផ្លូវភេទផងដែរ» (ក្នុងមាត្រាទី១)។ ការបៀតបៀននិងអំពើហិង្សាយេនឌ័រ ចាក់ឫសគល់ក្នុងទំនាក់ទំនងនៃ**អំណាចមិនស្មើភាពគ្នារវាងបុរសនិងស្ត្រី**ដែលកើតមានក្នុងសង្គមជាច្រើន។ ទំនាក់ទំនងនៃអំណាចមិនស្មើភាពគ្នាគឺមិនមានជាប់ពាក់ព័ន្ធទៅនឹងកត្តាខុសគ្នានៃជីវសាស្ត្រភេទបុរសនិងស្ត្រីនោះទេ ប៉ុន្តែ**វាកើតឡើងក្នុងតួនាទីយេនឌ័រក្នុងសង្គម ដែលដាក់បញ្ចូលក្នុងភេទទាំងពីរក្នុងជីវិតសង្គមនិងសេដ្ឋកិច្ច**។ ក្នុងប្រទេសជាច្រើន អ្នកធ្វើការតាមផ្ទះត្រូវបានមើលឃើញថាមានឋានៈតូចទាប ប្រាក់ឈ្នួលទាប ការងារជំនាញមិនសូវមានតម្រូវការ។ ដូច្នេះហើយ អ្នកធ្វើការតាមផ្ទះត្រូវបានផ្តល់តម្លៃទាប និងមិនត្រូវបានគេមើលឃើញ បើទោះបីជាពួកគេមានភាពសំខាន់មិនអាចខ្វះបានក្នុងគ្រួសាររបស់នយោជកក្តី។

**ទម្រង់ដទៃទៀតនៃការរើសអើង** អ្នកធ្វើការតាមផ្ទះជាច្រើនមកពីក្រុមមនុស្សដែលមានភាពអត់ខ្សោយតែងតែជួបការរើសអើង មិនត្រឹមតែដោយសារតែកត្តាភេទ និងយេនឌ័រនោះទេ ប៉ុន្តែមានកត្តាជាតិសាសន៍ ជនជាតិ ពណ៌សម្បុរ សាសនា សង្គម ប្រទេសជាតិ ឬកំណើតមកពីទីដាច់ស្រយាល ពិការភាព អាយុ ឋានៈជនអន្តោប្រវេសន៍ និន្នាការផ្លូវភេទ ( Sexual Orientation) ឬ អត្តសញ្ញាណយេនឌ័រ (Gender Identity) ជាដើម។ ឧទាហរណ៍ កត្តាជាច្រើននៃការរើសអើស នៅពេលអ្នកធ្វើការតាមផ្ទះត្រូវបានរើសអើសដោយសារគាត់ជាស្ត្រីជនជាតិភាគតិច ហានិភ័យនៃការបៀតបៀននិងអំពើហិង្សាកាន់តែអាក្រក់ឡើង។ ករណីសាច់រឿងបង្ហាញយ៉ាងច្បាស់។ អ្នកស្រី Sunita ក្នុងប្រទេសឥណ្ឌាមានដើមកំណើតមកពីក្រុមគ្រួសារកុលសម្ព័ន្ធ។ អ្នកស្រី Murni មកពីប្រទេសឥណ្ឌូនេស៊ីចាប់ផ្តើមធ្វើការនៅអាយុ១២ឆ្នាំ។ ទាំង Murni និង Riza គឺមកពីប្រទេសហ្វីលីពីន មានកំណើតមកពីទីជនបទដាច់ស្រយាល។ កុមារី Sabina មកពីប្រទេសឥណ្ឌាមានដើមកំណើតមកពីគ្រួសារជនអន្តោប្រវេសន៍ ហើយនៅអាយុ១៤ឆ្នាំ កុមារីនេះត្រូវបានគេរំលោភនិងសម្លាប់។ ចំណែកអ្នកស្រី Maria ធ្វើអន្តោប្រវេសន៍មកពីប្រទេសឥណ្ឌូនេស៊ីដើម្បីរកការងារធ្វើក្នុងប្រទេសគុយវ៉ែត និងអ្នកស្រី Baby ធ្វើអន្តោប្រវេសន៍មកពីប្រទេសឥណ្ឌូនេស៊ីដើម្បីរកការងារធ្វើក្នុងទីក្រុងហុងកុង។

អ្នកធ្វើការតាមផ្ទះជាច្រើនអ្នកដែលជាភេទទីបី អ្នកស្រលាញ់ភេទដូចគ្នា ឬអ្នកមានយេនឌ័រពីរ ក៏ស្ថិតក្នុងហានិភ័យខ្ពស់ក្នុងការធ្លាក់ខ្លួនក្លាយជាជនរងគ្រោះនៃការបៀតបៀននិងអំពើហិង្សាផងដែរ ដោយសារតែពួកគេមិនអាចសម្របតាមបទដ្ឋានសង្គមភេទផ្ទុយគ្នាបាន ប៉ុន្តែពួកគេមាននិន្នាការផ្លូវភេទ (Sexual Orientation) ឬអត្តសញ្ញាណយេនឌ័រ (Gender Identity) ផ្សេងគ្នា។

**ផលប៉ះពាល់នៃការបៀតបៀននិងអំពើហិង្សាលើអ្នកធ្វើការតាមផ្ទះ** ដោយសារតែទំនាក់ទំនងនៃអំណាចមិនស្មើគ្នាជាមួយនយោជក អ្នកធ្វើការតាមផ្ទះត្រូវបានគេគំរាមកំហែងឲ្យបង្ខំទទួលយក និងត្រូវសម្រុតគំរាបដោយការបំភិតបំភ័យបញ្ឈប់ពីការងារ។ អ្នកធ្វើការតាមផ្ទះភាគច្រើនរស់នៅធំធាត់ក្នុងសង្គមដែលពោរពេញដោយការរើសអើងនិងមានភាពលំអៀងយេនឌ័រ និងកង្វះការអប់រំ។ ការប្រឈមនឹងស្ថានភាពបែបនេះជាញឹកញាប់ធ្វើឲ្យបុគ្គលម្នាក់ខ្វះការស្រលាញ់ឲ្យតម្លៃខ្លួនឯង និងមិនហ៊ានតវ៉ានឹងបុគ្គលមានអំណាច។ អ្នកធ្វើការតាមផ្ទះត្រូវទទួលយកការបៀតបៀន និងអំពើហិង្សាដែលនេះគឺជារឿងពិតដែលកើតឡើងលើបុគ្គលជាច្រើននាក់រួចមកហើ

យ។ បើទោះបីជាយ៉ាងក៏ដោយ ដូចបានឃើញក្នុងករណីរឿងរ៉ាវជាច្រើន ការប្រឈមនឹងការបៀតបៀននិងអំពើហិង្សាអាចនឹងប៉ះពាល់ទៅដល់សុខភាពរាងកាយនិងផ្លូវចិត្ត បាត់បង់ភាពក្លាហាន ទំនុកចិត្តក្នុងខ្លួន និងរារាំងសុខុមាលភាពបុគ្គល និងអាចសម្លាប់ជីវិតបុគ្គលនោះថែមទៀតផង។

ករណីសាច់រឿងជាច្រើនបង្ហាញថាអ្នកធ្វើការតាមផ្ទះអាចនឹងទទួលរងការឈឺចាប់ដោយសារការបំពារបំពានធ្ងន់ធ្ងរក្នុងរយៈពេលច្រើនឆ្នាំដោយសារតែពួកគេមិនអាចឬមិនហ៊ានរត់គេចដើម្បីស្វែងរកយុត្តិធម៌។ ឧទាហរណ៍ករណីក្នុងប្រទេសឥណ្ឌា កុមារី Sabian ត្រូវបានគេរំលោភនិងសម្លាប់ចោល និងអ្នកនាង Sunita ត្រូវបានគេរំលោភនិងវាយធ្វើបាបយ៉ាងធ្ងន់ធ្ងរមុននឹងសម្រេចចិត្តហ៊ានរត់គេចខ្លួនចេញ។ អ្នកនាង Murni ក្នុងប្រទេសឥណ្ឌូនេស៊ីស្រកទម្ងន់សល់ត្រឹមតែ ២៥គីឡូក្រាមប៉ុណ្ណោះ នៅពេលអ្នកស្រីសម្រេចចិត្តព្យាយាមគេចខ្លួនពីផ្ទះរបស់នយោជក។ ចំណែក អ្នកស្រី Maria ក្នុងប្រទេសគុយវ៉ែតបាត់បង់ភាពក្លាហានក្នុងការប្រឆាំងតទល់នឹងការបំពារបំពាន និងការពារខ្លួនពីសំណាក់នយោជក។ ចុងក្រោយ អ្នកស្រី Maria បានត្រលប់មកស្រុកកំណើតក្នុងប្រទេសហ្វីលីពីនវិញ ប៉ុន្តែស្ថិតក្នុងសភាពភ័យខ្លាច និងតែងតែក្អួតចង្អោរនៅពេលធុំក្លិនសាប៊ូម្តងៗ។

ការរំលោភបំពាននិងកង្វះការការរកស្វែងរកយុត្តិធម៌ជូនជនរងគ្រោះអាចនឹងនាំឲ្យជនរងគ្រោះបាត់បង់ក្តីសង្ឃឹមមានជំងឺផ្លូវចិត្តនិងផ្លូវកាយ និងបាត់បង់ការងារធ្វើនិងប្រាក់ចំណូលថែមទៀតផង។ ក្នុងប្រទេសកម្ពុជា អ្នកស្រីស្រី មុំ បានធ្លាក់ខ្លួនឈឺបន្ទាប់ពីទទួលរងអំពើហិង្សាប្រព្រឹត្តិដោយគ្រួសារដែលនាងបានរៀបការជាមួយ។ ដូចគ្នានេះដែរ អ្នកនាង Riza ក្នុងប្រទេសហ្វីលីពីនត្រូវបានវាយដំបន្ទាប់ពីទទួលរងការបៀតបៀនដោយភ្នាក់ងារអ្នករកការងារធ្វើ។ អ្នកស្រីមិនចង់ដាក់ពាក្យបណ្តឹងនោះទេ ដោយសារអ្នកស្រីមានភាពភ័យខ្លាច។ អ្វីដែលអ្នកស្រីចង់បានគឺចង់ត្រលប់ទៅកាន់ស្រុកភូមិកំណើតវិញ។

- ប៉ុន្តែករណីសាច់រឿងជាច្រើនក៏បានបង្ហាញយ៉ាងច្បាស់ផងដែរអំពីអ្នកធ្វើការតាមផ្ទះដែលរងការរំលោភបំពានអាចមានការធូរស្បើយនិងអាចមានភាពរឹងមាំ រឹងពឹងឡើងវិញ ប្រសិនបើពួកគេទទួលបានការជួយអ្នកអង្គការអ្នកធ្វើការតាមផ្ទះ (DWOs)។
- ដោយមានជំនួយពី JALA PRT អ្នកនាង Murni មកពីប្រទេសឥណ្ឌូនេស៊ីបានត្រលប់ទៅសាលារៀនម្តងទៀតនិងបានបញ្ចប់ការសិក្សារបស់នាង។
- អ្នកនាង Sunita មកពីប្រទេសឥណ្ឌាត្រូវបានទទួលរងការបំពារបំពាន ប៉ុន្តែមិនចុះចាញ់ក្នុងការទាមទារយុត្តិធម៌។ ដោយមានជំនួយពី NDWM អ្នកនាងហ៊ានវាយយកយុត្តិធម៌យ៉ាងក្លាហាននិងរកបានការងារធ្វើជាអ្នកធ្វើការតាមផ្ទះថែមទៀត។ នាង Sunita បានបញ្ចប់ការសិក្សា និងក្លាយជាមេដឹកនាំអ្នកធ្វើការតាមផ្ទះដ៏ខ្លាំងមួយរូប។
- ក្នុងប្រទេសបង់ក្លាដែស អ្នកស្រី Anowara ដែលជាសមាជិករបស់ NDWUU បានទាក់ទងអ្នកដឹកនាំសាខារបស់ខ្លួន ហើយអ្នកដឹកនាំនោះដែលបានផ្តល់ដំណឹងទៅដល់សមាជិកអំពីស្ថានភាពរបស់អ្នកស្រី។ ពួកគេបានប្រមូលផ្តុំគ្នាស្វែងរកយុត្តិធម៌ ហើយសកម្មភាពក្រុមរបស់ពួកគេបានទទួលបានភាពជោគជ័យក្នុងការចរចាជាមួយនយោជក ដោយ Anowara ទទួលបានការបង់ប្រាក់ឈ្នួលទាំងអស់មកវិញ។

## ឧបសគ្គក្នុងការប្រឆាំងនឹងការបៀតបៀននិងអំពើហិង្សាយេនឌ័រ

គ្រប់ករណីរឿងរ៉ាវទាំងអស់ពណ៌នាអំពីការបៀតបៀននិងអំពើហិង្សាទៅលើស្ត្រីនិងកុមារីដែលមកពីក្រុមគ្រួសារដែលអន់ខ្សោយ មានជាប់ឬសគល់ក្នុងសង្គមនិងស្ថាប័នផ្សេងៗក្នុងសង្គមនោះ ដូចជាស្ថាប័នប៉ូលិស ភ្នាក់ងារអនុវត្តច្បាប់ និងតុលាការជាដើម។ **ការបៀតបៀននិងអំពើហិង្សា**លើអ្នកធ្វើការតាមផ្ទះគឺត្រូវបានគេមើលឃើញថាហាក់ដូចជាអំពើ **«ធម្មតា» «ជាផ្នែកនៃជីវិតរបស់យើង» ឬ«សឹងក្លាយជាផ្នែកមួយនៃវប្បធម៌ទៅហើយ»**។ អ្នកធ្វើការតាមផ្ទះមួយចំនួនខ្លួនគេត្រូវបានសង្គមសម្រប និងបានទទួលយកគំនិតនិងទស្សនៈបែបនេះ ប៉ុន្តែទស្សនៈបែបនេះហាក់ដូចធម្មតាក្នុងក្រសែភ្នែកនយោជកដែលប្រព្រឹត្តិអំពើបៀតបៀននិងអំពើហិង្សាដែលមិនត្រូវទទួលទោសទណ្ឌដោយច្បាប់។ ជាញឹកញាប់ មន្ត្រីដែលទទួលខុសត្រូវលើផ្នែកច្បាប់មានការការពារគំនិតនិងទស្សនៈខាងលើ និងទំនងជាមិនសូវអើពើនឹងតួនាទីរបស់ខ្លួនប្រសិនបើជនរងគ្រោះជាកុមារីនិងជាស្ត្រីដែលមកពីគ្រួសារដែលមានការរើសអើងឬគ្រួសារអន់ខ្សោយ។ ការកង្វះការគោរព ឲ្យតម្លៃលើអ្នកធ្វើការតាមផ្ទះក្នុងសហគមសង្គមទាំងមូល ក្នុងចំណោមនយោជក និងបណ្តាស្ថាប័ននានាដែលអនុវត្តច្បាប់និងការពារអ្នកធ្វើការតាមផ្ទះពីការបៀតបៀននិងអំពើហិង្សាគឺជាឧបសគ្គដែលគួរឲ្យខ្លាច។ **សម្រាប់ DWOs ការផ្លាស់ប្តូរគំនិតនិងទស្សនៈចាស់គម្រិលទាំងនេះគឺជាអាទិភាពសម្រាប់សកម្មភាពរបស់យើង។**

ករណីសាច់រឿងចំនួន៥ក្នុងចំណោមករណីចំនួន៨គឺសុទ្ធតែមានពាក់ព័ន្ធនឹងការបំពារបំពានផ្នែករាងកាយ ផ្លូវភេទ និងផ្លូវចិត្តរបស់អ្នកធ្វើការតាមផ្ទះ ដែលករណីទាំងនេះត្រូវមានការដាក់ទោសទណ្ឌដោយអនុលោមតាមក្រមព្រហ្មទណ្ឌ និងច្បាប់ការពារអនីតិជន ដូចក្នុងករណីក្នុងប្រទេសឥណ្ឌា និងច្បាប់ប្រឆាំងនឹងអំពើហិង្សាក្នុងគ្រួសារ ដូចក្នុងករណីក្នុងប្រទេសឥណ្ឌូនេស៊ីនិងប្រទេសកម្ពុជា។ ករណីរឿងរបស់អ្នកស្រី Murni និង JALA PRT (ឥណ្ឌូនេស៊ី) អ្នកនាង ស្រីមុំ និងសមាគមអ្នកធ្វើការតាមផ្ទះ ADW (ប្រទេសកម្ពុជា) និងកុមារី Sabina និង GKS និងករណីរបស់អ្នកនាង Sunita និង សហជីពស្ត្រីអ្នកធ្វើការតាមផ្ទះជាតិ (NDWM) (ប្រទេសឥណ្ឌា) បានបង្ហាញអំពីដំណើរការផ្លូវច្បាប់ដែលពិបាកនិងមានរយៈពេលយូរក្នុងការស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ និងការសូកប៉ាន់របស់មន្ត្រីប៉ូលិស និងតុលាការ ដោយនយោជកអាចរារាំងការអនុវត្តច្បាប់និងការដាក់ទោសជនល្មើសផងដែរ។ ក្នុងប្រទេសគុយវ៉ែត កិច្ចប្រឹងប្រែងរួមដោយមានសមាគមអ្នកធ្វើការតាមផ្ទះសាន់ឌីហ្គិន - គុយវ៉ែត (SKDWA) ប៉ូលិសគុយវ៉ែត និងស្ថានទូតហ្វីលីពីនផង បានធ្វើការជួយសង្គ្រោះអ្នកស្រី Maria និងជូនអ្នកស្រីទៅកាន់ប្រទេសកំណើតវិញ ប៉ុន្តែករណីរបស់អ្នកស្រីត្រូវបានព្យួរទុកនៅឡើយ។

ករណីរឿងរ៉ាវជាច្រើនបង្ហាញអំពី**តួនាទីដ៏សំខាន់របស់ DWOs ក្នុងការជួយគាំទ្រអ្នកធ្វើការតាមផ្ទះក្នុងទទួលបានយុត្តិធម៌។**

- សកម្មភាពដ៏មានប្រសិទ្ធភាពពីសំណាក់ប៉ូលិស ការគាំទ្ររបស់បុគ្គលទៅលើអ្នកនាង Murni និងការតស៊ូមតិដោយ Jala PRT និងមជ្ឈមណ្ឌលជំនួយផ្នែកច្បាប់ស្ត្រី បានជួយធ្វើឲ្យមានការកាត់ទោសនយោជករបស់ Murni ដាក់ពន្ធនាគារ។
- អ្នកនាង Sunita ក្នុងប្រទេសឥណ្ឌាទទួលបានប្រាក់សំណង ដោយមានជំនួយពី NDWM និងអ្នកស្រី Baby Jane ក្នុងទីក្រុងហុងកុង បានទទួលបានប្រាក់សំណងមួយចំនួន ដោយមានការជួយជ្រោមជ្រែងពី FADWU។

- សមាគមអ្នកធ្វើការតាមផ្ទះសាន់ឌីហ្គីន - គុយវ៉ែត (SKDWA) ក្នុងប្រទេសគុយវ៉ែតបានឆ្លើយតបទៅនឹងសាររបស់អ្នកស្រី Maria និងខិតខំព្យាយាមទំនាក់ទំនងអ្នកស្រីដើម្បីស្វែងរកស្នាមជាំនិងស្លាកស្នាមលើដងខ្លួន។ សកម្មភាពជាក្រុមពីសំណាក់មេដឹកនាំនិងសមាជិករបស់ Anowara និង NDWUU នាំឲ្យមានការទូទាត់ប្រាក់ឈ្នួលហួសកំណត់ទាំងអស់ជូន Marai។
- សកម្មភាពដោយការប្តេជ្ញាចិត្តពី GKS និងគ្រួសាររបស់កុមារី Sabina ក្នុងរយៈពេលជាង៥ឆ្នាំនាំឲ្យមានការរកែមុខនិងកំណត់អត្តសញ្ញាណជនល្មើសដែលបានរំលោភនិងសម្លាប់ Sabina បើទោះបីជាជនល្មើសទាំងនោះមិនទាន់ត្រូវបានដាក់ទោសនៅឡើយក្តី។

ករណីសាច់រឿងទាំងអស់នេះបង្ហាញយ៉ាងច្បាស់ថា**ច្បាប់ដែលមានចែងនិងយន្តការនៃការអនុវត្តច្បាប់មិនអាចសម្រេចដោយមានប្រសិទ្ធភាពក្នុងការជួយការពារជនរងគ្រោះអ្នកធ្វើការតាមផ្ទះ**រួចចេញពីការបំពាននិងអំពើហិង្សាឡើយ។ ក្នុងប្រទេសមួយចំនួនទៀតមានតែច្បាប់ ក្រមព្រហ្មទណ្ឌ ដែលអាចស្វែងរកមធ្យោបាយផ្លូវច្បាប់លើការរំលោភបំពានដូចជាការបំពារបំពានផ្លូវកាយនិងផ្លូវភេទ។

- ក្នុងប្រទេសកម្ពុជានិងឥណ្ឌូនេស៊ី ច្បាប់ប្រឆាំងនឹងអំពើហិង្សាគ្រួសារត្រូវបានអនុម័ត។ ប៉ុន្តែ ច្បាប់ក្នុងប្រទេសកម្ពុជាខ្វះយន្តការក្នុងការអនុវត្តនិងពេលវេលាជាក់លាក់។ ដូចនេះ ច្បាប់មិនអាចអនុវត្តបានល្អ។ ក្នុងប្រទេសឥណ្ឌូនេស៊ី អ្នកធ្វើការតាមផ្ទះភាគច្រើនត្រូវរាប់បញ្ចូលជាសមាជិកគ្រួសារដោយអនុលោមតាមច្បាប់។ ប៉ុន្តែ ច្បាប់នេះមិនមានប្រសិទ្ធភាពក្នុងការអនុវត្តដោយសារតែកង្វះការទទួលដឹងពីសាធារណៈជន និងភាពលំអៀងយេនឌ័ររបស់មន្ត្រីអនុវត្តច្បាប់ តុលាការ និងក្នុងសង្គមទាំងមូល។ ដូចនេះ Jala PRT និងអង្គការសិទ្ធិមនុស្ស កុមារ និងស្ត្រីមួយចំនួនចូលរួមក្នុងយុទ្ធនាការចំនួន២៖ ប្រឆាំងនឹងការបៀតបៀននិងអំពើហិង្សាយេនឌ័រក្នុងកន្លែងធ្វើការ និងការអភិវឌ្ឍនិងការអនុម័តច្បាប់ការពារអ្នកធ្វើការតាមផ្ទះ។
- ក្នុងប្រទេសឥណ្ឌា ច្បាប់ក្រមព្រហ្មទណ្ឌគឺត្រូវប្រើប្រាស់ដើម្បីផ្តល់នូវវិធានផ្លូវច្បាប់ក្នុងករណីមានការបំពានផ្លូវភេទនិងផ្លូវកាយ រួមទាំងអំពើឃាតកម្ម ជនរងគ្រោះអ្នកធ្វើការតាមផ្ទះផងដែរ។ ច្បាប់ពាក់ព័ន្ធនានាក៏ត្រូវបានអនុម័តដើម្បីការពារកុមារពីការបទល្មើសផ្លូវភេទ រារាំងពលកម្មកុមារ បង្ការនិងការពារការបៀតបៀនផ្លូវភេទលើស្ត្រីនៅកន្លែងធ្វើការ។ ច្បាប់ផ្សេងទៀតត្រូវបានដាក់ស្នើក្នុងករណី GKS និងគ្រួសាររបស់ Sabina ជាពិសេសពាក់ព័ន្ធនឹងសិទ្ធទទួលបានព័ត៌មាន ការទប់ស្កាត់អំពើពុករលួយ និងច្បាប់ធ្វើបត្យាប័ន (Extradition Act) ពីព្រោះជនល្មើសបានចាកចេញពីប្រទេស។ បើទោះបីជាយ៉ាងណាក៏ដោយ ដំណើរការផ្លូវច្បាប់ទាមទាររយៈពេលរាប់ឆ្នាំ និងតម្រូវការចំណាយប្រាក់កាក់និងពេលវេលាច្រើន ដូចក្នុងករណីរបស់ Sunita និងសហជីពស្ត្រីអ្នកធ្វើការតាមផ្ទះជាតិ (NDWWU)។ បន្ទាប់ពីអស់រយៈពេលជាច្រើនឆ្នាំ ក្រុមគ្រួសាររបស់ Sabina ចុងក្រោយបានសម្រេចទទួលយកសំណងតិចតួចមិនសមរម្យ។

ដូចក្នុងការអនុវត្ត ច្បាប់ក្នុងប្រទេសឥណ្ឌាមិនមានដំណើរការល្អនិងមានប្រសិទ្ធភាពក្នុងការជួយកាត់បន្ថយការបៀតបៀននិងអំពើហិង្សាលើស្ត្រីនិងកុមារអ្នកធ្វើការងារតាមផ្ទះ។ អង្គការ GKS និង DNWM កំពុងអំពាវនាវឲ្យមានវិធានការច្បាស់លាស់ក្នុងការពង្រឹងផ្នែកច្បាប់និងក្នុងការជំរុញឲ្យស្ថានប័ននានាជួយការពារស្ត្រីនិងកុមារអ្នកធ្វើការតាមផ្ទះកាន់តែប្រសើរ។ វិធានការទាំងនោះរួមមាន៖

ការបៀតបៀននិងអំពើហិង្សាយេនឌ័រលើអ្នកធ្វើការតាមផ្ទះ

- ចេញសេចក្តីប្រកាសពីភាពខុសច្បាប់នៃការធ្វើការងារផ្ទះចំពោះកុមារនិងយុវវ័យអាយុក្រោយ១៨ឆ្នាំ ដោយសារការងារនេះប្រឈមភាពគ្រោះថ្នាក់ចំពោះកុមារ
- អនុម័តវិធានការឆ្លើយតបនឹងភាពស្មើគ្នាយេនឌ័រ ដូចជាការបង្កើតអង្គភាពប៉ូលិស និងប្រព័ន្ធតុលាការ ដាច់ដោយឡែកដែលមានមន្ត្រីជាស្ត្រីក្នុងការធ្វើការដោះស្រាយករណីអំពើហិង្សាផ្លូវភេទ និង
- ពង្រឹងអំណាចប្រតិបត្តិរបស់គណៈកម្មាធិការជាតិការពារស្ត្រីនិងសិទ្ធិកុមារ (National Commissions for Women and for the Protection of Child Rights)។ ដូច្នេះ សេចក្តីណែនាំរបស់គណៈកម្មាធិការនេះដាក់ស្នើទៅកាន់នាយកដ្ឋានរដ្ឋាភិបាលនានា ដូចជាមន្ត្រីអនុវត្តច្បាប់ជាដើម នឹងផ្សារភ្ជាប់ជាមួយកាតព្វកិច្ចក្នុងកិច្ចការងារ។

ក្រមព្រហ្មទណ្ឌនិងច្បាប់ឧក្រិដ្ឋតម្រូវឲ្យមានការដាក់បន្ទុកភស្តុតាងច្រើននិងនិតិវិធីដោះស្រាយដែលទាមទារពេលវេលាយូរនិងការចំណាយប្រាក់កាក់ច្រើន។ អ្នកធ្វើការតាមផ្ទះចំនួនតិចប៉ុណ្ណោះដែលត្រូវបានការពារពីការបៀតបៀននិងអំពើហិង្សាដែលមានចែងក្នុងច្បាប់ការងារ។

- ក្នុងប្រទេសបង់ក្លាដែសនិងឥណ្ឌា ច្បាប់ការងារត្រូវបានគេឲ្យដឹងថាមិនទាន់មានប្រសិទ្ធិភាពនៅឡើយ។
- ប្រទេសហ្វីលីពីនគឺជាប្រទេសទីមួយដែលមានច្បាប់អ្នកធ្វើការតាមផ្ទះជាតិពេញលេញដោយមានការអនុវត្តច្បាប់និងបញ្ញត្តិនានាដើម្បីផ្តល់នូវការការពារផ្នែកការងារនិងសង្គមដល់អ្នកធ្វើការតាមផ្ទះ។ ក្នុងប្រទេសអាស៊ានមួយនេះ ឧបសគ្គមួយនោះគឺការអនុវត្តច្បាប់ឲ្យមានប្រសិទ្ធភាពក្នុងថ្នាក់ឃុំនិងថ្នាក់ស្រុកដែលជាទូទៅនយោជកនិងមន្ត្រីអនុវត្តច្បាប់ជាសាច់ញាតិឬអ្នកស្គាល់គ្នា និងធនធានហិរញ្ញវត្ថុនិងធនធានមនុស្សមន្ត្រីរដ្ឋាភិបាលមានភាពខ្វះខាត។
- នៅក្នុងទីក្រុងហុងកុង អ្នកធ្វើការតាមផ្ទះអន្តោប្រវេសន៍ទទួលការការពារដោយច្បាប់ការងារនិងច្បាប់សមភាព ដូចនេះពួកគេអាចស្វែងរកយន្តការណ៍អនុវត្តពាក់ព័ន្ធនានា ដូចជាយន្តការណ៍ដំណោះស្រាយជម្លោះការងារ និងយន្តការសមភាពនានា។ ករណីសាច់រឿងរបស់អ្នកស្រី Baby Jane បានបង្ហាញអំពីយន្តការណ៍ដំណោះស្រាយជម្លោះដែលត្រូវបានអនុវត្ត។ ប៉ុន្តែការអនុវត្តមានភាពវៀចវេរដោយសារភាពទន់ខ្សោយរបស់អ្នកស្រី បើទោះបីជានយោជករូបនោះចុងក្រោយបានសម្រេចឲ្យធ្វើការទូទាត់សំណងទៅដល់ជនរងគ្រោះក្តី។

ទោះបីជាយ៉ាងណាក៏ដោយ ស្ថានភាពរបស់អ្នកស្រី Baby Jane អាចនាំឲ្យមានចន្លោះខ្វះខាតដ៏ធំមួយក្នុងច្បាប់ការងារដែលមានក្នុងប្រទេស ដែលនយោជកតម្រូវឲ្យមានការទូទាត់សំណងការព្យាបាលអ្នកធ្វើការតាមផ្ទះអន្តោប្រវេសន៍អំឡុងការធ្វើការរបស់នយោជិក ប៉ុន្តែនយោជកនោះមិនបានធ្វើការទូទាត់នោះឡើយ ហើយថែមទាំងបានបញ្ចប់កុងត្រា និងធ្វើការបណ្តេញចេញយ៉ាងកម្រោលនិងយ៉ាងអយុត្តិធម៌បំផុត។ អ្នកស្រី Baby Jane ត្រូវបានបណ្តេញចេញដោយសារតែអ្នកស្រីមានជំងឺមហារីក និងពាក្យបណ្តឹងទី២ប្រឆាំងនឹងការរើសអើងការងារក្រោម បទបញ្ញត្តិរើសអើងជនពិការ (Disability Discrimination Ordinance) នៅព្យួរនៅឡើយនៅគណៈកម្មការឱកាសស្មើភាពគ្នា (EOC)។

បន្ថែមពីនេះ មាត្រាមួយចំនួនដែលចែងក្នុងច្បាប់អន្តោប្រវេសន៍ហុងកុងកាន់តែធ្វើឲ្យមានហានិភ័យដល់អ្នកធ្វើការតាមផ្ទះអន្តោរប្រវេសន៍ឲ្យមានការប្រឈមនឹងការបៀតបៀននិងអំពើហិង្សាដោយសារនយោជក។ មាត្រា

ទាំងនោះរួមមានទាំងច្បាប់ស្នាក់នៅជាមួយនយោជកដែលអ្នកធ្វើការតាមផ្ទះត្រូវស្នាក់នៅក្នុងការគ្រប់គ្រងរបស់នយោជក និងច្បាប់២សប្តាហ៍ ដែលទាមទារឲ្យអ្នកធ្វើការតាមផ្ទះចាកចេញពីទីក្រុងហុងកុងក្នុងរយៈពេល២សប្តាហ៍ក្រោយការបញ្ចប់កិច្ចសន្យាការងារ។



ការប្រមូលផ្តុំរបស់សហព័ន្ធសហជីពអ្នកធ្វើការតាមផ្ទះអាស៊ី (FADWU) ក្នុងទីក្រុងហុងកុង [រូបភាព៖ IDWF]

## ការបៀតបៀននិងអំពើហិង្សាយេនឌ័រលើអ្នកធ្វើការតាមផ្ទះ

# សេចក្តីបញ្ចប់និងផ្លូវឆ្ពោះទៅមុខ

## សេចក្តីបញ្ចប់

ការបៀតបៀននិងអំពើហិង្សាយេនឌ័រលើអ្នកធ្វើការតាមផ្ទះគឺជាបញ្ហាដ៏គួរឲ្យព្រួយបារម្ភក្នុងប្រទេសក្នុងទ្វីបអាស៊ី។ ករណីសាច់រឿងជាច្រើនបានបង្ហាញឲ្យឃើញជាឧទាហរណ៍មួយចំនួននៃទម្រង់ផ្សេងនៃការបៀតបៀននិងអំពើហិង្សាផ្លូវកាយ ផ្លូវចិត្ត ផ្លូវភេទ និងផ្នែកសេដ្ឋកិច្ចទៅលើអ្នកធ្វើការតាមផ្ទះ និងបង្កផលប៉ះពាល់មួយចំនួនទៀតទៅលើសុខុមាលភាពនិងសុខភាពរបស់ពួកគេផងដែរ។ ការខ្លាចបាត់បង់ការងារធ្វើ និងការមិនមានជម្រើសដទៃ អ្នកធ្វើការតាមផ្ទះត្រូវស៊ូទ្រាំជាមួយការបំពារបំពាន រហូតទាល់តែគ្មានលទ្ធភាពក្នុងការស៊ូទ្រាំតទល់ទៀតបាន។ អ្នកធ្វើការតាមផ្ទះមួយចំនួនព្យាយាមស្វែងរកផ្លូវរត់គេច និងមួយចំនួនធ្លាក់ខ្លួនឈឺនិងឈឺរ៉ាំរ៉ៃបន្ទាប់ពីត្រូវបានជួយសង្គ្រោះ។ បើទោះបីជាបែបនេះក្តី អ្នកធ្វើការតាមផ្ទះជាច្រើនមានក្រុមបណ្តាញជួយគាំទ្ររបស់ពួកគេ និងហើយពួកគេត្រូវបានផ្តល់ការជួយគាំទ្រដូចជាការអប់រំ និងការងារ ហើយពួកគេអាចជាសះស្បើយផ្លូវចិត្តនិងមានកម្លាំងរឹងមាំក្នុងការជួយពង្រឹងចលនាអ្នកធ្វើការតាមផ្ទះដូចក្នុងករណីក្នុងប្រទេសបង់ក្លាដែស ឥណ្ឌា និងឥណ្ឌូនេស៊ីជាដើម។

អ្នកធ្វើការតាមផ្ទះជាច្រើនស្ថិតក្នុងហានិភ័យនៃការធ្លាក់ខ្លួនក្លាយជាជនរងគ្រោះនៃការបៀតបៀននិងអំពើហិង្សាដោយសារតែការងារផ្ទះមិនត្រូវបានគេមើលឃើញឲ្យតម្លៃនិងចាត់ទុកជាការងារ«ពិត» ហើយអ្នកធ្វើការតាមផ្ទះមិនត្រូវបានគេចាត់ទុកជាកម្មករ«ពិត»។ ការងារផ្ទះជាទូទៅជាការងារសម្រាប់ឋានៈទាប និងត្រូវចាត់ទុកថាជាការងាររបស់ស្ត្រីដែលគ្មានជំនាញ។ អ្នកធ្វើការតាមផ្ទះជាច្រើននាក់គឺជាស្ត្រីនិងកុមារីដែលសុទ្ធតែកំពុងប្រឈមមុខនឹងការរើសអើងយេនឌ័រ។ ពួកគេទាំងនោះតែងតែជួបនឹងទម្រង់ការរើសអើងផ្សេងៗពីព្រោះពួកគេមកពីគ្រួសារអន់ខ្សោយ ទីជនបទ ជនជាតិភាគតិច ក្រុមកុលសម្ព័ន្ធដែលមានការប្រកាន់ជំនឿសាសនា និងទទួលបានការអប់រំទាប។ ពួកគេទាំងនោះធ្វើការឲ្យនយោជកក្នុងទីក្រុងដែលពួកគេទាំងនោះជាអ្នកមាន មានឋានៈ តួនាទីមុខមាត់ មានការអប់រំល្អ និងមានអំណាចផងដែរដែលខុសឆ្ងាយពីអ្នកធ្វើការតាមផ្ទះ។ ទាំងអស់នេះដូចគ្នានឹងអ្នកធ្វើការតាមផ្ទះដែលធ្វើអន្តោប្រវេសន៍ពីប្រទេសកំណើតទៅកាន់ប្រទេសអភិវឌ្ឍន៍ស៊ីវិល័យដទៃទៀតដូចគ្នា។ ការបៀតបៀននិងអំពើហិង្សាលើអ្នកធ្វើការតាមផ្ទះមិនមែនជាស្ថានភាពដែលមិនត្រូវអើពើ លើកលែងនោះឡើយ ដោយវាមិនមែនជាអំពើដោយឡែករបស់បុគ្គលនយោជកទៅលើអ្នកធ្វើការតាមផ្ទះនៅពេលវេលានិងទីកន្លែងជាក់លាក់នោះឡើយ។ ការបៀតបៀននិងអំពើហិង្សាទៅលើអ្នកធ្វើការតាមផ្ទះគឺជា «ជាទង្វើជាប្រព័ន្ធ»។ វាគឺជាបាតុភូតនៃប្រព័ន្ធមួយដែលមានការ «ចាក់ឫសគល់យ៉ាងជ្រៅក្នុងរចនាសម្ព័ន្ធក្នុងសង្គម» រាប់តាំងពីរបៀបដែលការងារផ្ទះត្រូវបានរៀបចំឡើង ច្បាប់ទម្លាប់នានាត្រូវបានអនុវត្តលើអ្នកធ្វើការតាមផ្ទះ និងរបៀបដែលស្ថាប័នរដ្ឋាភិបាលដើរតួជំនួសពួកគេ នៅពេលមានការអនុវត្តច្បាប់។

**ករណីរឿងរ៉ាវទាំងនោះបង្ហាញថា៖**

- ការកង្វះការយល់ដឹងនិងភាពស្ថិតស្ថិរនៃភាពស្មើគ្នាយេនឌ័រនិងទម្រង់ផ្សេងៗនៃការរើសអើងចំពោះអ្នកធ្វើការតាមផ្ទះ រារាំងមិនឲ្យមានការអនុវត្តច្បាប់មានប្រសិទ្ធភាព បង្អាក់ការអភិវឌ្ឍនិងបង្កើតច្បាប់ថ្មី និងបង្កការប៉ះពាល់ដល់ការផ្តល់ជំនួយនិងការគាំទ្រទៅដល់អ្នកធ្វើការតាមផ្ទះដែលជាជនរងគ្រោះ ពីសំណាក់មន្ត្រីរដ្ឋាភិបាល (មានដូចជាប៉ូលិស តុលាការ មន្ត្រីការងារនិងសុខភាពជាដើម) មេដឹកនាំសហ

គមន៍ និងសាធារណៈជនទូទៅផងដែរ។

- ក្រុមព្រហ្មទណ្ឌអាចធ្វើការផ្តល់ជូននូវសំណងទៅដល់អ្នកធ្វើការតាមផ្ទះក្នុងករណីមានឃាតកម្ម និងការរំលោភបំពានផ្លូវកាយនិងផ្លូវភេទប៉ុណ្ណោះ។ វាពិតជាមានភាពចន្លោះខ្វះខាតខ្លាំងទៅលើយន្តការមានប្រសិទ្ធភាពក្នុងការអនុវត្តច្បាប់ ផ្តល់សំណងជំងឺចិត្តទៅជនរងគ្រោះ និងដាក់ទោសជនល្មើស។ DWOs និងជនរងគ្រោះជាច្រើននាក់ត្រូវបង្ខំចិត្តចំណាយធនធានមនុស្សនិងហិរញ្ញវត្ថុអស់ពេលជាច្រើនឆ្នាំដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ។ តែក៏មានករណីលើកលែងមួយចំនួន នៅពេលការរំលោភបំពានមានលក្ខណៈធ្ងន់ធ្ងរខ្លាំង នោះ DWOs និងអង្គការសង្គមស៊ីវិលដទៃទៀតអាចជួយស្វែងរកយុត្តិធម៌ដោយដាក់ទោសជនល្មើសបានដោយជោគជ័យ តាមរយៈការបង្កើតបណ្តាញនិងកេណ្ឌប្រមូលនាយកដ្ឋានរដ្ឋាភិបាលនិងអង្គការសង្គមស៊ីវិល និងលើកការតវ៉ាតស៊ូមតិរួមគ្នាជាសាធារណៈ។
- អ្នកធ្វើការតាមផ្ទះមិនត្រូវបានគេដាក់បញ្ចូលក្នុងច្បាប់ការពារពលកម្ម សមភាព កិច្ចគាំពារសង្គមឡើយក្នុងស្ទើគ្រប់ប្រទេសទាំងអស់ក្នុងពិភពលោក។ នេះមានន័យថាពួកគេមិនមានឬមានការការពារតិចតួចទៅនឹងទម្រង់ដទៃទៀតនៃការបៀតបៀននិងអំពើហិង្សាដែលមិនមានចែងឬដាក់បញ្ចូលក្នុងក្រមព្រហ្មទណ្ឌ។ លើសពីនេះ អ្នកធ្វើការតាមផ្ទះនិងនយោជកមិនអាចទទួលបានប្រយោជន៍ឬជំនួយពីការដាក់ពាក្យបណ្តឹង ការស៊ើបអង្កេត និងយន្តការដោះស្រាយជម្លោះដែលផ្តល់ជូនក្រោមទិដ្ឋភាពច្បាប់នៅឡើយ។

ជាចុងក្រោយ ករណីរឿងរ៉ាវបង្ហាញថាវាពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ **អ្នកធ្វើការតាមផ្ទះក្នុងការចងក្រងនិងអភិវឌ្ឍធ្វើឲ្យសហជីពនិងអង្គការអ្នកធ្វើការតាមផ្ទះ (DWOs) ឲ្យកាន់តែខ្លាំងបន្ថែមទៀត។** ករណីរឿងជាច្រើនក៏បានលើកបង្ហាញអំពី ភាពខ្លាំងដែលសហជីពនិងអង្គការអ្នកធ្វើការតាមផ្ទះ (DWOs) ថាជាខ្សែជីវិតរបស់អ្នកធ្វើការតាមផ្ទះដែលទទួលរងការឈឺចាប់ពីអំពើហិង្សានានា តាមរយៈការផ្តល់ជម្រកស្នាក់នៅ ជំនួយផ្នែកច្បាប់ ចរចាជាមួយនយោជកឬអាជ្ញាធរដើម្បីទទួលបានយុត្តិធម៌ជូនជនរងគ្រោះ និងជួយជនរងគ្រោះឲ្យរស់រឹងមាំម្តងទៀត និងក្លាយជាអ្នកដឹកនាំអ្នកធ្វើការតាមផ្ទះផងដែរ។ បន្ថែមពីនេះការផ្តល់សេវាជួយគាំទ្រដោយផ្ទាល់ ពួកគេក៏ចូលរួមក្នុងយុទ្ធនាការ និងការតស៊ូមតិដើម្បីការពារនិងដោះស្រាយអំពើហិង្សាលើអ្នកធ្វើការតាមផ្ទះ ស្ត្រី និងកុមារផងដែរ។ ពួកគេក្រើនរំលឹកនិងបញ្ជ្រាបការយល់ដឹងក្នុងចំណោមសមាជិកនិងអ្នកធ្វើការតាមផ្ទះបន្ថែម និងប្រមូលផ្តុំពួកគេដើម្បីធ្វើសកម្មភាពណាមួយផងដែរ។

អង្គការ DWOs នៅតែបន្តចូលរួមសកម្មភាពយុទ្ធសាស្ត្រជាមួយដៃគូរដ្ឋាភិបាលនិងក្រៅរដ្ឋាភិបាលបន្ថែម។ ពួកគេចង់ស្វែងរកដំណោះស្រាយរយៈពេលវែងដូចជាកំណែប្រែប្រព័ន្ធច្បាប់ និងយន្តការណ៍អនុវត្តមានប្រសិទ្ធភាពនានាដើម្បីការពារនិងដោះស្រាយបញ្ហាអំពើហិង្សាប្រឆាំងអ្នកធ្វើការតាមផ្ទះ រួមទាំងកុមារ មនុស្សវ័យជំទង់ និងក្រុមមនុស្សទន់ខ្សោយក្នុងសង្គមផងដែរ។ ករណីសិក្សាជាច្រើនបានបង្ហាញថា DWOs បានចូលរួមជាផ្នែក និងជួយពង្រឹងចលនាសិទ្ធិមនុស្សរបស់ស្ត្រី កម្មករ រាប់ចាប់ពីថ្នាក់តំបន់រហូតថ្នាក់ជាតិនិងអន្តរជាតិដើម្បីធានាថាមនុស្សគ្រប់រូបមានសិទ្ធិរស់នៅ និងធ្វើការដោយមិនមានការបៀតបៀននិងអំពើហិង្សា។

**ផ្លូវឆ្ពោះទៅមុខ**

«ការបង្ការការពារការបៀតបៀននិងអំពើហិង្សាក្នុងពិភពការងារគឺមានទំនាក់ទំនងយ៉ាងស្អិតល្អួតក្នុងឈានដល់ការបញ្ឈប់ការរើសអើង លើកកម្ពស់សមភាព និងការពង្រីកសន្តិសុខហិរញ្ញវត្ថុ។»

**NDWWU, Bangladesh and SEWA, India.[3]**

3 IDWF, វេទិកាទាមទារបញ្ឈប់ការបៀតបៀននិងអំពើហិង្សាលើស្ត្រីនិងបុរសក្នុងពិភពការងារ, ទីក្រុងហ្សឺណែវ ឆ្នាំ២០១៨

អនុសញ្ញាអាយឡូ (ILO) លេខ ១៨៩ (C189) និងអនុសាសន៍លេខ ២០១ (R201) ស្ដីអំពីការងារសមរម្យសម្រាប់អ្នកធ្វើការតាមផ្ទះ និងអនុសញ្ញាលេខ ១៩០ (c190) និងអនុសាសន៍លេខ ២០៦ (r206) ស្ដីអំពីការបៀតបៀននិងអំពើហិង្សាក្នុងពិភពការងារ ផ្ដល់នូវស្តង់ដារការងារអន្តរជាតិដើម្បីការពារនិងកាត់បន្ថយការបៀតបៀននិងអំពើហិង្សាលើអ្នកធ្វើការតាមផ្ទះ។ អនុសញ្ញាលេខ ១៩០ (c190) អំពាវនាវឲ្យសមាជិកអាយឡូ (ILO) ទាំងអស់ធ្វើការៈ

- អនុម័តការឆ្លើយតបនឹងសមភាពយេនឌ័រដើម្បីការពារនិងលុបបំបាត់ការបៀតបៀននិងអំពើហិង្សាក្នុងពិភពការងារ។ វិធីបែបនេះត្រូវការដោះស្រាយលើមូលហេតុមូលដ្ឋាន និងកត្តាហានិភ័យ មានដូចជាផ្នត់គំនិតយេនឌ័រ ទម្រង់ផ្សេងៗនៃការរើសអើង និងទំនាក់ទំនងអំណាចយេនឌ័រមិនស្មើភាពគ្នាជាដើម។
- កំណត់វិស័យ ប្រភេទការងារ និងការរៀបចំការងារដែលកម្មករមានការប្រឈមនឹងការបៀតបៀននិងអំពើហិង្សាច្រើនជាងគេ និងការធ្វើការវាយតម្លៃហានិភ័យ
- ធានាថាជនរងគ្រោះនៃការបៀតបៀននិងអំពើហិង្សាយេនឌ័រក្នុងពិភពការងារអាចធ្វើការដាក់ពាក្យបណ្ដឹង ការឆ្លើយតបនឹងសមភាពយេនឌ័រ សុវត្ថិភាពនិងប្រសិទ្ធភាព និងទាមទារយន្តការដំណោះស្រាយ ការជួយគាំទ្រ ផ្ដលសេវាកម្មនិងមធ្យោបាយផ្លូវច្បាប់នានា។

សហព័ន្ធអ្នកធ្វើការតាមផ្ទះអន្តរជាតិ (IDWF) នឹងនៅតែបន្តការជួយគាំទ្រនិងសហការជាមួយសមាជិករបស់ខ្លួនក្នុងការបញ្ចុះបញ្ចូលរដ្ឋាភិបាលប្រទេសនានាក្នុងការផ្ដល់សច្ចាប័នទៅលើអនុសញ្ញាលេខ ១៨៩ (C189) និងអនុសញ្ញាលេខ ១៩០ (c190) និងអនុវត្តអនុសញ្ញាទាំងនេះដោយអនុលោមតាមអនុសាសន៍លេខ ២០១ (R201) និងអនុសាសន៍លេខ ២០៦ (R206) ផងដែរ។ សមាជិករបស់សហព័ន្ធអ្នកធ្វើការតាមផ្ទះអន្តរជាតិ (IDWF) នៅក្នុងប្រទេសជាច្រើនបានធ្វើការកាត់បន្ថយការបៀតបៀននិងអំពើហិង្សាយេនឌ័រទៅលើអ្នកធ្វើការតាមផ្ទះជាអាទិភាពចម្បង។

ការបោះពុម្ពផ្សាយនៃករណីរឿងរ៉ាវទាំងអស់នេះគឺជាជំហានទី១ក្នុងការបង្កើនការយល់ដឹងនិងចែករំលែកបទពិសោធន៍របស់ DWOs ទៅលើការប្រយុទ្ធប្រឆាំងនឹងការបៀតបៀននិងអំពើហិង្សាលើអ្នកធ្វើការតាមផ្ទះក្នុងតំបន់អាស៊ី។

ជំហានទី២យើងនឹងធ្វើការអភិវឌ្ឍនិងដាក់ឲ្យប្រើប្រាស់ **«កញ្ចប់បណ្ដុះបណ្ដាលៈ អ្នកធ្វើការតាមផ្ទះចងក្រងដើម្បីប្រយុទ្ធប្រឆាំងនឹងការបៀតបៀននិងអំពើហិង្សា»** ដើម្បីបណ្ដុះឲ្យអ្នកធ្វើការតាមផ្ទះនិងស្ថាប័នរបស់ពួកគេឲ្យទទួលបានចំណេះដឹងនិងជំនាញក្នុងការទទួលបានការងារសមរម្យនិងកន្លែងការងារដែលមិនមានការបៀតបៀននិងអំពើហិង្សាសម្រាប់អ្នកធ្វើការតាមផ្ទះទាំងអស់។

# ឯកសារយោង

IDWF, *Platform of Demands on Violence and Harassment against Women and Men in the World of Work*, Geneva, 2018.

IDWF, *Resolution to Eradicate Gender-Based Violence*, adopted at the second worldwide IDWF Congress, Cape Town, 2018.

IDWF, *Report on IDWF survey of gender-based violence against domestic workers, Asia*, in partnership with Bread for the World and LEARN, Philippines, Hong Kong, January 2018.

ILO, *Convention No. 190 and Recommendation No. 206 on violence and harassment in the world of work,* Geneva, 2019.

ILO, *Domestic workers across the world: Global and regional statistics and the extent of legal protection,* Geneva, 2013.

ILO, *Convention No. 189 and Recommendation No. 201 on decent work for domestic workers*, Geneva, 2011.

ILO, *Equality and non-discrimination at work in East and South-East Asia, Guide*, Bangkok, 2011.

ILO and IDWF, *Decent work for domestic workers in Asia and the Pacific, Manual for trainers*, Bangkok and Hong Kong, 2012.

# ឧបសម្ព័ន្ធ

## របៀបសម្ភាស

1. សូមចែករំលែកករណីរឿងរ៉ាវនៃអំពើហិង្សាយេនឌ័រ (Gender Based Violence) ដែលសហជីពរបស់អ្នកបានជួបប្រទះនិងបានជួយដោះស្រាយ៖ យោងតាមទម្រង់របស់ IDWF ដើម្បីទាមទារអំពើហិង្សាយេនឌ័រ (GBV) ទម្រង់នៃអំពើហិង្សារអាចជាផ្លូវកាយ ផ្លូវចិត្ត សេដ្ឋកិច្ចឬហិរញ្ញវត្ថុ និងវប្បធម៌ជាដើម។

2. សូមចែករំលែកការវិភាគឬការអង្កេតរបស់អ្នកពាក់ព័ន្ធនឹងឧបសគ្គនិងចន្លោះខ្វះខាតក្នុងការប្រើប្រាស់ប្រព័ន្ធយុត្តិធម៌ក្នុងការជួយជនរងគ្រោះ។ តើវិធានការអ្វីដែលសហជីពរបស់អ្នកបានធ្វើឡើងដើម្បីស្វែងរកដំណោះស្រាយសម្រាប់ករណីនេះ? **ព្យាយាមសរសេរសាច់រឿងនេះឲ្យបានយ៉ាងហោចណាស់អតិបរិមា ៤០០ពាក្យ។**

## តារាងផ្ទៀងផ្ទាត់ទិន្នន័យ

| | | |
|---|---|---|
| ព័ត៌មាន | ឈ្មោះស្ថាប័ន<br>អាសយដ្ឋាន<br>ប្រភេទស្ថាប័ន | បំពេញរួចរាល់ (✓)<br>/ មិនទាន់បានបំពេញ (✕) |
| អ្នកនិពន្ធ | ឈ្មោះ<br>លេខទំនាក់ទំនង (លេខទូរស័ព្ទ/WhatsApp)<br>អ៊ីម៉ែល | |
| **របាយការណ៍ករណីរឿង** | | |
| នរណា | ជនរងគ្រោះ៖<br>ឈ្មោះ អាយុ ភេទ ទីកន្លែងកំណើត ឆ្នាំចូលធ្វើការ<br><br>ជនល្មើស៖<br>ឈ្មោះ<br>អាយុ<br>ភេទ<br>ទីកន្លែងកំណើត<br>ឆ្នាំជួលបម្រើការងារ | |
| ទីកន្លែង | ក្នុងផ្ទះ (ផ្ទះបាយ, បន្ទប់គេង, បន្ទប់ទទួលភ្ញៀវ, ទីធ្លាមុខផ្ទះ)<br>ទីក្រុង<br>ប្រទេស | |

| | | |
|---|---|---|
| ពេលវេលា | ភាពញឹកញាប់៖<br>តើញឹកញាប់ប៉ុណ្ណា? (រៀងរាល់ថ្ងៃ, រៀងរាល់សប្តាហ៍, មួយខែម្តង)<br><br>ថ្ងៃទី & ឆ្នាំ៖<br><br>ម៉ោង៖<br>ពេលយប់ (ពាក់កណ្តាលយប់)<br>ថ្ងៃ (ព្រឹក រសៀល) | |
| អ្វី | ប្រភេទនៃអំពើហិង្សាយេនដ័រ៖<br>ផ្លូវអារម្មណ៍/ផ្លូវកាយ/ផ្នែកហិរញ្ញវត្ថុ/វប្បធម៌<br><br>ពណ៌នាអំពីអំពើហិង្សា៖<br>សកម្មភាព<br>ពណ៌នាសកម្មភាព<br><br>តើអ្វីជាអំពើហិង្សាយេនឌ័រ?<br>សូមធ្វើការពន្យល់។ | |
| របៀបណា | តើអ្វីជាជម្លោះកើតឡើង?<br>ហេតុផល<br>ភាពខ្វែងគំនិត<br>កំហុស<br><br>តើមូលហេតុនៃជម្លោះជាអ្វី?<br><br>ហេតុអ្វីមានអំពើហិង្សាយេនឌ័រកើតឡើង?<br>សូមធ្វើការពន្យល់។ | |
| **ផលប៉ះពាល់នៃអំពើហិង្សាយេនឌ័រ** | | |
| លើជនរងគ្រោះ | ផ្លូវចិត្ត<br>ផ្លូវកាយ<br>ផ្លូវអារម្មណ៍<br>ហិរញ្ញវត្ថុ<br>សង្គម (គ្រួសារ) | |

| | | |
|---|---|---|
| លើជនល្មើស | ផ្លូវចិត្ត<br>ផ្លូវកាយ<br>ផ្លូវអារម្មណ៍<br>ហិរញ្ញវត្ថុ<br>សង្គម (គ្រួសារ) | |
| **ការឆ្លើយតបពីជនរងគ្រោះ** | | |
| ការប្រតិកម្ម/ការឆ្លើយតបភ្លាមៗ | | |
| វិធានការអនុវត្ត | | |
| លទ្ធផលនៃវិធានការ | | |
| ឧបសគ្គប្រឈម | | |
| **ការជួយគាំទ្រពីស្ថាប័ននានា** | | |
| វិធានការអនុវត្តដោយសហជីព | | |
| លទ្ធផលនៃវិធានការ | | |
| ឧបសគ្គប្រឈម | | |
| ករណីជោគជ័យ | | |
| មេរៀនដែលបានរៀនសូត្រ | | |
| ឆ្លុះបញ្ចាំងការអនុវត្តល្អក្នុងការការពារកុំឲ្យមានការកើតឡើងម្តងទៀត | | |
| **គោលការណ៍ផ្លូវច្បាប់ ( ច្បាប់ & គោលនយោបាយ )** | | |
| វិធានការផ្លូវច្បាប់ដែលបានអនុវត្ត | | |
| ការកាត់ក្តី | | |
| លទ្ធផលនៃការកាត់ក្តី | | |
| ផលប៉ះពាល់លើជនរងគ្រោះ | | |
| ផលប៉ះពាល់លើជនល្មើស | | |
| ឧបសគ្គប្រឈម | | |
| ការសំណូមពរធ្វើការផ្លាស់ប្តូរ | | |

ការបៀតបៀននិងអំពើហិង្សាយេនឌ័រលើអ្នកធ្វើការតាមផ្ទះ:

# ទំនាក់ទំនងស្ថាប័ននានា

**JALA PRT, Indonesia**

tel: +62 81247200500
secretariat address: Jl. kalibata Utara I no.38 a, rt.1/rW.2, kalibata, kec. pancoran, kota Jakarta selatan, Daerah khusus Ibukota Jakarta 12740, Indonesia
email: jala_prt@yahoo.com
blog: http://www.tungkumenyala.com/ Facebook: Jala prt

**ADW — Cambodia**

tel: +855 078 711 494/098 575 174/097 55 92 109
address: #1h, street 907, sangkat toul sangker, khan reosey kao, phnom penh, cambodia email: adwcambodia@gmail.com
Facebook: association of Domestic Workers -aDW

**UNITED — Philippines**

tel: +63(02) 332-1434
address: 94 scout Delgado, laging handa, quezon city, philippines email: unitedphildomworkers@gmail.com
Facebook: United Domestic Workers of the Philippines

**NDWF Patna — India**

tel: + 91 9708809122
address: 5b 1 kulharia complex, ashok rajpath, bankipur, patna 4, India email: indiandwf@gmail.com

**GKS — Gurgaon, India**

tel: +91 9560352313 / 7042310055
address: house no 375, Dada wala mohalla, behind mcD school, kapashera, south West Delhi, India
email: gksgurgaon@gmail.com




**NDDWU— Bangladesh**

tel: +88-01718683331
address: 31/F, topkhana road, Dhaka-1000,
bangladesh
email:murshida_ndwwuakter@yahoo.com

**SKDWA - Kuwait**

email: sandigankw@gmail.com
Facebook: Sandigan Kuwait Domestic Workers Association

**FADWU — Hong Kong**

tel: +852 2770 8668 / 9163 3734
address: 19/F 557-559 nathan road, kowloon,
hong kong email: fadwu.hk@gmail.com
Facebook: @HKFADWU




# ការបៀតបៀននិងអំពើហិង្សាយេនឌ័រលើអ្នកធ្វើការតាមផ្ទះ

## ករណីរឿងកើតឡើងក្នុងបណ្ដាប្រទេសអាស៊ី

**International Domestic Workers Federation**

### ទំនាក់ទំនង IDWF

សហព័ន្ធអ្នកធ្វើការតាមផ្ទះអន្តរជាតិ (IDWF)

**Workshop No. 13, 13/F, Kwai Cheong Centre,**
**No. 50 Kwai Cheong Road, Kwai Chung, N.T.**
**Hong Kong**

email: info@idwfed.org

www.idwfed.org

Facebook: IDWFED